ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 12-Jun-2013, 13:27
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣**

**ម៉ោង ០៨: ៣៤នាទី**

**សវនាការលើកទី១៨៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms. Faiza ZOUAKRI)*

លោកស្រី មីរាម ម៉ាហ្វេសសាន់ទិ
*(Ms Miriam MAFESSANTI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ ដារាវស្មី

លោក វ៉េង ហ៊ត់

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ(*Mr.Victor KOPPE*)

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ (*Ms. Anta GUISSE*)

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ូនណូហ្វត

(*Ms. Elisabeth SIMONNEAU-FORT*)

លោក ហុង គឹមសួន

លោកស្រី គ្រីស្ទីន ម៉ាទីណូ

(*Ms. Chritine MARTINAU*)

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| លោក សុន អរុណ | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោកស្រី គ្រីស្ទីន ម៉ាទីណូ | បារាំង |
| លោក នួន ជា | ខ្មែរ |
| លោក ស៊ីដនី ស្ដេនប៊ឹក (TCW-624) | អង់គ្លេស |
| លោក ឈឹម សុធារ៉ា (TCE-12) | ខ្មែរ |

## ឧបសម្ព័ន្ធ

### **ការសួរសំណួរទៅសាក្សី:  លោក ស៊ីដនី ស្កេនប៊ីក** (TCW-624)


សួរដោយបន្តលោក អាប់ឌុលឡាក់ ថារីក ផ្ដើមពី ........................................................ទំព័រ ៣
សួរដោយលោក ពេជ អង្គ ផ្ដើមពី ....................................................................ទំព័រ ២០
សួរដោយលោកស្រី គ្រីស្ទីន ម៉ាទីណូ ផ្ដើមពី ..........................................................ទំព័រ ២១
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី...................................................................ទំព័រ ៣១


### **ការសួរសំណួរទៅអ្នកជំនាញ:  លោក ឈឹម សុធារ៉ា** (TCE-12)


សួរដោយបន្តលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្ដើមពី ..................................................ទំព័រ ៥៥
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី...................................................................ទំព័រ ៦៣
សួរដោយលោក គង់ សំអុន ផ្ដើមពី .....................................................................ទំព័រ ៨០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៨:៣៤:១៥]

ប្រធានអង្គជំនុំ៖

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនៅព្រឹកនេះ យើងនឹងបន្តធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ស្តេនប៊ឹក តាមប្រព័ន្ធសោតទស្សន៍ពីសហរដ្ឋអាមេរិក។

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលត្រូវផ្តល់ស្តាប់សក្ខីកម្មនៅព្រឹកនេះ ហើយនិងបញ្ហាទាំងឡាយដែលមាន ប្រសិនបើមានក្នុងអំឡុងពេលដំណើរការសវនាការកន្លងមក។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ សូមកត់សម្គាល់ដោយឡែកលោក នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនដែលនៅពីខាងក្រោមបន្ទប់សវនាការនេះ តាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមូលហេតុបញ្ហាសុខភាព។ នៅពេលព្រឹកនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី ស៊ីដនី ស្តេនប៊ឹក តាមរយៈប្រព័ន្ធសោតទស្សន៍ពីសហរដ្ឋអាមេរិក។ ហើយសាក្សីរូបនេះបានត្រៀមខ្លួនរួចជាស្រេចសម្រាប់ការផ្តល់សក្ខីកម្មផងដែរ។

[០៨:៣៥:៤៤]

ចំណែកនៅពេលរសៀល យើងនឹងបន្តស្តាប់សក្ខីកម្មអ្នកជំនាញ ឈឹម សុធារ៉ា។ ហើយនៅថ្ងៃនេះមានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម TCW-665។ សាក្សីនេះបានបញ្ជាក់ថាតាមសមត្ថភាពដែលគាត់អាចដឹងគឺគាត់មិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ ហើយគាត់បានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៣។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជម្រាបសួរ!

សូមអញ្ជើញលោកមេធាវី!

**លោក សុន អរុណ៖**

នៅអំឡុងពេលធ្វើសក្ខីកម្មសាក្សី ស៊ីដនី ស្កេនប៊ឺក នេះលោក នួន ជា គាត់នឹងសូមធ្វើសេចក្ដីបំភ្លឺអំពីផែនការជម្លៀសប្រជាជនចេញពីទីក្រុងនានា និងពិសេសពីទីក្រុងភ្នំពេញ។ ហើយសូមការអនុញ្ញាតពីលោកប្រធានរយៈពេលពីណាក៏បានដែរ ប៉ុន្តែក្នុងរយៈពេលដែលសក្ខីកម្មរបស់លោក ស៊ីដនី ស្កេនប៊ឺក ថ្ងៃហ្នឹង ឬក៏ស្អែកទៅតាម។ អរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការផ្ដល់នូវព័ត៌មាននេះ។

សួស្ដីលោក ស៊ីដនី ស្កេនប៊ឺក!

**លោក ស៊ីដនី ស្កេនប៊ឺក៖**

សូមជម្រាបសួរលោកប្រធាន។

[០៨:៣៧:២៧]

**ប្រធានអង្គជំនុំ៖**

លោក ស្កេនប៊ឺក កាលពីលោកដែលផ្ដល់សក្ខីកម្មកាលពីម្សិលមិញ មានបញ្ហាលំបាក ឬក៏បញ្ហាអ្វីកើតឡើងទេ នៅខាងលោកឯណោះ?

**លោក ស៊ីដនី ស្កេនប៊ឺក៖**

អត់មានទេលោកប្រធាន។ ខ្ញុំគិតថា ខ្ញុំបានដឹងអំពីនីតិវិធីច្បាស់លាស់ ហើយខ្ញុំមិនមានបញ្ហាអ្វីទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តនេះអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរយៈពេលក្នុងការសួរដេញដោលចំពោះសាក្សី ស៊ីដនី ស្កេនប៊ឺក មួយវគ្គសវនាការព្រឹកនេះទៀត។ ហើយក៏សូមជម្រាបផងដែរថា តាមទទួលព័ត៌មានគឺមានបញ្ហាបន្តិចបន្តួចអំពីការពិបាកក្នុងការស្វែងរកចំណុចដែលភាគីបានដកស្រង់ដើម្បីសួរដេញ

ដោលចំពោះគាត់ ព្រោះកាលណាតែយើងបង្ហាញតែលេខ ERN ទេ ការមើលហ្នឹងមិនទាន់ទេ អ៊ីចឹងគួរតែពិចារណា និងកំណត់ដល់ចំណុចបន្ទាត់ ឬក៏កថាខណ្ឌនៃឯកសារដែលយោងផង ដើម្បីឲ្យគាត់ងាយក្នុងការស្វែងរក ហើយនិងមើលទាន់ និងអាចឆ្លើយទាន់ចំពោះសំណួរដែលសួរបាទ។

សូមអញ្ជើញ!

[០៨:៣៨:៥៨]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។ សូមជម្រាបសួរមេធាវី។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** សូមជម្រាបសួរលោក ស្តេនប៊ឹក! ហើយសូមអរគុណដែលលោកបានត្រឡប់មកវិញដើម្បីផ្តល់សក្ខីកម្មក្នុងការជួយដល់តុលាការទៅលើបញ្ហាមួយនេះ។ ឥឡូវនេះ ខ្ញុំបង្ហាញជាផែនទីបង្ហាញផ្លូវទូទៅមួយ ដើម្បីខ្ញុំធ្វើការចោទសួរសំណួរទៅលោក ហើយខ្ញុំចង់សាកសួរអំពីការជម្លៀសប្រជាជនចេញពីទីក្រុង។ គឺព្រឹត្តិការណ៍ដែលលោកបានពណ៌នានៅក្នុងសៀវភៅកំណត់ហេតុរបស់លោក ដែលនិយាយអំពីការស្វែងរកមន្ត្រីរបបសាធារណរដ្ឋ។ ហើយបន្ទាប់មកយើងនឹងនិយាយអំពីព្រឹត្តិការណ៍ដែលលោកបានសង្កេតឃើញនៅក្នុងស្ថានទូតបារាំង ហើយនិងចុងក្រោយបំផុត គឺនិយាយអំពីដំណើររបស់លោកចាកចេញពីទីក្រុងភ្នំពេញទៅកាន់ប្រទេសថៃ។

មុនពេលខ្ញុំចាប់ផ្តើមទៅលើប្រធានបទទាំងអស់នោះ ខ្ញុំចង់សាកសួរលោកអំពីបញ្ហាមួយចំនួនតូចទាក់ទងទៅនឹងសៀវភៅកំណត់ហេតុដែលខ្ញុំគួរតែសួរលោកតាំងពីម្សិលមិញមក។ សៀវភៅកំណត់ហេតុគឺនិយាយអំពី គឺចាប់ផ្តើមពីថ្ងៃទី០៤ ខែមករា រហូតដល់ខែ៥ គឺថ្ងៃទី០៣ ខែ៥ ឆ្នាំ១៩៧៥។ ហើយវាជាកំណត់ត្រាប្រចាំថ្ងៃ គឺជារៀងរាល់ថ្ងៃតែម្តង។ ដូច្នេះជាដំបូង ខ្ញុំចង់សួរលោកថាតើលោកចាប់ផ្តើមកត់ត្រាព័ត៌មានទាំងអស់នេះនៅពេលណា?

[០៨:៤០:៣១]

**លោក ស៊ីដនី ស្តេនប៊ឹក៖**

**ឆ៖** គឺថាខ្ញុំចាប់ផ្តើមនៅពេលដើមឆ្នាំនោះ គឺដើមឆ្នាំ១៩៧៥ ដើម្បីធ្វើការកត់ត្រានូវកំណត់-

ហេតុប្រចាំថ្ងៃ។ តាមពិតទៅ ខ្ញុំមិនទម្លាប់សរសេរសៀវភៅកំណត់ហេតុនោះទេ រហូតដល់ពេលដែលខ្ញុំចាកចេញពីទីក្រុងភ្នំពេញ គឺនៅពេលដែលខ្ញុំមកដល់ទីក្រុងបាងកក ទើបខ្ញុំចាប់ផ្ដើមសរសេរសៀវភៅកំណត់ហេតុ។ ហើយសៀវភៅនេះ មិនដែលធ្វើការបោះពុម្ពផ្សាយទេ ព្រោះរឿងដែលខ្ញុំសរសេរ បន្ទាប់ពីខ្ញុំបានចាកចេញភ្លាមៗ គឺក្រោយដែលខ្ញុំបានទទួលសេរីភាពភ្លាមៗ គឺវារៀបរាប់អំពីហេតុការណ៍ដដែលៗ ឬក៏វាមានមូលដ្ឋានដដែលៗ។ ដូច្នេះ ខ្ញុំគិតថាមិនចាំបាច់ត្រូវការបោះពុម្ពផ្សាយនោះទេ ប៉ុន្តែខ្ញុំនៅតែរក្សាទុកវា។

[០៨:៤១:២២]

**ស៖** តើលោកធ្វើការកត់ត្រាដែរឬទេ នៅក្នុងរយៈពេលដែលលោកបានរៀបរាប់នៅក្នុងសៀវ-ភៅកំណត់ត្រានោះ?

**ឆ៖** បាទ សៀវភៅកត់ត្រារបស់ខ្ញុំគឺមានព័ត៌មានជាច្រើន ក៏ដូចជាមានព័ត៌មាននៅក្នុងសារព័ត៌-មានជាច្រើនដែរ។ ប៉ុន្តែខ្ញុំគិតថា ការប្រើប្រាស់សៀវភៅកំណត់ហេតុ វាមានប្រយោជន៍។

**ស៖** តើលោកមានបានប្រើប្រាស់សៀវភៅដើម្បីជួយដល់ការសរសេរកំណត់ហេតុរបស់លោកទេ?

**ឆ៖** បាទ ខ្ញុំប្រើប្រាស់។

**ស៖** ខ្ញុំមានសំណួរមួយទៀត ទាក់ទងទៅនឹងការងាររបស់លោកផងដែរ គឺព័ត៌មានដែលយើងមានចំពោះមុខតុលាការ។ គឺព័ត៌មានដែលមាននៅក្នុងឯកសារ នៅក្នុងតុលាការគឺលោកបានបញ្ជាក់ថាលោកបានទទួលនូវពានរង្វាន់មួយ គឺនៅក្នុងឆ្នាំ៧៦។ តើលោកអាចប្រាប់តុលាការបានដែរឬទេ ថាតើពានរង្វាន់អ្វីដែលលោកបានទទួល? ហើយគេផ្ដល់រង្វាន់ដើម្បីអ្វី?

**ឆ៖** គឺជាពានរង្វាន់ដែលគេផ្ដល់ចំពោះអ្នកយកសារព័ត៌មានបរទេសដែលប្រថុយប្រថានខ្ពស់ដែលហ៊ានប្រថុយប្រថានខ្ពស់ ហើយខ្ញុំទទួលយកពានរង្វាន់នេះ ដោយសារតែក្នុងនាមឲ្យជំនួយការហើយក៏ដូចជាបងប្អូនរបស់ខ្ញុំ គឺលោក ឌិត ប្រន។ ព្រោះថាដោយសារ ប្រសិនបើគ្មាន ឌិត ប្រន ទេ ខ្ញុំមិនអាចធ្វើការងារដូចដែលខ្ញុំបានធ្វើនោះទេ។

[០៨:៤២:៥៣]

**ស៖** នៅពេលដែលលោកនិយាយថា ពានរង្វាន់ដែលផ្ដល់ឲ្យហ្នឹង គឺផ្ដល់ឲ្យសម្រាប់អ្នកដែលប្រថុយប្រថានខ្ពស់។ តើប្រថុយប្រថានខ្ពស់នៅក្នុងប្រទេសកម្ពុជាទេ?

**ឆ៖** បាទ គឺគេផ្តល់ពានរង្វាន់ចំពោះការដែលខ្ញុំនៅបន្តរហូតនៅក្នុងស្ថានទូតអាមេរិក។ ហើយខ្ញុំចាកចេញគឺថានៅថ្ងៃ១២ ខែមេសា ចាកចេញពីស្ថានទូតនោះ។ គឺថាខ្ញុំមិនចាកចេញទៅប្រទេសអាមេរិកជាមួយអ្នកព័ត៌មានដទៃទៀតទេ គឺខ្ញុំនៅបន្តនៅក្នុងប្រទេសកម្ពុជា។ ហើយខ្ញុំ និង ឌិត ប្រន គឺយើងសម្រេចថានៅដល់ថ្ងៃនោះ ហើយយើងនៅមើលការជម្លៀស ហើយគ្រួសាររបស់ ឌិត ប្រន ក៏បានធ្វើដំណើរចេញទៅប្រទេសអាមេរិក។

**ស៖** សូមអរគុណលោក។ ឥឡូវនេះ ខ្ញុំបន្តទៅប្រធានបទថ្មីមួយទៀត ដែលខ្ញុំបានបង្ហាញប្រាប់លោកមុននេះបន្តិច។ ឥឡូវនេះ គឺយើងនិយាយអំពីការជម្លៀស គឺរូបភាពនៃការជម្លៀសដែលលោកបានកត់ត្រានៅក្នុងសៀវភៅកំណត់ហេតុរបស់លោក។ ឥឡូវនេះ ខ្ញុំចង់សួរលោកអំពីហេតុការណ៍ចំនួន។ លោកបានពណ៌នាអំពី -- នៅក្នុងចំណុចជាច្រើននៅក្នុងសៀវភៅកំណត់ហេតុរបស់លោកអំពីការលួច ឬការប្លន់ទំនិញ។ ជាឧទាហរណ៍ ខ្ញុំសូមធ្វើការអាននូវព័ត៌មានមួយចំនួនដែលខ្ញុំសូមធ្វើការដកស្រង់ ហើយខ្ញុំចង់ឲ្យលោកធ្វើការពន្យល់បន្ថែម។ គឺចំណុចនេះនៅក្នុងសៀវភៅរបស់លោក គឺឯកសារ E236/1/4/3.1, នៅទំព័រ៦៣ ដែលភាសាអង់គ្លេសមានលេខ 00898271 គឺនៅចុងទំព័រ នៅផ្នែកខាងក្រោមនៃទំព័រគឺប្រយោគក្រោមមួយចុងក្រោយគេ។ ខ្ញុំសូមធ្វើការដកស្រង់ "នៅពេលដែលទីក្រុងក្លាយទៅជាទីក្រុងខ្មោច គឺពួកវាយប្រហារបានធ្វើការទាមទារការលួចប្លន់ ហើយនិងការដុតកម្ទេចអគារ"។ ខ្ញុំចង់សួរលោកថា តើលោកឃើញការលួច ការដុតហ្នឹងប៉ុន្មាន ហើយតើលោកឃើញដោយរបៀបណា?

[០៥:៤៥:២៩]

**ឆ៖** ខ្ញុំឃើញលទ្ធផលនៃការលួច និងការដុតតែប៉ុណ្ណោះ។ គឺខ្ញុំឃើញអំពីលទ្ធផលដែលខ្មែរក្រហមត្រឡប់មកពីកណ្តាលទីក្រុងវិញ បន្ទាប់ពីគេលួចអីវ៉ាន់ ឬក៏បន្ទាប់ពីពួកគេបានយកអីវ៉ាន់ដែលគេបានដណ្តើមបានពីហាងនានាមក។ ហើយមន្ត្រីទូត ឬក៏អ្នកណាម្នាក់ដែលគេអនុញ្ញាតឲ្យចូលទៅក្នុងទីក្រុងហ្នឹង គឺថាអ្នកដែលត្រឡប់មកវិញ គឺគេប្រាប់យើងថាគេឃើញអ្វីខ្លះ។ ដូច្នេះហើយ នេះទាំងអស់គឺអ្វីដែលខ្ញុំនិយាយយោង។ ប៉ុន្តែតាមពិតទៅ ខ្ញុំមិនបានឃើញដោយផ្ទាល់ភ្នែកនោះទេ ខ្ញុំមិនបានឃើញការលួច ការដុតនេះទេ។

នៅពេលដែលពួកគេមកដល់ពីដំបូងនោះ គឺពួកខ្មែរក្រហមបានយកម៉ាស៊ីនអង្គុលីលេខ យកនាឡិកា ហើយនិងវិទ្យុរបស់ខ្ញុំនៅពេលដែលគេចាប់ខ្លួនខ្ញុំនោះ។ ហើយនៅពេលដែលគេយក គឺខ្ញុំអត់តវ៉ាទេ គឺអរណាស់បើសិនជាគេទុកខ្ញុំរស់ជីវិតនោះ។

[០៨:៤៦:៤៥]

**ស៖** ឥឡូវនេះខ្ញុំចង់និយាយបន្តិចអំពីពេលវេលាដែលលោកបានពណ៌នានេះ គឺនៅទំព័រ៦៨ ដល់ ៦៩។ លោកបានរៀបរាប់អំពីអ្វី -- ព្រឹត្តិការណ៍ដែលលោកបានឃើញ គឺព្រឹត្តិការណ៍ដែលពាក់ព័ន្ធទៅនឹងការយកទ្រព្យសម្បត្តិជាកម្មសិទ្ធិរបស់អ្នកដទៃ គឺនៅទំព័រ៦៨ និង៦៩ នៃសៀវភៅរបស់លោក គឺឯកសារមានលេខ 00898266 ដល់ 67។ ខ្ញុំសូមធ្វើការដកស្រង់ "ខ្ញុំឃើញមានអ្នកឡានដឹកអីវ៉ាន់ដែលមានទំនិញជាច្រើនដូចជាបារី អីវ៉ាន់ និងបារី។ ហើយពួកគេបានបើកផ្លូងស្ពាន ហើយយើងក៏មើលឃើញជនស៊ីវិលដែលបានធ្វើដូចគ្នានោះដែរ។ ទាហានបានដណ្តើមយកនាឡិកា ហើយនិងអីវ៉ាន់ពីប្រជាជនទាំងអស់នោះ"។ ខ្ញុំចង់សួរថា តើលោកបានសង្កេតឃើញអំពីការដែលទាហានយកវិទ្យុ និងនាឡិកាពីប្រជាជនដែរឬទេ?

**ផ៖** នេះគឺជាអ្វីដែលខ្ញុំបានឃើញផ្ទាល់នៅថ្ងៃទី១តែម្តង។ គឺនៅពេលដែលគេអបអរជ័យជម្នះហ្នឹង គឺពួកគេមកឈរក្បែរៗគ្នា ហើយគេលើកកំប៉ុងទឹកក្រូចដើម្បីអបអរ។ ប៉ុន្តែខ្ញុំមិនយល់ថាហេតុអ្វីទេ ប៉ុន្តែខ្ញុំគិតថាប្រហែលជាសង្គ្រាមចប់ហើយ ពួកគេអបអរការបញ្ចប់សង្គ្រាម។ ដូច្នេះខ្ញុំឃើញអំពីការលួច ប៉ុន្តែខ្ញុំអត់ឃើញពីការដុតអគារ ដុតអ្វីនោះទេ។ នៅពេលដែលយើងស្តាប់ឮអ្វីដែលកើតឡើងហើយនៅពេលដែលយើងស្តាប់ឮអ្វីដែលបានធ្វើនៅខាងក្រៅ គឺយើងឃើញថាទាហានមួយរូបនោះ គឺទាហានខ្មែរក្រហមមួយរូបនោះចូលទៅក្នុងឡាន ហើយគាត់បើកឡាន។ ប៉ុន្តែនិយាយតាមពិតទៅគឺថាទាហានខ្មែរក្រហមហ្នឹងអត់ចេះបើកឡាននោះទេ។ ខ្ញុំដឹងនៅពេលក្រោយ។

[០៨:៤៩:១២]

ហើយនិយាយតាមពិតទៅ គឺគាត់ឡើងជិះឡានហ្នឹង ប៉ុន្តែគាត់បញ្ឆេះអត់ឆេះសោះ។ ហើយនៅពេលដែលគាត់បញ្ឆេះឆេះហ្នឹង គឺគាត់បើកបុកជញ្ជាំងអគារតូចមួយ។

**ស៖** សូមអភ័យទោសលោក យើងត្រូវកាត់លោកបន្តិច ដោយសារតែខ្ញុំមិនមានពេលវេលាច្រើន ហើយសង្ឃឹមថាលោកអាចជួយខ្ញុំទៅលើបញ្ហាដទៃទៀត។ ដោយសារតែយើងធ្វើការពិភាក្សាអំពីអំឡុងពេលវេលានៅពេលដែលលោកត្រូវបានគេឃុំខ្លួន ហើយនិងលោកបានសង្កេតឃើញ ខ្ញុំចង់និយាយអំពីចម្លើយដែលលោកផ្តល់កាលពីម្សិលមិញ។ លោកបានរៀបរាប់អំពី ឌិត ប្រេន ជិះម៉ូតូជាមួយនឹងទាហានខ្មែរក្រហម ឬក៏មន្ត្រីខ្មែរក្រហម ហើយទៅឆ្ងាយប្រហែលជា២០-៣០នាទី។ ហើយនៅពេលគាត់ត្រឡប់មកវិញ លោកត្រូវបានគេដោះលែង។ តើលោកដឹងដែរឬទេថា ឌិត ប្រេន គាត់ទៅណាដែរ?

តើមានអ្វីកើតឡើងនៅពេលដែលគាត់ទៅនោះ?

[០៨:៥០:១៩]

**ឆ៖** គឺថាលោក ខិត ប្រន ទៅក្រសួងព័ត៌មាន។ នៅក្រសួងព័ត៌មានហ្នឹងគឺគេ ខ្មែរក្រហមគេបង្កើតទីបញ្ជាការបណ្ដោះអាសន្នមួយនៅទីនោះ។ ហើយគឺជាកន្លែងបន្ទាប់ពីគេដោះលែងយើង គេយកយើងទៅនោះតែម្ដងទៅក្រសួងព័ត៌មាននោះតែម្ដង។ ហើយអ្វីដែល ខិត ប្រន ធ្វើក៏មិនបានប្រាប់យើងភ្លាមៗនោះទេ ប៉ុន្តែនៅពេលដែលយើងត្រូវបានគេដោះលែងនោះគឺគាត់ប្រាប់ខ្ញុំថា គាត់គ្រាន់តែសួរមេទ័ពនៅទីនោះដើម្បីឱ្យឧត្តមសេនីយ៍នៅទីនោះពន្យល់ថាតើយើងធ្វើការងារអីខ្លះបាន។ ហើយនៅពេលនោះគឺថាមន្ត្រីខ្មែរក្រហមគាត់ទាក់ទងតាមវិទ្យុទាក់ទងទៅ ហើយបន្ទាប់មកគេឆ្លើយថាអ្នកសារព័ត៌មានអាចធ្វើការបាន។ ដូច្នេះគេក៏ឲ្យគាត់ត្រឡប់មកវិញជាមួយនឹងមន្ត្រីខ្មែរក្រហម។ ហើយមន្ត្រីខ្មែរក្រហមនោះប្រាប់ថា យើងស្របច្បាប់ យើងធ្វើការងារនឹងត្រូវច្បាប់។ ដូច្នេះគេមិនសម្លាប់យើងទេ។ ដូច្នេះគេក៏ដោះលែងយើងបន្ទាប់មក។

[០៨:៥១:៣៤]

**ស៖** សូមអរគុណលោក។ ឥឡូវនេះយើងនិយាយអំពីការជម្លៀសប្រជាជន ហើយនិងហេតុ-ការណ៍នានាដែលកើតឡើងនៅពេលជម្លៀសនោះ។ នៅក្នុងកំណត់ហេតុរបស់លោក លោកបានរៀបរាប់នៅទំព័រ ៧៦ ដល់ ៧៩ គឺលោករៀបរាប់អំពីមន្ត្រីនៅកាកបាទក្រហម និងមន្ត្រីអង្គការសហប្រជាជាតិ។ ខ្ញុំនឹងធ្វើការអានន្ទូវសំណួរទាំងអស់ នូវចំណុចទាំងអស់នេះ។

ចំណុចទី១ គឺនៅទំព័រ៧៦ ភាសាអង់គ្លេសមានលេខ 00898284។ នេះគឺជាការជជែកគ្នារវាងវេជ្ជបណ្ឌិតនៅកាកបាទក្រហម។ ខ្ញុំសូមធ្វើការដកស្រង់ "គេមិនបានគិតអំពីមនុស្សធម៌ទេ លោកស្រីម៉ារី កាមិសែល គឺវេជ្ជបណ្ឌិតនៅខាង ក្រុមរះកាត់កាកបាទក្រហមដែលបានពណ៌នាអំពីការបណ្ដេញប្រជាជនចេញពីមន្ទីរពេទ្យកាលពីម្សិលមិញ។ ពួកគេបណ្ដេញប្រជាជនទាំងអស់ សូម្បីតែអ្នករបួស សូម្បីតែអ្នកពិការ សូម្បីតែអ្នកដែលមានស្ថានភាពគ្រោះថ្នាក់ធ្ងន់ធ្ងរក៏គេចេញដែរ។ មនុស្សជាច្រើនបានស្លាប់។ វាជារឿងដ៏គួរឲ្យភ័យរន្ធត់យ៉ាងខ្លាំង។ ពួកបះបោរបានបង្ខំឲ្យអ្នកទាំងអស់គ្នាហ្នឹងបោះបង់ចោលអ្នកជំងឺ។ តើលោកអាចបញ្ជាក់បានដែរឬទេ ថាលោកបានស្ដាប់ ឬក៏បានជជែកជាមួយនឹងលោកស្រីវេជ្ជបណ្ឌិតនេះ?

[០៨:៥៣:១៥]

**ឆៈ** បាទ គឺខ្ញុំបានជជែកគ្នាមែន។

**សៈ** សូមអរគុណ។ ឥឡូវនេះខ្ញុំសូមដកស្រង់នូវចំណុចបន្តទៀតគឺទំព័រ៧៩, ភាសាអង់គ្លេស មានលេខ00898287 លោកបាននិយាយអំពីចំណុចមួយដែលធ្វើឡើងដោយអ្នកតំណាងសហប្រជាជាតិ ដែលខ្ញុំសូមធ្វើការដកស្រង់៖ “ហ្វីណាន់ ស៊ែល័រ ដែលជាប្រធានអ្នកតំណាងអង្គការសហប្រជាជាតិ នៅកម្ពុជាមានអារម្មណ៍ខឹងក្រេវក្រោធយ៉ាងខ្លាំង។ គាត់និយាយថាពួកគេហាក់ដូចជាមនុស្សមកពីភព ដទៃ គាត់និយាយ។ ការគិតរបស់ពួកគេគឺផ្ទុយពីអ្វីដែលយើងគិត។ ខ្ញុំប្រាប់គេថា ខ្ញុំអាចជួយបាន ប្រសិន បើគេចង់ឲ្យខ្ញុំជួយ។ ខ្ញុំនិយាយថា ខ្ញុំមានអ្នកជំនាញ៤២នាក់ នៅក្នុងទីក្រុងបាងកកអាចមកជួយបាន។ ប៉ុន្តែលោកដឹងទេ ថាគេធ្វើអី? ពួកគេហ្នឹងសើច។ គេមិនចង់ឲ្យយើងជួយទេ។ ខ្ញុំនឹងជួយពួកគេប្រសិនបើ ខ្ញុំអាច ប៉ុន្តែវាគ្មានផ្លូវដែលខ្ញុំអាចជួយគេបានទេ”។ ដូច្នេះអ្វីដែលខ្ញុំចង់សួរលោកនៅពេលនេះគឺថា តើ លោកបានជជែកជាមួយបុគ្គលម្នាក់នេះដែរឬទេ?

**ឆៈ** បាទ។ នេះគឺជាកំណត់ត្រារបស់ខ្ញុំ។

**សៈ** សូមអរគុណលោក។ តាមដែលលោកដឹងផ្អែកទៅលើអ្វីដែលលោកបានឃើញក៏ដូចអ្វីដែល លោកបានជជែក ឬក៏អ្វីដែលលោកបានស្តាប់ឮ តើភ្នាក់ងារមនុស្សធម៌ ដូចជាកាកបាទក្រហម ឬក៏ អង្គការសហប្រជាជាតិអាចផ្តល់ជំនួយមនុស្សធម៌ដល់ប្រជាជនដែលត្រូវបានគេជម្លៀសនៅពេលណា មួយចាប់ផ្តើមពីពេលជម្លៀសដែរឬទេ? តើពួកគេអាចផ្តល់ដែរឬទេ?

[០៨:៥៥:០០]

**ឆៈ** អត់ទេ គឺថាអ្នកផ្តល់ជំនួយមនុស្សធម៌ហ្នឹងត្រូវបានគេរាំងមិនឲ្យធ្វើការងារមនុស្សធម៌បាន។

**សៈ** សូមអរគុណលោក។ ការសុន្ទនានេះ គឺធ្វើឡើងនៅពេលដែលលោកស្នាក់នៅស្ថានទូតគឺ នៅថ្ងៃទី១៨ ខែមេសា។ នៅក្នុងពេលនោះលោកក៏បានរៀបរាប់អំពីការផ្សព្វផ្សាយតាមវិទ្យុដែលលោក បានស្តាប់ឮ គឺនៅទំព័រ១០៤ នៅក្នុងសៀវភៅកំណត់ហេតុ -- កំណត់ត្រា។ អង់គ្លេសមានលេខ 00898312 គឺនៅវេលាម៉ោងបួន ហើយលោកបានរៀបរាប់ដូចតទៅនេះ “វិទ្យុភ្នំពេញបានប្រកាសអំពី លទ្ធផលនៃសមាជជាពិសេស ដែលធ្វើឡើងនៅក្នុងទីក្រុង ហើយនិយាយថា សមាជបានបង្ហាញអំពីការ សម្រេចរបស់ប្រទេសក្នុងការតស៊ូយ៉ាងមុតមាំប្រឆាំងនឹងការជ្រៀតជ្រែករបស់បរទេសទៅក្នុងកិច្ចការ ផ្ទៃក្នុងកម្ពុជា។ ទោះបីថាជាការជ្រៀតជ្រែកផ្នែកយោធា នយោបាយ សេដ្ឋកិច្ចសង្គម ការទូត ឬក៏ការ ជ្រៀតជ្រែកដែលគេចាត់ទុកថា ជាការជ្រៀតជ្រែកផ្នែកមនុស្សធម៌ក៏ដោយ”។ ខ្ញុំចង់ដឹងថា តើការផ្សព្វ

ផ្សាយតាមវិទ្យុហ្នឹង ថាតើលោកស្ដាប់ឮផ្ទាល់ ឬក៏គេបកប្រែឲ្យលោកស្ដាប់ជាភាសា -- បកឲ្យស្ដាប់ពីភាសាខ្មែរ?

[០៨:៥៦:៤១]

**ផៈ** គឺថា ខ្ញុំមិនចាំទេ អំពីចំណុចនេះ។ ខ្ញុំមិនចាំថា ខ្ញុំស្ដាប់ផ្ទាល់ ឬក៏មិននោះទេ ហើយខ្ញុំក៏មិនចាំច្បាស់ថាវាជាភាសាខ្មែរ ឬក៏អីនោះដែរ។ ដូច្នេះខ្ញុំអាចឆ្លើយបានថា គេប្រាប់ខ្ញុំ។

**សៈ** សូមអរគុណលោក។ នៅក្នុងកថាខណ្ឌដែលយើងបានមើលពេលកន្លងមកនេះ គឺកថាខណ្ឌដែលរៀបរាប់អំពីវេជ្ជបណ្ឌិតត្រូវបានគេបង្ខំឲ្យចាកចេញពីសណ្ឋាគារឡឺភ្នំនោះ។ ខ្ញុំចង់ឲ្យលោកពិនិត្យមើលទៅលើហេតុការណ៍នៅតាមទីកន្លែងមួយចំនួនទៀត ដែលលោកបានរៀបរាប់នៅក្នុងកំណត់ត្រារបស់លោក គឺនៅទំព័រ៥០ នៃកំណត់ត្រារបស់លោក -- អ៎! មិនមែនទេគឺទំព័រ៨២ គឺអង់គ្លេសមានលេខ 00898290 គឺថ្ងៃទី១៩ ខែមេសា ដែលលោកកត់ត្រានៅម៉ោងប្រាំមួយល្ងាច លោកបានរៀបរាប់ដូចតទៅនេះ៖

"បុគ្គលិកមន្ទីរពេទ្យកាល់ម៉ែត ត្រូវបានបង្ខំចេញដោយពួកបះបោរបានមកដល់ស្ថានទូត ដោយជិះនៅក្នុងឡានដែលមានមនុស្សពេញ -- ពេលឡានខ្លះមានថ្នាំពេញនៅក្នុងនោះ។ គិលានុបដ្ឋាយិកាមកពីមន្ទីរពេទ្យបាននិយាយថា ពួកបះបោរនុំងបង្ខំសឹងតែអ្នកជំងឺទាំងអស់ឲ្យចេញពីមន្ទីរពេទ្យនៅក្នុងរយៈពេល២ថ្ងៃ។ អ្នកណាដែលមិនអាចដើរ គឺគេរុញមកដាក់ចោលនៅលើថ្នល់ដោយគេងនៅលើគ្រែ។ ចំពោះបុគ្គលិកដែលនៅខាងក្រោយ ឬក៏បុគ្គលិកទុកអ្នកជំងឺដែលធ្ងន់ធ្ងរនៅក្នុងមន្ទីរពេទ្យ។ យើងសង្ឃឹមថាគ្រូពេទ្យនឹងមកដល់ ប៉ុន្តែអត់មានទេ។ មិនមានគ្រូពេទ្យខ្មែរក្រហមណាមួយមកដល់នោះទេ។ សម្បីតែក្មេងដែលឈឺធ្ងន់ដែលគ្មានចំណីអាហារគ្រប់គ្រាន់ក៏គេទុកចោលដែរ គេទុកចោលប្រាំនាក់នៅទីនេះ"។ ដូច្នេះហើយ នេះគឺជាកំណត់ត្រាដែលលោកបានធ្វើនៅថ្ងៃទី១៩ មេសា។ តើត្រឹមត្រូវដែរឬទេ?

[០៨:៥៩:១៦]

**ផៈ** បាទគឺត្រឹមត្រូវ។ គឺថាបុគ្គលិកមន្ទីរពេទ្យកាល់ម៉ែត គាត់នៅបន្តការងាររបស់គាត់។ ខ្ញុំគិតថារដ្ឋាភិបាលបារាំង គេជួយដល់មន្ទីរពេទ្យកាល់ម៉ែតនៅពេលនោះ។ ហើយមន្ទីរពេទ្យកាល់ម៉ែតគឺនៅជិតស្ថានទូតបារាំង។ ដូច្នេះពួកគេប្រាប់យើងថា ប្រសិនបើគេបណ្ដេញចេញពីមន្ទីរពេទ្យ គឺពួកគេអាចចូលក្នុងស្ថានទូតបារាំង ហើយពួកគេធ្វើដូច្នេះមែន គឺគេជិះឡានច្រើន ដែលឡាននុំងមានទាំងថ្នាំពេទ្យមានទាំងគ្រឿងផ្គត់ផ្គង់វេជ្ជសាស្ត្រជាដើម។ គឺពួកគេត្រូវបានបណ្ដេញចេញដោយពួកខ្មែរក្រហមដោយ

យកកាំភ្លើងភ្ជង់ពួកគាត់ វាជាហេតុការណ៍គួរឲ្យរន្ធត់យ៉ាងខ្លាំង។

**ស៖** សូមអរគុណលោក។ ឥឡូវនេះខ្ញុំលើកឧទាហរណ៍មួយទៀត នៅទំព័រ១០១ នៅថ្ងៃទី២៦ ខែ០៤ ឆ្នាំ៧៥ គឺឯកសារដែលមានលេខ 00898309 នៅម៉ោង១០:១៥ ព្រឹក លោកបាននិយាយដូចតទៅនេះ៖ "ចំណុចខ្លា គឺថាអ្នកតំណាងមូលនិធិជួយសង្គ្រោះកុមារបានមកដល់ទូតជាចុងក្រោយ គឺថា៩ថ្ងៃបន្ទាប់ពីត្រូវបានគេឃុំខ្លួនគាត់នៅស្នាក់ការរបស់គាត់ ដោយសារតែគាត់ធ្វើការថែរក្សាក្មេងៗដែលត្រូវបានគេបោះបង់ចោលទីនោះ។ ដូចជាអ្នកដទៃដែរគាត់ត្រូវបានគេបណ្ដេញចេញដោយខ្មែរក្រហម ប៉ុន្តែដោយមិនមានការបង្ខំនោះឡើយ។

[០៩:០១:០៥]

ស្តូត បាននិយាយថាខ្មែរក្រហមមិនដឹងថាមាននរណាម្នាក់នៅក្នុងមន្ទីរពេទ្យទេ រហូតដល់ពេលក្មេងៗនោះវាយំខ្លាំងទើបគេដឹង។ ពីរបីថ្ងៃក្រោយបន្ទាប់ពីគ្រប់គ្រងទីក្រុងមក បន្ទាប់ពីបានធ្វើការទាក់ទាញចំណាប់អារម្មណ៍របស់ទាហាន ពួកខ្មែរក្រហមបានបង្ខំគាត់ឲ្យចាកចេញ ហើយឲ្យមកស្ថានទូត។ ពួកគេប្រាប់ថាក្មេងៗនឹងត្រូវបានគេបញ្ជូនទៅក្នុងសាលារៀន ប៉ុន្តែគាត់មិនជឿទេ ហើយគិលានុបដ្ឋាយិកាកម្ពុជាត្រូវបានគេបញ្ជូនទៅតាមទីជនបទដូចប្រជាជនដទៃទៀត"។ ខ្ញុំ -- តើនេះជាការសន្ទនាដែលលោកបានធ្វើជាមួយបុគ្គលនេះដែរឬទេ?

**ឆ៖** បាទ។

**ស៖** តើលោកអាចពណ៌នាបានដែរឬទេថា តើវាមានការចេញបទប្បញ្ញត្តិ ឬការកំណត់បទប្បញ្ញត្តិណាមួយដែលទាក់ទងទៅនឹងក្មេងៗ និងគិលានុបដ្ឋាយិកាដែលគេទុកចោលនោះដែរឬទេ?

**ឆ៖** តាមដែលខ្ញុំដឹងគឺអត់ទេ។ គឺថាគាត់ព្រួយបារម្ភយ៉ាងខ្លាំងអំពីអ្វីដែលអាចនឹងកើតឡើងចំពោះក្មេងៗ និងគ្រូពេទ្យទាំងអស់នោះ ព្រោះគាត់ធ្វើការនៅក្នុងអង្គការបរទេស។

**ស៖** សូមអរគុណ។ នៅពេលនេះខ្ញុំចូលទៅដល់ចំណុចមួយទៀតដែលខ្ញុំបានពិនិត្យកាលពីលើកមុននេះផងដែរ។ ចំណុចនេះគឺពាក់ព័ន្ធទៅនឹងអ្វីដែលលោកសង្កេតលើព័ត៌មានដែលលោកប្រមូលបានជាពិសេសព័ត៌មានអំពីការស្វែងរកមន្ត្រីរដ្ឋការ និងទាហានសម័យ លន់ នល់។ បរិបទដែលខ្ញុំសូមលើកឡើង គឺអ្វីដែលលោកបានលើកឡើងអំពីអារម្មណ៍នៅក្នុងក្រុង គឺត្រង់ទំព័រ៦៥, ERNជាភាសាអង់គ្លេសគឺ 00898273។ នៅត្រង់ផ្នែកនេះលោកបានរៀបរាប់ថាតើ អាឡាំង រ៉ុកអហ្វ បាននិយាយអ្វីខ្លះអំពីទាហាននៅខាងត្បូងនោះ បណ្ដើរអ្នកទោសជាង១០០នាក់ចេញទៅ។ ខាងក្រោមលោកសរសេរដូចតទៅ៖

"អារម្មណ៍នៅក្នុងទីក្រុង យើងអាចឃើញមានការផ្លាស់ប្តូរ ទាហានរដ្ឋាភិបាលដែលត្រូវបានចាប់ខ្លួនប៉ុន្មានម៉ោងមុននេះ កំពុងតែដោះសម្លៀកបំពាក់មានការភ័យខ្លាចណាស់នៅទូទាំងក្រុង"។

ខ្ញុំសូមសួរលោកឲ្យលោកជម្រាបជូនតុលាការថា តើលោកសន្និដ្ឋានចំណុចនេះដោយរបៀបណាថាពួកគាត់ហ្នឹងដោះអាវហ្នឹងដោយមានការភ័យខ្លាច?

[០៩:០៣:៥៧]

**ឆ៖** ព័ត៌មាននេះគឺខ្ញុំបានទទួលមកពីមន្ត្រីស្ថានទូតបារាំងមួយរូបដែលគាត់អាចធ្វើដំណើរពិនិត្យមើលនៅក្នុងក្រុង ដើម្បីពិនិត្យមើលរបស់របរនៅក្នុងផ្ទះរបស់គាត់ អាចយកមកបាន។ ហើយគឺអ្នកនោះបានទៅក្រោយមកប្រាប់ខ្ញុំថា គាត់បានឃើញអ្វីខ្លះ។ នេះហើយជាការរៀបរាប់ដែលគាត់ប្រាប់មកខ្ញុំ ជាពិសេសគឺការរៀបរាប់ពីមន្ត្រីទាំងនោះគឺមន្ត្រីស្ថានទូតគាត់ប្រាប់ខ្ញុំដូច្នេះ។

**ស៖** សូមអរគុណ។ លោកឆ្លើយកាលពីម្សិលមិញពាក់ព័ន្ធទៅនឹងមន្ត្រីជាន់ខ្ពស់របស់របបសាធារណរដ្ឋខ្មែរថា ខ្មែរក្រហមបានធ្វើសេចក្តីប្រកាសថានឹងសម្លាប់ពួកនុ៎ងចោល។ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ តើមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរណាដែលលោកបានលើកឡើងកាលពីម្សិលមិញនោះ?

**ឆ៖** ជាការពិត ខ្ញុំមិនបានដឹងថាតើមន្ត្រីនោះម្នាក់ៗសម្លាប់នៅពេលណានោះទេ។ អ្វីដែលខ្ញុំរាយការណ៍នៅពេលនោះ គឺមន្ត្រីស្ថានទូតបារាំងប្រាប់យើងថា នេះជាហេតុការណ៍ដែលបានកើតឡើងនៅពេលនោះ។ អ្វីដែលខ្ញុំចាំនោះគឺថា ឡុង បូរ៉េត ត្រូវបានគេសម្លាប់ចោល ហើយខ្ញុំកំពុងតែគិតផងដែរ គឺ សិរិមតៈ ក៏ត្រូវបានគេសម្លាប់ចោទផងដែរ។ ខ្ញុំមិនដឹងតើគេសម្លាប់នៅពេលណា ឬក៏មន្ត្រីប្រាំរូបទៀតនៅក្នុងបញ្ជីត្រូវសម្លាប់ចោលនោះ ត្រូវបានគេសម្លាប់ចោលនៅពេលណា ឬក៏សម្លាប់ មិនសម្លាប់នោះទេ។ នេះគឺជាព័ត៌មានដែលខ្ញុំទទួលបាន។ ហើយពួកគេធ្វើការដោះស្រាយបញ្ហានេះយ៉ាងលឿនណាស់ចំពោះខ្មែរក្រហមនោះ។

[០៩:០៦:២១]

**ស៖** សូមអរគុណ។ ត្រង់ទំព័រ៦៧នៃកំណត់ហេតុរបស់លោក អង់គ្លេស 00898275 យើងឃើញមានចំណុចចុចខ្មៅៗ ដែលពាក់ព័ន្ធនឹងម៉ោងបីល្ងាច គឺមានសរសេរដូចតទៅ។ ខ្ញុំគួរតែនិយាយថាព័ត៌មាននេះប្រហែលជាលោកទទួលមកពីអ្នកផ្សេង។ "នៅល្ងាចម៉ោងប្រហែលបី គឺក្នុងពេលដែលខ្ញុំឃើញគេចាប់ខ្លួននោះ ខ្មែរក្រហមធ្វើការបាញ់រ៉ុក្កែតជាមួយនឹងគ្រាប់កាំភ្លើងចូលមកអូតែលភ្នំ។ កន្លែង

ដែលគេស្រាវជ្រាវរកមន្ត្រីឃោធារបស់រដ្ឋាភិបាល។ ហើយបន្ទាប់មក គឺមានការវាយទៅលើរដ្ឋមន្ត្រី រដ្ឋការសម័យ លន់ នល់ នោះ”។ តើលោកទទួលព័ត៌មាននេះតាមរបៀបណា? ទទួលមកពីនរណាគេដែរ?

**ឆ៖** មានមនុស្សជនបរទេសដូចខ្ញុំដែរ គឺពួកគាត់នោះដើរចេញមកពីអូតែលនោះ សណ្ឋាគារនោះ ហើយខ្ញុំសួរពួកគាត់ថា “មានអ្វីកើតឡើង? ហេតុអ្វីបានជាពួកគាត់ដើរចេញមក?” ពួកគាត់ប្រាប់ខ្ញុំថា “គេប្រាប់ឲ្យចេញពីសណ្ឋាគារនេះ តែកន្លះម៉ោងចេញឲ្យអស់ ដើម្បីទៅស្ថានទូតបារាំង”។ ខ្ញុំសួរថា “នៅពេលណាដែរ?” ហើយមន្ត្រី ស្កេនដាវី អីនោះ – ជនជាតិ ស្កេនដាវី នោះ គឺថាប្រាប់ខ្ញុំថា “គេប្រាប់ ២៥នាទីមុននេះ ហើយខ្ញុំបានទៅប្រមូលយកម្ហូបកំប៉ុង ដើម្បីចាកចេញទៅស្ថានទូតបារាំង”។

**សៈ** ពាក់ព័ន្ធទៅនឹងការសង្កេតដែលលោកបានពិនិត្យឃើញថាដំបូងនោះ គឺយើងឃើញថាទាហានខ្មែរក្រហមនេះចូលទៅអូតែលនេះ ម៉ោងប្រហែលជាបីល្ងាចដើម្បីទៅរកមន្ត្រីរដ្ឋាភិបាល។ តើគេប្រាប់លោក ឬក៏យ៉ាងណាដែរ?

[០៩:០៨:៣៩]

**ឆ៖** អ្នកដែលនៅក្នុងហ្នឹង គឺថាគាត់ប្រាប់ខ្ញុំ នៅពេលដែលគាត់ដើរចេញមក ហើយអ្នកផ្សេងទៀតក្រោយមកក៏ប្រាប់ខ្ញុំផងដែរ។ ខ្ញុំមិនបានឃើញការស្រាវជ្រាវរបស់ខ្មែរក្រហមនោះដោយផ្ទាល់នោះទេ ក៏ប៉ុន្តែខ្ញុំគ្រាន់តែចូលទៅអូតែល សណ្ឋាគារនោះ ដើម្បីទៅយករបស់របររបស់ខ្ញុំចេញមកតែប៉ុណ្ណោះ។

**សៈ** សូមអរគុណ។ នៅពេលនោះ ខ្ញុំសូមសួរអំពីហេតុការណ៍នៅស្ថានទូតបារាំងដែលខ្ញុំបានលើកឡើងចំណុចនេះរួចមកហើយផងដែរ។ ជាការពិតកាលពីម្សិលមិញ លោកបានរៀបរាប់អំពីការប្រគល់ខ្លួន សិរិមតៈ គឺគាត់ប្រគល់ខ្លួននៅថ្ងៃទី២០ ខែមេសា។ នៅក្នុងពេលនោះ លោកក៏បានរៀបរាប់អំពីការរៀបចំដែលធ្វើបានឡើងក្នុងការបណ្តេញប្រជាពលរដ្ឋកម្ពុជាដែលនៅសល់ក្នុងស្ថានទូតបារាំង។ ហើយលោកបានរៀបរាប់នៅត្រង់ទំព័រ១០៨ ចាប់ផ្តើមពីទំព័រ១០៨មក គឺលោកបានរៀបរាប់អំពីការប្រគល់ខ្លួន។ គឺខ្ញុំសូមលើកឡើងថា ការប្រគល់ខ្លួនរបស់អ្នកដែលមិនមានលិខិតឯកសារច្បាស់លាស់នៅក្នុងស្ថានទូតក្រៅពី សិរិមតៈ។ ក្រោយមកគឺថាលោកបានបន្តរៀបរាប់អំពីរបៀបដែលគេហុចកូនក្មេងនោះទៅឲ្យគ្រួសារជនបរទេស។ ហើយថាតើការរៀបចំការរវាងជនបរទេ និងពលរដ្ឋកម្ពុជានៅពេលនោះ គឺធ្វើឡើងយ៉ាងម៉េចដើម្បីជួយឲ្យជនពលរដ្ឋកម្ពុជាហ្នឹងអាចស្នាក់នៅស្ថានទូតនោះបាន។ ខ្ញុំមានពេលវេលាតែខ្លីប៉ុណ្ណោះ។ ដូច្នេះខ្ញុំសូមឲ្យលោករៀបរាប់ជូនតុលាការទាក់ទងទៅនឹងហេតុការណ៍នេះ?

[០៩:១០:៣០]

**ឆ៖** លោក ឌីវ៉ាក់ ដែលគឺជាមន្ត្រីនាំមុខនាពេលនោះ មន្ត្រីនាំមុខនៅក្នុងស្ថានទូតបារាំង គឺគាត់បានរៀបចំជាពិធីអាពាហ៍ពិពាហ៍ដូចដែលលោកបានរៀបរាប់។ ធ្វើដូច្នេះដើម្បីជួយដល់អ្នកដែលត្រូវគេបង្ខំឲ្យចេញទៅក្រៅស្ថានទូត។ នៅពេលដែលខ្ញុំខ្មែរក្រហមគាត់បានដឹងអំពីបញ្ហាហ្នឹង មិនដឹងថាដឹងតាមរបៀបណាទេ ប្រហែលជាតាមការទាក់ទងតាមវិទ្យុ ឬក៏យ៉ាងណានោះ ខ្ញុំគិតថាអ៊ីចឹង។ ខ្មែរក្រហមនោះបានប្រាប់ទៅ ឌីវ៉ាក់ ថាឈប់ធ្វើរបៀបហ្នឹង។ ហើយលោក ឌីវ៉ាក់ នោះធ្វើជាអ្នកមេបានៅក្នុងពិធីអាពាហ៍ពិពាហ៍ដើម្បីកុំឲ្យយកពលរដ្ឋកម្ពុជាចេញពីស្ថានទូតបាន។ ក៏ប៉ុន្តែខ្មែរក្រហមប្រាប់ថាឲ្យឈប់ភ្លាម បើសិនមិនឈប់ទេ មន្ត្រីនិងបុគ្គលិករបស់ ឌីវ៉ាក់ នោះក៏ត្រូវទទួលទណ្ឌកម្មពិន័យដូចគ្នា។ ក៏ប៉ុន្តែ ឌីវ៉ាក់ ពេលនោះក្លាហានណាស់ ហើយគឺគាត់ជួយទៅតាមលទ្ធភាពដែលគាត់អាចជួយទៅបាន។

[០៩:១១:៥០]

**ស៖** តើលោកអាចរៀបរាប់អ្វីដែលលោកបានឃើញ និងសង្កេតពាក់ព័ន្ធទៅនឹងស្ថានភាពរបស់គ្រួសារទាំងអស់នោះ ជាពិសេសស្ថានភាពគ្រួសារដែលត្រូវបានគេបង្ខំឲ្យចាកចេញពីស្ថានទូតនោះ?

**ឆ៖** គ្រួសារមួយគ្រួសារនោះ គឺមានស្វាមីធ្វើការងារនៅសារទូរលេខ ហើយគឺថាគាត់ និងភរិយារបស់គាត់នេះ។ ភរិយាទើបតែកើតកូនលើកដំបូង ហើយគឺគាត់បានឆ្លងកាត់ស្ថានភាពលំបាកលំបិននេះ គឺបានន័យថាឆ្លងកាត់ស្ថានភាពសង្គ្រាម និងការកាប់សម្លាប់នាពេលនោះ គឺបុរសរូបនោះបានដើរមករកខ្ញុំ ហើយសួរថា “តើខ្ញុំអាចដាក់លុយកក់មួយឲ្យខ្ញុំនេះជាអ្នកគ្រប់គ្រងទៅលើគណនីរបស់គាត់បានដែរឬទេនាពេលនោះ?” ក្រោយមកនៅពេលដែលគាត់ និងភរិយារបស់គាត់ត្រូវបានបណ្ដើរចេញពីស្ថានទូតនាពេលនោះ ខ្ញុំនៅក្នុងចំណោមហ្នឹង ហើយខ្ញុំឃើញបុរសហ្នឹង និងភរិយារួមទាំងកូនរបស់គាត់។ ស្ត្រីភរិយានោះសួរខ្ញុំថា “អាចយកកូនខ្ញុំ -- គាត់ទៅដើម្បីឲ្យខ្ញុំនេះជាអ្នកថែទាំកូនគាត់ផង”។ បន្ទាប់មកពួកគាត់ទាំងពីរបានចេញទៅ។ ខ្ញុំគិតថា ខ្ញុំមិនអាចចេញទៅក្រៅបាននោះទេ ហើយមិនដឹងថាតើមានអ្វីកើតឡើងនោះទេ។ ដូច្នេះសូមឲ្យលោកស្រី និងលោកនោះមើលកូននោះខ្លួនឯងទៅ ខ្ញុំមិនបានអាចធ្វើទៅបានទេ។ ក៏ប៉ុន្តែនារីបារាំងដែលនៅក្នុងនោះផងដែរនោះ គាត់បានស្ដាប់ឮ ហើយខ្ញុំឃើញថាគឺគេរកគ្រួសារ មួយគ្រួសារហ្នឹងឃើញ។ ហើយបន្ទាប់មកគឺថាគ្រួសារទាំងពីរហ្នឹង ប្ដីប្រពន្ធហ្នឹងបានហុចកូនឲ្យស្ត្រីបារាំងរូបនោះ។

[០៩:១៤:១១]

ហើយខ្ញុំក៏បានប្រគល់លុយដែលបុរស និងស្ត្រីនោះកក់ថាឲ្យខ្ញុំជាអ្នកកាន់កាប់ទៅឲ្យស្ត្រីបារាំងនោះមើលថែទាំកុមារ។

**ស៖** សូមអរគុណចំពោះការរៀបរាប់របស់លោក។ យើងឃើញថានៅពេលដែលប្រជាពលរដ្ឋរាប់រយនាក់ត្រូវបានគេបណ្តើរដឹកចេញទៅក្រៅស្ថានទូត ត្រង់ទំព័រ៨៧ ដល់៨៨នៃកំណត់ហេតុរបស់លោក ត្រង់ ERN ជាភាសាអង់គ្លេសគឺ 00898295 និងទំព័រក្រោយៗទៅទៀតនោះ។ លោកបានរៀបរាប់អំពីការចូលលុកលុយរបស់ខ្មែរក្រហមនៅក្នុងងទីតាំងស្ថានទូត។ ហើយខ្ញុំនឹងអានចំណុចនេះជូនលោកស្តាប់ "ពីរបីនាទីក្រោយមក ខ្មែរក្រហមបីនាក់សម្លៀកបំពាក់ខ្មៅជាមួយនឹងកាំភ្លើងខ្លី និងសៀវ-ភៅបានចូលមកក្នុងស្ថានទូត។ មន្ត្រីកុងស៊ុល ឌីវ៉ាក់ សួរពួកគេ ហើយគាត់បានដើរជាមួយខ្មែរក្រហមដោយទឹកមុខនៅស្ងៀម។ នៅពេលនោះខ្មែរក្រហមសួរធ្វើកំណត់ហេតុហើយពិភាក្សាគ្នា។ ពលរដ្ឋកម្ពុជាមួយចំនួនបន្ទាប់មកចេញមកពីកន្លែងរោងជាងមួយគឺនៅមន្ទីរពេទ្យកាល់ម៉ែត ហើយពេលនោះគឺថាមានការចៀសវាងកុំឲ្យមានស្ថានភាពនោះកើតឡើង។ ពួកគេអំពាវនាវក៏ប៉ុន្តែជនកុម្មុយនីស្ត គឺមិនខ្វល់ទេ ហើយបានរុញច្រានអ្នកទាំងអស់នោះចេញពីស្ថានទូត។ តើលោកឃើញខ្មែរក្រហមចូលមកស្ថានទូតដើម្បីស្វែងរកអ្នកដែលនៅសល់ដែរឬទេ?

**ឆ៖** បាទ ខ្ញុំឃើញ។ នេះជាហេតុការណ៍ដែលខ្ញុំបានឃើញ។

[០៩:១៦:០០]

**ស៖** សូមអរគុណ។ នៅក្នុងសៀវភៅវាលពិឃាតឯកសារ E243.2 ត្រង់ទំព័រ៧០ ទៅដល់ ៧១ យើងឃើញមានរូបថតមួយសន្លឹក។ ខ្ញុំចង់បង្ហាញជូនលោកដើម្បីឲ្យលោកពិនិត្យមើលថាតើនេះជារូបភាពឆ្លុះបញ្ចាំងអំពីស្ថានភាពនៅស្ថានទូត ឬក៏យ៉ាងណា?

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធានសុំការអនុញ្ញាត យើងខ្ញុំសូមបញ្ចាំងរូបថតនេះនៅលើអេក្រង់។ ERN ពាក់ព័ន្ធគឺ 00862602។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ខ្ញុំសូមលើកឡើងថា រូបថតនេះគឺផ្តល់ជូនយើង រ៉ុកូហ្វ។ សូមឲ្យ លោកពិនិត្យមើលថាតើកន្លែងនេះលោកស្គាល់ដែរឬទេ?

**លោក ស៊ីដនី ស្កេនប៊ឺក៖**

**ឆ៖** រូថតនេះខ្ញុំក៏មានដែរមួយសន្លឹកគឺខ្មៅជាងនេះ។ ខ្ញុំមើលអេក្រង់ទៅសូមអធ្យាស្រ័យដែលខ្ញុំឃើញរាងខ្មៅ។ បាទ គឺចំពោះខ្ញុំដូចជាអត់ចាំទេ មិនដឹងកន្លែងណានោះទេ។

[០៩:១៧:២០]

**ស៖** ខ្ញុំបន្តទៅមុខទៀត។

**ឆ៖** នៅអក្សរខាងក្រោមប្រហែលជាអាចបញ្ជាក់បាន។

**ស៖** ខ្ញុំសូមបន្តទៅមុខទៀតដើម្បីសន្សំពេលវេលា។ មិនមានសរសេរអក្សរនៅពីក្រោមនោះទេ ក៏ប៉ុន្តែវាដឹងថាជាទីតាំងស្ថិតនៅក្នុងស្ថានទូត។ យើងខ្ញុំសូមបន្តសួរលោកទៅមុខទៀត។

ខ្ញុំនៅពេលនេះសូមសួរសំណួរបីបួនទៀតពាក់ព័ន្ធទៅនឹងដំណើររបស់លោក ធ្វើដំណើរទៅកាន់ប្រទេសថៃដែលលោកបានរៀបរាប់កាលពីម្សិលមិញ។ ជាដំបូងខ្ញុំសូមសួរលោកឲ្យរៀបរាប់ជូនតុលាការប្រសិនបើលោកនៅនឹកឃើញ ថាតើពលរដ្ឋកម្ពុជាមួយចំនួននោះអាចឡើងគេចខ្លួនតាមរថយន្តជាមួយលោកហ្នឹងដោយរបៀបណាទៅ គឺនៅថ្ងៃ៣០ ខែមេសា?

**ឆ៖** តើលោកសួរខ្ញុំសំណួរណាមួយដែរ?

[០៩:១៨:៥០]

**ស៖** គឺពាក់ព័ន្ធទៅនឹងការឡើងឡាននៅថ្ងៃ នៅព្រឹកថ្ងៃទី៣០ ខែមេសា។ នៅពេលនោះគឺមានការជួយ ប្រមូលលួចលាក់ពលរដ្ឋកម្ពុជាបីនាក់គឺជាស្ត្រីគឺបានន័យថាស្ត្រីបីនាក់នោះបានត្រូវបានជួយលាក់ខ្លួននៅក្នុងក្បួនរថយន្តជាមួយលោកចេញទៅគឺមានស្ត្រីបីនាក់។ ខ្ញុំសូមឲ្យលោករៀបរាប់។

**ឆ៖** ខ្ញុំព្យាយាមនឹកសិន។ ឈ្មោះបុរសម្នាក់នោះគឺឈ្មោះ ប៊ីហ្សូ។ ខ្ញុំមិនចាំឈ្មោះរបស់គាត់ទេ។

**ស៖** គឺមិនជាថ្វីអ្វីទេលោក ស្កេនប៊ឺក លោកអាចរៀបរាប់ទៅ។ គឺយើងឃើញថា ម៉ោងប្រាំព្រឹកគឺម៉ោងប្រាំព្រឹកវានៅងងឹតមានការដឹកឡើងឲ្យមនុស្សឡើងជិះឡានគឺ ប៊ីហ្សូ គឺគាត់ជួយឲ្យពលរដ្ឋ

កម្ពុជានោះគឺឡើងឡាននោះបាន ទោះបីឈ្មោះនោះមិនមានក្នុងបញ្ជីក៏ដោយ។ បន្ទាប់មក ប៊ីហ្ស៊ូ បានទៅជួបជាមួយនឹងទាហាន គឺទាហានកុម្មុយនីស្ត ហើយពួកគេនោះនិយាយថាច្រើនពេក ឲ្យទាញមនុស្សចុះសិន ហើយឡើងសាថ្មី។ នៅពេលនោះ គឺថាគាត់រៀបចំដោយជំនាញ ប៊ីហ្ស៊ូ គឺជួយរៀបចំដោយជំនាញ គឺគាត់បានជួយមនុស្សបីនាក់ដោយ ទោះបីជាពួកគេគ្មានការអនុញ្ញាតក៏ដោយ។

មួយ គឺជនជាតិអាមេរិក ហើយមួយទៀត គឺស្ត្រីកម្ពុជា ពីរនាក់ គឺម្នាក់មានម្នាក់រៀបការជាមួយនឹងបុរសបរទេស។ ហើយឃើញមានស្ត្រីម្នាក់ ជាមួយនិងកូនស្រី អាចរត់រួចផងដែរ។ ពួកគាត់ហ្នឹង គឺថាមិនមានឈ្មោះនៅក្នុងបញ្ជីនោះទេ។

**ស៖** សូមអរគុណ--

**ឆ៖** ខ្ញុំមិនដឹងមិនដឹងថាតើ ប៊ីហ្ស៊ូ ធ្វើអ៊ីចឹងនៅពេលដែលប្រជាជនឡើងឡានជាច្រើនក្រោយមកទៀតនោះទេ ក៏ប៉ុន្តែយើងរីករាយណាស់នៅពេលដែលឃើញប្រជាពលរដ្ឋអាចឡើងជិះឡានជាមួយយើង។

[០៩:២១:៣០]

**ស៖** សូមអរគុណ។ នៅពេលនេះ ខ្ញុំសល់ពេលតែបន្តិចតែប៉ុណ្ណោះ។ ដូច្នេះប្រសិនបើខ្ញុំសូមឲ្យលោករៀបរាប់ដោយសង្ខេប ប្រសិនបើលោកអាចធ្វើទៅបាន យើងមើលការរៀបរាប់របស់លោកតាមអ្វីដែលលោកឃើញក្នុងពេលដែលលោកធ្វើដំណើរពីភ្នំពេញទៅកាន់ព្រំដែនថៃ។ ខ្ញុំនឹងធ្វើឲ្យអានជូនលោកនៅអត្ថបទជាក់លាក់ឲ្យលោកឆ្លើយ។

ដំបូងត្រង់ទំព័រ១០៩, អង់គ្លេស ERN00898317, លោកបានរៀបរាប់អំពីការធ្វើដំណើរនាពេលនោះ ជាពិសេសការធ្វើដំណើរតាមផ្លូវមុនីវង្ស លោកបានរៀបរាប់ដូចតទៅ៖ “នៅពេលដែលយើងធ្វើដំណើរតាមផ្លូវមុនីវង្សនោះ គឺថាយើងឃើញផ្លូវទីក្រុងគួរឲ្យខ្លាច។ ភ្លើងតាមផ្លូវបើក ហើយឃើញមានពន្លឺស្ទង់ៗ ឃើញមានក្រដាសរប៉ាត់រប៉ាយ និងឡានដែលគេបោះបង់ចោល។ ឃើញឆ្កែ ឆ្មា ដើរកាត់ពាសពេញតាមផ្លូវ។ យើងមិនឃើញមានប្រជាជន គ្មានជនស៊ីវិល មានតែខ្មែរក្រហមតែប៉ុណ្ណោះ។ អ្នកខ្លះដើរតាមចិញ្ចើមផ្លូវ អ្នកខ្លះនៅក្នុងហាង។ ហើយពេលខ្លះគេឃើញមានឆក់លួចក្នុង -- ឆក់លួចប្លន់ក្នុងហាងផងដែរ”។ ដូច្នេះគឺ តើហេតុការណ៍ដែលលោកបានឃើញ នៅពេលដែលលោកធ្វើដំណើរតាមមុនីវង្សនោះ គឺថាឃើញមានការឆក់ប្លន់ក្នុងហាងផងដែរឬម៉េច?

**ឆ៖** បាទ ខ្ញុំឃើញដូច្នោះផងដែរ គឺឃើញមានការឆក់ប្លន់នៅក្នុងហាង។

[០៩:២៣:២៧]

**ស៖** សូមអរគុណនៅពេលនេះ ខ្ញុំសូមចូលទៅដល់ចំណុចមួយទៀតដែលពាក់ព័ន្ធទៅនឹងដំណើររបស់លោក ការធ្វើដំណើររបស់លោកទៅព្រំដែនថៃ។ អង់គ្លេស ERN គឺ 00898322 ត្រង់ទំព័រ១១៤ ដល់១១៥។ នៅក្នុងពេលនោះ គឺថាលោកបានទៅដល់ជិតភូមិល្វា ក្នុងខេត្តកំពង់ឆ្នាំង ហើយលោកនៅពេលនោះអាចមើលឃើញប្រជាជនខ្លះដែរ លោកបានរៀបរាប់ដូចតទៅ៖

“មនុស្សមួយចំនួននៅក្នុងក្បួនរថយន្តនោះនិយាយភាសាខ្មែរអាចនិយាយជាមួយអ្នកស្រុកបាន។ វៀតណាមចំណាយពេល២៥ឆ្នាំ ដើម្បីរំដោះប្រទេស។ ខ្មែរក្រហមចំណាយពេលតែ ៥ឆ្នាំតែប៉ុណ្ណោះរំដោះប្រទេស។ មន្ត្រីមួយទៀតនិយាយអំពីឋានៈនៅក្នុង -- ឋានន្តរស័ក្តិរបស់ទាហានដែលចំណាយពេល៣ឆ្នាំ ត្រូវធ្វើការនៅក្នុងស្រែ”។ តើនេះគឺជាកិច្ចសន្ទនាដែលលោកបានស្តាប់ដោយផ្ទាល់ បានឃើញដោយផ្ទាល់នៅពេលដែល -- នៅពេលនោះ គឺថាមានទាហានខ្មែរក្រហមនិយាយជាមួយនិងអ្នកជិះឡានជាមួយលោកជាភាសាខ្មែរ ឬយ៉ាងម៉េច?

**ឆ៖** គឺថាអ្នកនៅលើក្បួនរថយន្តនោះបានប្រាប់ខ្ញុំដូច្នេះ។ គាត់និយាយភាសាខ្មែរបាន ហើយទៅនិយាយជាមួយនឹងទាហានខ្មែរក្រហមនាពេលនោះ។ យើងឃើញថាមានមនុស្សពីរបីនាក់ត្រឡប់មកប្រាប់ខ្ញុំអំពីហេតុការណ៍ហ្នឹង។

[០៩:២៥:១០]

**ស៖** សូមអរគុណ។ នៅក្រោមហ្នឹងបន្តិច លោកនិយាយអំពីជនភៀសខ្លួនចេញទៅ បានគេជំរុញចេញទៅពីខេត្តកំពង់ឆ្នាំង។ អ្នកជនភៀសខ្លួនមួយចំនួនត្រូវបានគេបណ្តេញចេញពីខេត្តកំពង់ឆ្នាំង ហើយកំពុងតែរស់នៅតាមភូមិ។ ឃើញមួយនោះជាវេជ្ជបណ្ឌិតឈ្មោះ ដំ ចាន ដែលប្រាប់ខ្ញុំអំពីខ្មែរក្រហមរំដោះកំពង់ឆ្នាំងនៅថ្ងៃ១៨ ខែមេសា។ គាត់បាននិយាយថា “មន្ទីរពេទ្យត្រូវបានគេបណ្តេញ អ្នកជំងឺត្រូវបានគេបណ្តេញចេញពីមន្ទីរដូចនៅក្នុងទីក្រុងភ្នំពេញផងដែរ។ យើងគ្មានពេលវេលារៀបចំរបស់របរនោះទេ។ ខ្ញុំគ្រាន់តែបានទៅជាមួយនឹងកូនរបស់ខ្ញុំបីនាក់ និងភរិយារបស់ខ្ញុំ ម្តាយរបស់ខ្ញុំ”។

វេជ្ជបណ្ឌិតបាននិយាយថា “ខ្មែរក្រហមហាក់ដូចជាធ្វើបាបបុគ្គលិកពេទ្យ ហើយពួកគេមិនឲ្យឈប់នោះទេ ដេញយើងចេញតែម្តង។ យើងមិនដឹងថាយើងកំពុងធ្វើដំណើរទៅតាម ទៅណានោះឡើយ។ ពេលនោះមន្ត្រីខ្មែរក្រហមបានឃើញយើង ហើយចាប់ផ្តើមសួរវេជ្ជបណ្ឌិតរូបនោះ។ មុខរបស់គាត់មានការភ័យខ្លាច គាត់មើលចុះទៅក្រោមដី ហើយគាត់ព្យាយាមទៅកាន់គ្រួសាររបស់គាត់។ មន្ត្រីនោះបានងាកមកខ្ញុំមើលក្នុងកំណត់ហេតុ ហើយសួរខ្ញុំថា តើខ្ញុំកំពុងតែនិយាយជាអ្វីជាមួយនឹងគ្រូពេទ្យនោះ?” ខ្ញុំ

អាចសុំសួរលោកបានដែរឬទេ តើនៅពេលដែលលោកនិយាយជាមួយលោកវេជ្ជបណ្ឌិតនោះ មួយក្រុមរបស់លោកវេជ្ជបណ្ឌិតហ្នឹង គឺមានប៉ុន្មាននាក់ដែរ នៅពេលដែលចេញពីកំពង់ឆ្នាំង?

**ឆ៖** មិនមែនជាក្រុម ក្រុមហ្នឹងមិនមានមនុស្សច្រើននាក់នោះទេ វេជ្ជបណ្ឌិតរូបហ្នឹងគឺចេញមកពីព្រៃ គុម្ពោតព្រៃហើយនិយាយជាមួយនឹងយើង។ គាត់ប្រាប់ គាត់ចង់ប្រាប់អំពីស្ថានភាពដែលគាត់ និងគ្រួសាររបស់គាត់ និងអ្នកផ្សេងបានជួបប្រទះ។ គាត់បានប្រាប់ខ្ញុំ ខ្ញុំទាញកំណត់ហេតុមកយកមកកត់ត្រា ហើយនេះជាអ្វីដែលគាត់បានប្រាប់ខ្ញុំ។

**ស៖** សូមអរគុណ។ នៅប៉ុន្មានបន្ទាត់ខាងក្រោមនេះគឺ លោក ឡេង -- បាទ នៅពេលនោះលោកធ្វើលេស ហើយបន្ទាប់មកលោកខ្មែរក្រហមសុំបារីមួយដើមពីលោក។ តើលោកមានន័យយ៉ាងម៉េចដែរ?

[០៩:២៧:៤៦]

**ឆ៖** ខ្ញុំគិតថានៅពេលនោះ ខ្មែរក្រហមគិតថាខ្ញុំប្រើប្រាស់ព័ត៌មាននេះដើម្បី -- សម្រាប់ផ្ទាល់ខ្លួនដែលខ្មែរក្រហមជំទាស់ ហើយនៅពេលនោះ ខ្ញុំលេងល្បិច ហើយខ្ញុំគ្រាន់តែថាខ្ញុំជាអ្នកដែលដឹកនាំភ្ញៀវទេសចរមកពីប្រទេសកាណាដា។

**ស៖** ដោយសារពេលវេលា ខ្ញុំសូមសួរអំពីទីរួមខេត្ត និងក្រុងដែលលោកបានឃើញ ហើយលោកសូមជួយបញ្ជាក់ថា តើនេះជាព័ត៌មានរបស់លោកឃើញដោយផ្ទាល់ ឬក៏យ៉ាងម៉េច? ទី១ គឺ ដំបូងគឺសួរអំពីក្រគរ និងកំពង់ឆ្នាំង បន្ទាប់មកសួរអំពីពោធិ៍សាត់ ដែលត្រូវបានគេជម្លៀសដូចគ្នា។ តើលោកបានឆ្លងកាត់ទីក្រុង ទីរួមទាំងអស់នេះឬយ៉ាងណាដែរ? នៅពេលនោះគឺថាលោកឃើញមានការបណ្តេញប្រជាជនចេញដែរឬទេ?

**ឆ៖** គឺខ្ញុំមកឃើញអ៊ីចឹង ហើយអ្នកដែលនៅក្បួន ក្នុងក្បួនឡានក៏ឃើញដូចខ្ញុំផងដែរ។

[០៩:២៨:៤៨]

**ស៖** លោកបានរៀបរាប់ ហើយលោកបាននិយាយអំពីបាត់ដំបងផងដែរ រួមទាំងប៉ោយប៉ែត។ តើលោកបានឆ្លងកាត់បាត់ដំបង និងប៉ោយប៉ែតដែរឬទេ ហើយអាចឃើញស្ថានភាពយ៉ាងម៉េចដែរនាពេលនោះ?

**ឆ៖** បាទ ខ្ញុំឃើញជារឿយៗឃើញសត្វពាហនៈ និងគោ ក្របីនៅក្នុងស្រែ មិនឃើញមនុស្សនោះទេ។ យើងឆ្លងកាត់ទីរួមខេត្តទាំងអស់នោះ។

**ស៖** សូមអរគុណ។ នៅពេលដែលលោកឆ្លងកាត់ពោធិ៍សាត់ត្រង់ទំព័រ១២០, អង់គ្លេស ERN 00898328 ត្រង់ម៉ោង១:៤០នាទី លោកបាននិយាយដូចតទៅ៖ "នៅក្នុងខេត្តពោធិ៍សាត់ស្ថានភាពនោះគឺដូចទីរួមខេត្តដទៃ គ្មានជនស៊ីវិល គ្មានទាហាន។ ផ្ទះត្រូវបានឆក់ប្លន់ ហើយយើងឃើញមានរបស់របរនៅរប៉ាត់រប៉ាយ។ នៅលើតុនោះមានឃើញម្ហូបអាហារនោះមិនទាន់ឆ្អិននោះទេ ក៏ឲ្យប្រជាជនត្រូវតែចាកចេញដោយប្រញាប់"។ តើនេះគឺជាអ្វីដែលលោកបានឃើញដែរឬទេ?

[០៩:៣០:០៤]

**ឆ៖** ពេលខ្លះយើងអាចចុះពីលើឡានបាន ដូច្នេះយើង ខ្ញុំបានឃើញមែន។ នេះគឺជាអ្វីដែលខ្ញុំបានឃើញ។

**ស៖** នេះសំណួរចុងក្រោយរបស់ខ្ញុំ នៅតាមផ្លូវលោកឃើញទីក្រុងគ្មានមនុស្សនៅ ហើយលោកអាចមើលឃើញនៅពេលដែលលោកធ្វើដំណើរ។ តើលោកបានឃើញ ថាតើប្រជាពលរដ្ឋទាំងអស់នោះទៅណាអស់ទៅ? ស្ថិតនៅតាមចញ្ចើមផ្លូវ នៅជិតទីរួមខេត្តនោះ ឬទៅណា? តើលោកអាចឃើញទេ?

**ឆ៖** អត់បានឃើញទេ។ មិនមានសញ្ញាបញ្ជាក់ណាមួយ ថាតើគេយកអ្នកទាំងអស់នោះទៅណានោះទេ។

[០៩:៣០:៤៩]

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះការអត់ធ្មត់របស់លោកក្នុងការឆ្លើយសំណួររបស់ខ្ញុំក្នុងរាត្រីដែលលោកកំពុងតែនៅនេះ។ ហើយខ្ញុំសូមអរគុណណាស់ព័ត៌មានទាំងឡាយដែលលោកផ្តល់ជូនខ្ញុំនេះមានសារប្រយោជន៍ដល់យើងខ្ញុំ និងដល់តុលាការ។ ដូច្នេះនៅពេលនេះ ខ្ញុំសូមអនុញ្ញាតពីអង្គជំនុំជម្រះផ្តល់វេទិកានេះបន្តទៅឲ្យខាងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមអរគុណអង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ។

អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ គឺខ្ញុំ ពេជ អង្គ ហើយនិងលោកស្រី

គ្រីស្ទីន ម៉ាទីណូ ជាអ្នកលើកសំណួរសម្រាប់សាក្សីរូបនេះ ពីខាងដើមបណ្តឹងរដ្ឋប្បវេណី។ យើងខ្ញុំមាន សំណួរបន្តិចបន្តួចទេ សម្រាប់លោកសាក្សី។

[០៩:៣១:៥៤]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** ជម្រាបសួរលោកសាក្សី។ សំណួររបស់ខ្ញុំៗចង់សួរថា បន្ទាប់ពីពេលដែលអាមេរិកឈប់ ទម្លាក់គ្រាប់បែកនៅកម្ពុជាដែលលោកបាននិយាយថា ខែ៦ ឬខែ៧ ឆ្នាំ១៩៧៣។ ថាតើមានទាហាន អាមេរិកណាចូលរួមជាមួយទាហាន លន់ នល់ នៅក្នុងការវាយតបតជាមួយទាហានខ្មែរក្រហមដែរឬ ទេ? តើលោកអាចដឹងពីរឿងហ្នឹងដែរឬទេ?

**លោក ស៊ីដនី ស្តេនប៊ឺក៖**

**ឆ៖** តាមដែលខ្ញុំដឹង ពួកគេផ្តល់យោបល់ចំពោះមេដឹកនាំផ្នែកកម្ពុជា ដោយការផ្តល់យោបល់ ហ្នឹងថាឲ្យបន្តទៅមុខ ប៉ុន្តែពួកគេមិនបានចូលរួមដោយផ្ទាល់នៅក្នុងការវាយប្រយុទ្ធនោះទេ។ គឺថាគេ មិនបានចូលរួមអ្វីក្រៅពីទម្លាក់គ្រាប់បែកនោះទេ។

[០៩:៣៣:១១]

**ស៖** ពួកគេនេះ ថាតើលោកសំដៅទៅអ្នកណា?

**ឆ៖** សូមអភ័យទោស ខ្ញុំអត់យល់សំណួររបស់លោកទេ។

**ស៖** លោកបាននិយាយថា ពួកគេបានផ្តល់យោបល់ឲ្យបន្តនៅក្នុងការវាយប្រយុទ្ធ។ តើលោក អាចបញ្ជាក់បានទេ ពួកគេនេះ តើពួកគេនេះជាអ្នកណា?

**ឆ៖** ខ្ញុំនិយាយសំដៅទៅលើពួកយោធានៅក្នុងស្ថានទូត គឺនៅក្នុងស្ថានទូតអាមេរិក។ គឺពួក អាមេរិកដែលពិភាក្សាជាមួយយោធាកម្ពុជា ដោយពួកអាមេរិក គេផ្តល់យោបល់ដល់កម្ពុជាថាឲ្យបន្តទៅ មុខទៀត។ ខ្ញុំដឹងតែប៉ុណ្ណេះទេ ព្រោះថាខ្ញុំមិនអាចចូលរួមនៅក្នុងការពិភាក្សា ខ្ញុំមិនអាចស្តាប់ឮការ ពិភាក្សានោះទេ ប៉ុន្តែខ្ញុំដឹងថា អ្វីដែលគេធ្វើគឺបែបនេះ។ ដូច្នេះ ខ្ញុំប្រាប់លោកបានត្រឹមតែប៉ុណ្ណេះទេ។

**ស៖** តើយោបល់នេះ មានបានលេចចេញមកខាងក្រៅ។ ចង់និយាយថា នៅក្នុងស្រទាប់ មេដឹកនាំ -- ត្រូវបានលេចចេញជាសាធារណៈ ឬក៏ត្រូវបានសរសេរនៅក្នុងកាសែតណាមួយដែរឬទេ?

[០៩:៣៥:០៧]

**ឆ៖** អត់ទេ។

**ស៖** ជាសំណួរចុងក្រោយរបស់ខ្ញុំ ហើយបន្ទាប់មកខ្ញុំសូមឲ្យផ្ទេរវេទិកានេះជូនទៅសហការីរបស់ខ្ញុំ។ បន្ទាប់ពីពេលបញ្ឈប់ លែងមានកាទម្លាក់គ្រាប់បែកពីខែមិថុនា ឬខែកក្កដា ឆ្នាំ១៩៧៣ តើមានបរិយាកាសដែលមានបរិយាកាសព្រួយបារម្ភថានឹងអាចមានការទម្លាក់គ្រប់បែកកើតឡើងបន្ទាប់ពីពេលដែលឈប់នោះ បន្តមកទៀតដែរឬទេ?

**ឆ៖** អត់ទេ តាមដែលខ្ញុំដឹងគឺអត់ទេ។ ព្រោះថាសមាជ ឬក៏សភានៅសហរដ្ឋអាមេរិកនៅទីក្រុងវ៉ាស៊ីនតោននោះ គឺបានបញ្ឈប់ការផ្តល់ជំនួយមកប្រទេសកម្ពុជារួចទៅហើយ។ ដូច្នេះគឺវាច្បាស់ណាស់ថា អាមេរិកគឺសុខចិត្តចុះចាញ់ខ្មែរក្រហម។

**លោក ពេជ អង្គ៖**

បាទសូមគោរពលោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអនុញ្ញាតផ្ទេរវេទិកាជូនសហការីរបស់ខ្ញុំ។ សូមអរគុណលោកប្រធាន។

[០៩:៣៦:៤៦]

**ប្រធានអង្គជំនុំ៖**

បាទសូមអញ្ជើញ!

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

ជម្រាបសួរលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។

**សួរដោយលោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

**ស៖** ជម្រាបសួរលោក ស៊ីដនី ស្កេនប៊ឹក។ ខ្ញុំអត់ឃើញលោកទេ ប៉ុន្តែខ្ញុំដឹងថាលោកកំពុងតែនៅទីនេះហើយ។ សហព្រះរាជអាជ្ញាបានសួរសំណួរជាច្រើនទៅកាន់លោក។ ដូច្នេះខ្ញុំចង់ត្រឡប់មកសួរអំពីចំណុចមួយចំនួន។ ជាដំបូង ខ្ញុំមានសំណួរសំខាន់មួយ ខ្ញុំកត់សម្គាល់ថាលោកមកដល់គឺនៅឆ្នាំ៧០ នៅប្រទេសកម្ពុជា។ បន្ទាប់មកយើងដឹងថា លោកត្រឡប់ទៅវិញ។ ដូច្នេះលោកនៅទីនេះ គឺថាដើម្បីផ្តល់សក្ខីកម្មយើងពីខែមករា ឆ្នាំ៧៥ រហូតទៅដល់ខែឧសភា ឆ្នាំ៧៥។ អ៊ីចឹងខ្ញុំចង់ដឹងថា តើនៅក្នុងចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ហ្នឹង លោកមានបានមកស្នាក់នៅកម្ពុជាដែរឬទេ?

[០៩:៣៧:៥៥]

**លោក ស៊ីដនី ស្កេនប៊ឺក៖**

**ឆ៖** ខ្ញុំមកកម្ពុជាច្រើនដង ហើយខ្ញុំស្នាក់នៅរយៈពេលយូរពេលខ្លះ។

**ស៖** នៅពេលដែលលោកមកស្នាក់នៅកម្ពុជា គឺចន្លោះពីខែមករា រហូតទៅដល់ខែឧសភា ឆ្នាំ ៧៥ គឺលោកមកធ្វើការដើម្បីកាសែតរបស់លោក គឺញូវយ៉កថាមស៍។ តើលោកមានទទួលបានព័ត៌មានពាក់ព័ន្ធទៅនឹងអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាដែរឬទេ? គឺមានន័យថា តើរដ្ឋាភិបាល លន់ នល់ កំពុងធ្វើអ្វីខ្លះ? តើមានអ្វីខ្លះដែលកើតឡើងនៅទូទាំងប្រទេស ហើយនិងការឈានមុខរបស់ខ្មែរក្រហមដែលបានរំដោះប្រទេសបានមួយភាគធំហើយនោះ?

**ឆ៖** គឺមានកន្លែងជាច្រើនដែលយើងអាចទទួលបានព័ត៌មាន។ ស្ថានទូតអាមេរិកពេលខ្លះឆ្លើយសំណួរអំពីការរុលចូលរបស់ពួកខ្មែរក្រហម។ ឧត្តមសេនីយ៍កម្ពុជា ពេលខ្លះអាចផ្តល់នូវការសម្ភាសហើយប្រាប់ពួកយើងផងដែរ។ អាចប្រាប់ពីការបរាជ័យធ្ងន់ធ្ងរជាដើម។ ដូច្នេះវាបង្ហាញច្បាស់ហើយថាប្រទេសកម្ពុជាគឺចាប់ផ្តើមរួញស្រុញ -- បានន័យថារដ្ឋាភិបាលកម្ពុជាចាប់ផ្តើមរួញតូចទៅៗ គឺរដ្ឋាភិបាលរបស់ លន់ នល់ នោះ។

ដូច្នេះយើងគិតថា វាប្រហែលនឹងបរាជ័យនៅពេលណាមួយ។ ហើយមនុស្សចាប់ផ្តើមជម្លៀសមកទីក្រុង។ ហើយប្រជាជនត្រូវបានខ្មែរក្រហមកៀងឲ្យធ្វើជាទាហាន។ ខ្ញុំទទួលព័ត៌មានទាំងអស់នេះគឺដោយសារតែមានពេលវេលាគ្រប់គ្រាន់ ហើយយើងមិនអាចធ្វើដំណើរទៅគ្រប់កន្លែងបាន ប៉ុន្តែយើងអាចធ្វើដំណើរបានច្រើនកន្លែងដើម្បីសួរប្រជាជនឲ្យដឹងថា តើខ្មែរក្រហមធ្វើអ្វី? ថាតើខ្មែរក្រហមរុញចូលដល់ទីណា? ឬក៏ទីណា នោះឯង?

[០៩:៤០:៣៩]

**ស៖** លោកឆ្លើយថា លោកអាចធ្វើដំណើរបាន។ នេះជាសំណួរខ្ញុំចង់សួរលោក តើលោកបានទៅណាខ្លះ ក្នុងអំឡុងពេលមុនឆ្នាំ៧៥ នោះ? ហើយតើលោកយល់ឃើញថាអ្វីដែលបានកើតឡើងនៅក្នុងតំបន់រំដោះនោះ យ៉ាងដូចម្តេចខ្លះ? គឺខ្ញុំចង់សំដៅទៅព័ត៌មានដែលលោកអាចទទួលបានពីតំបន់រំដោះ។

**ឆ៖** គឺខ្ញុំទទួលព័ត៌មានច្បាស់ថា ខ្មែរក្រហមកំពុងតែរុញចូលមក ហើយពួកគេបានបង្កការបំផ្លិចបំផ្លាញទៅលើអគារ គឺខ្ញុំចង់និយាយថា ពួកគេបំផ្លាញអគាររដ្ឋាភិបាល រោងចក្រ ឬក៏តំបន់ទេសចរណ៍នៅដើមឆ្នាំ គឺថានៅពេលនោះប្រជាជនអាចប្រាប់យើងថាតើកន្លែងណាខ្លះដែលខ្មែរក្រហមគ្រប់គ្រង កន្លែងណាខ្លះដែលខ្មែរក្រហមមិនគ្រប់គ្រង។ គេអាចប្រាប់ថា ភូមិជាប់គេនេះខ្មែរក្រហម

គ្រប់គ្រងហើយ ប៉ុន្តែភូមិគេមិនទាន់ជាដើម។ ដូច្នេះយើងអាចទទួលបានព័ត៌មានបែបទាំងនេះ។ ហើយយើងអាចធ្វើដំណើរទៅតាមភូមិហ្នឹងភ្លាមៗឬក៏មួយភ្លែត យើងអាចធ្វើដំណើរទៅបាន ហើយខ្ញុំធ្វើបែបនេះ។

[០៩:៤២:២២]

**ស៖** ព័ត៌មានដែលលោកអាចទទួលបានតាមរបៀបដែលលោករៀបរាប់នេះ តើលោកមានទទួលបានព័ត៌មានពីជនភៀសខ្លួនដែលបានភៀសចេញពីតំបន់រំដោះហើយមករស់នៅទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** បាទ គឺថាមានជនភៀសខ្លួនជាច្រើនចូលមកទីក្រុង។ ហើយជនភៀសខ្លួនជាច្រើនចូលមកនៅក្នុងភ្នំពេញ និងនៅជុំវិញតំបន់ទីក្រុងភ្នំពេញ។ ខ្ញុំអាចជួបជាមួយពួកគាត់។ ហើយវាបង្ហាញច្បាស់ណាស់ថាខ្មែរក្រហមគឺចាប់ផ្ដើមវាយដណ្ដើមយកទីក្រុងម្ដងមួយ យកទីរួមខេត្ត ទីរួមស្រុកម្ដងមួយៗទោះបីថាយឺត ប៉ុន្តែប្រាកដណាស់គឺយកបានដោយជោគជ័យ។ គឺថាមិនមានសុទិដ្ឋិនិយមណាមួយដែលខ្ញុំគិតថារដ្ឋាភិបាលកម្ពុជា គឺថារដ្ឋាភិបាលលន់នល់ ហ្នឹងអាចជោគជ័យបាននោះទេ គឺខ្ញុំគ្មានសុទិដ្ឋិនិយមទាល់តែសោះ។ ទោះបីថាអាមេរិកជួយទម្លាក់គ្រាប់បែក ទោះបីថាការទម្លាក់គ្រាប់បែកអាមេរិកបញ្ចប់នៅឆ្នាំ៧៣ ហើយសភាសហរដ្ឋអាមេរិកបានបញ្ជាក់ថាគ្មានលុយដើម្បីជួយទៀតក៏ដោយ។ ដូច្នេះគឺវាប្រាកដណាស់។

**ស៖** មានចំណុចមួយចំនួនដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើល។ នៅក្នុងកំណត់ហេតុរបស់លោក ហើយនិងនៅក្នុងអត្ថបទផ្សេងៗរបស់លោកនោះលោកបានសរសេរថា ប្រជាជនកម្ពុជា និងជនបរទេសដែលនៅទីក្រុងភ្នំពេញគិតថារបប លន់ នល់ នឹងដួលរលំ ហើយមានមនុស្សជាច្រើនណាស់ចង់ឲ្យរបបនេះដួលរលំ ពិតណាស់។ ហើយពួកគេក៏យល់ឃើញថា របបកុម្មុយនីស្តហ្នឹងនឹងមិនអាក្រក់ជាងរបប លន់ នល់ ទេ។ ក្រៅពីការរុលចូលរបស់ខ្មែរក្រហមនោះ តើលោកមានព័ត៌មានអំពីថាតើការរស់នៅៗក្នុងតំបន់រំដោះនោះយ៉ាងម៉េចដែរ? ពីព្រោះថាខ្ញុំឃើញដូចជាមានភាពផ្ទុយគ្នារវាងអ្នកដែលគេចចេញពីតំបន់រំដោះមក នៅទីក្រុងភ្នំពេញនោះ វាលក្ខណៈខុសគ្នា។ អ៊ីចឹងហើយក៏ ប៉ុន្តែក៏មានសុទិដ្ឋិនិយមខ្លះដែរ។ តើលោកអាចពន្យល់បានទេ?

[០៩:៤៥:១០]

**ឆ៖** ខ្ញុំមិនដឹងថា តើលោកស្រីចង់និយាយពីសុទិដ្ឋិនិយមហ្នឹងចង់ចំណុចណាទេ។ ខ្ញុំមិនបានឮប្រជាជន ឬក៏មិនដែលធ្លាប់ឮអ្នកណាម្នាក់និយាយថា កុម្មុយនីស្តហ្នឹងជារឿងល្អនោះទេ។ ប្រហែលជា

មានអ្នកខ្លះនៅក្នុងកុម្មុយនីស្ត នៅក្នុងស្ថានទូតប្រទេសកុម្មុយនីស្ត ប៉ុន្តែដូចជាមិនមាននរណាម្នាក់ដែលខ្ញុំធ្លាប់ជួបហើយនិយាយថាល្អនោះទេ។ ខ្ញុំគិតថា ទាំងជនស៊ីវិល ទាំងទាហាន ទាំងអ្នកការទូតនៅទីនោះ គឺចាប់ផ្តើមខ្លាច ឬក៏ចាប់ផ្តើមដកថយដែលថា គឺចាប់ផ្តើមគិតថាខ្មែរក្រហមហ្នឹងទទួលជោគជ័យ។ ប្រជាជនកម្ពុជាពេលខ្លះគាត់មិនមានលក្ខណៈថាកាចសាហាវនោះទេ។

**ស៖** ខ្ញុំសួរសំណួរបែបនេះ ក៏ប៉ុន្តែខ្ញុំអត់មានពេលច្រើនទេ។ ដូច្នេះខ្ញុំនឹងមិនដកស្រង់នូវសំណេររបស់លោកនោះទេ ព្រោះថាលោកបានសរសេរក្នុងឯកសាររបស់លោកថា "លទ្ធិកុម្មុយនីស្តហ្នឹងអាចទៅរួច"។ ខ្ញុំចង់ត្រឡប់មកសួរសំណួរលោក ចង់ដឹងថាតើលោកមានទទួលបានព័ត៌មានជាក់លាក់អំពីជីវភាពរស់នៅ អំពីរបៀបរៀបចំតំបន់រំដោះរបស់ពួកខ្មែរក្រហមដែរឬទេ?

[០៩:៤៦:៥៥]

**ឆ៖** ខ្ញុំគិតថា យើងមិនដែលឮរបាយការណ៍អំពីបុគ្គលណាម្នាក់ដែលបានរត់គេចចូលមកទីក្រុងភ្នំពេញនោះទេ។ គឺយើងបានទទួលរបាយការណ៍តិចតួចពីមនុស្សដែលត្រូវបានគេឃុំខ្លួន ហើយគេបញ្ជូនទៅធ្វើការ និយាយអំពីមនុស្សដែលស្លាប់ដោយជំងឺ ដោយសារតែខ្វះចំណីអាហារ គឺថាមានបញ្ហាខ្វះម្ហូបអាហារនៅតាមតំបន់ជាច្រើន។ ទោះបីយ៉ាងណាក៏ដោយតំបន់ទាំងនោះគ្រប់គ្រងដោយរដ្ឋាភិបាល លន់ នល់។ ប៉ុន្តែទាំងអស់នេះសុទ្ធតែជារូបភាពអវិជ្ជមាន ហើយវាជារូបភាពមិនល្អរបស់ខ្មែរក្រហម។

**ស៖** ខ្ញុំនឹងសួរសំណួរផ្សេងទៀត ពីព្រោះថាព័ត៌មានដែលលោកទទួលបាននោះហាក់ដូចជាមានលក្ខណៈទូទៅពេក ហើយខ្ញុំគិតថាព័ត៌មាន -- វាពិបាកទទួលបានព័ត៌មានផ្ទាល់ណាស់នៅសម័យនោះៗ។ ចំពោះលោក ហើយនិងអ្នកកាសែតផ្សេងទៀតនុ៎ង ក៏ពិបាកក្នុងធ្វើដំណើរទៅកាន់តំបន់រំដោះដើម្បីយកព័ត៌មាននោះដែរ។ ឥឡូវនេះ ខ្ញុំចង់មកនិយាយអំពីទីក្រុងភ្នំពេញវិញ។ អម្បាញ់មិញនេះ តំណាងសហព្រះរាជអាជ្ញាបាននិយាយជាមួយលោកអំពីអូតែលឡឺភ្នំដែលលោកស្នាក់នៅ។ តើលោកអាចជម្រាបជូនបានទេថា តើ -- ខ្ញុំមិនថាគេហៅជាមន្ទីរពេទ្យ ឬគិលានដ្ឋាននោះទេ គឺថា ខ្ញុំចង់ដឹងថាតើនៅទីនោះនុ៎ងគេរៀបចំយ៉ាងម៉េចដែរ នៅពេលដែលលោកពិនិត្យឃើញថា មានហេតុការណ៍ដ៏គួរឱ្យភ័យខ្លាចបែបនេះនោះ? តើកន្លែងនុ៎ងហ្នឹង គេបំផ្លិចបំផ្លាញយ៉ាងម៉េចដែរ លោកអាចពន្យល់បានទេនៅអូតែលឡឺភ្នំនុ៎ង?

[០៩:៤៩:៣១]

**ឆ៖** តើលោកស្រីនិយាយអំពីថ្ងៃណាមួយ? ខ្ញុំច្របូកច្របល់ហើយឥឡូវនេះ។

**ស៖** សូមអភ័យទោស ខ្ញុំនិយាយថ្ងៃ១៧ មេសា នៅពេលដែលលោកត្រឡប់មកសណ្ឋាគារឡឺភ្នំ

វិញនោះ? ប្រហែលជាខ្ញុំអាចច្រឡំក៏ថា ក៏មិនដឹង ប៉ុន្តែគិតថាថ្ងៃទី១៧ មេសា ហ្នឹងហើយ គឺថាពេលនុ៎ង លោកកត់សម្គាល់ឃើញថា ត្រូវតែជម្លៀសប្រជាជនចេញពីសណ្ឋាគារ។ ដូច្នេះ ខ្ញុំគិតថានៅសណ្ឋាគារនុ៎ង ប្រហែលជាមានរៀបចំជាគិលានដ្ឋានមួយសម្រាប់ព្យាបាល ឬយើងអាចហៅជាពាក់កណ្តាលមន្ទីរពេទ្យ។ អ៊ីចឹងតើលោកអាចបញ្ជាក់បានទេ ថាតើនៅទីនោះ មានអ្នករបួសប៉ុន្មានដែលត្រូវបានព្យាបាល? ហើយថាតើក្រោយមកហ្នឹង គេកម្ទេចកន្លែងនោះយ៉ាងដូចម្តេចដែរ?

[០៩:៥០:៣០]

**ឆ៖** តាមដែលខ្ញុំចាំ ប្រហែលជាខ្ញុំចាំមិនច្បាស់ទេ ប៉ុន្តែខ្ញុំគិតថាដូចជាមិនមានវេជ្ជបណ្ឌិតអ្វីនោះទេ។ ប៉ុន្តែវាគ្រាន់តែជាតំណាង ជាមន្ទីរពេទ្យតំណាង លក្ខណៈតំណាងជាមន្ទីរពេទ្យ ឬក៏ជាសាខាមន្ទីរពេទ្យមួយ។ គឺថាខាងកាកបាទក្រហមមានបុគ្គលិកជាច្រើន ហើយពួកបុគ្គលិកកាកបាទក្រហមហ្នឹងស្នាក់នៅក្នុងសណ្ឋាគារនោះ។ ប៉ុន្តែខ្ញុំមិនដឹងថាពួកគាត់ធ្វើការអ្វីនោះទេ។ ហើយភាគច្រើនជនរងគ្រោះនៃសង្គ្រាមត្រូវបានគេយកទៅដាក់មន្ទីរពេទ្យជាច្រើន ដូចជាមន្ទីរពេទ្យព្រះកេតុមាលា។ គឺដាក់នៅអគារដែលគេធ្វើ គឺថានៅស្តាតគីឡាកន្លែងដែលគេប្រកួតប្រជែងកីឡាហ្នឹង ក៏គេយកទៅធ្វើកន្លែងដាក់អ្នកជំងឺផងដែរ។ ដូច្នេះខ្ញុំមិនដឹងច្បាស់ទេ។ ខ្ញុំមិនដឹងឲ្យជាក់ច្បាស់ថា តើកាកបាទក្រហមហ្នឹងគេធ្វើអ្វីនោះទេ។ គ្រាន់តែខ្ញុំដឹងថាមានបុគ្គលិកពេទ្យនៅទីនោះ តែបើគេធ្វើច្បាស់ ខ្ញុំមិនដឹងទេ។

**ស៖** សូមអរគុណលោក ស្តេនប៊ីក។ នៅក្នុងសៀវភៅរបស់លោក គឺឯកសារ E243.2។ លោកសរសេរថា នៅពេលនោះលោកនៅជាមួយ ឌិត ប្រន។ ហើយ ឌិត ប្រន ហ្នឹង រៀបរាប់អំពីលក្ខខណ្ឌលំបាកលំបិន ដូចជាមានអំពើហិង្សា ការភូតកុហក និងរបៀបដែលគេប្រព្រឹត្តចំពោះមនុស្ស និងរបៀបដែលគេប្រព្រិត្តចំពោះអ្នកស្នេហាជាតិនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំចង់ដឹងថា នៅពេលណាដែលលោកបានស្តាប់ឮគេនិយាយអំពីការកំណត់លក្ខណៈជាអ្នកជម្លៀសថាចាត់ទុកថាជា ១៧ មេសា អ្នកប្រជាជនថ្មីនេះ តើលោកស្តាប់ឮនៅពេលដែលលោកនៅស្ថានទូតនៅឡើយ ឬក៏ ឌិត ប្រន ជាអ្នកប្រាប់លោកនៅពេលក្រោយថា មានការបែងចែកជាប្រជាជន១៧ មេសា ឬប្រជាជនថ្មីនេះ?

[០៩:៥៣:៥២]

**ឆ៖** នៅពេលដែល ឌិត ប្រន ចេញពីការិយាល័យហ្នឹង គឺគាត់ប្រាប់ខ្ញុំនូវព័ត៌មានលម្អិត។ គឺថាខ្ញុំមិនអាចស្វែងរកឃើញថា តើអ្នកណាធ្វើអ្វី? អ្នកណានៅរស់ មិនរស់? ក្រោយបួនប្រាំឆ្នាំនោះ ខ្ញុំមិនអាចធ្វើបានទេ។ ដូច្នេះហើយ ខ្ញុំមិនមានព័ត៌មានអ្វីពីគាត់នោះទេ រហូតមកដល់ពេលគាត់ត្រឡប់មក

ហើយខ្ញុំដឹងថាគាត់នៅរស់រានមានជីវិត។ ដូច្នេះហើយ ឌិត ប្រន គឺជាអ្នកប្រាប់ខ្ញុំថាតើមានអ្វីកើតឡើង។ ឧទាហរណ៍ដូចថា នៅពេលគេលួច -- នៅពេលគាត់លួចប៉េងប៉ោះហ្នឹង គេធ្វើបាបគាត់យ៉ាងម៉េចខ្លះ ហើយគាត់បានរៀបរាប់ប្រាប់ខ្ញុំគ្រប់រឿងរ៉ាវទាំងអស់។ ហើយគាត់បង្ហាញពីការដែលគាត់លាក់ការងាររបស់គាត់ ហើយកុហកគេថាគាត់ជាអ្នកធាក់ស៊ីក្លូជាដើមហ្នឹង គឺគាត់រៀបរាប់ប្រាប់ខ្ញុំទាំងអស់។ ហើយគាត់នៅពេលនោះ គាត់ធ្វើជាល្ងង់អត់ដឹងខ្យល់អីជាដើមទាំងអស់នោះ។ ហើយដូចខ្ញុំប្រាប់លោកស្រីអ៊ីចឹងថា ឌិត ប្រន គាត់ប្រាប់ខ្ញុំទាំងអស់ ប៉ុន្តែ ឌិត ប្រន គាត់មិនមែនជាមនុស្សចូលចិត្តនិយាយកុហកទេ។

[០៩:៥៥:៣២]

**ស៖** សូមអរគុណ។ នៅពេលដែលគាត់រៀបរាប់អំពីរឿងរ៉ាវរបស់គាត់ប្រាប់លោកនោះ គឺយើងដឹងហើយថាមានអំពើហិង្សា។ តើគាត់មានប្រាប់លោកថាមានការបែងចែករវាងប្រជាជនចាស់ និងប្រជាជនមូលដ្ឋាន ពីព្រោះថាយើងកត់សម្គាល់ហើយឃើញថាអ្នកជម្លៀសចេញពីភ្នំពេញ គេចាត់ទុកជាប្រជាជន១៧មេសា។ អ៊ីចឹងតើគេមានប្រព្រឹត្តិអីផ្សេងគ្នារវាងអ្នកប្រជាជនទាំងពីរហ្នឹងទេ?

**ឆ៖** បាទ។ គាត់ប្រាប់ខ្ញុំអំពីរឿងរ៉ាវដែលថាប្រជាជនដែលខ្ញុំធ្លាប់ស្គាល់ មនុស្សដែលខ្ញុំធ្លាប់ស្គាល់ ដែលខ្ញុំរកឃើញ។ ប្រហែលជាពីរបីឆ្នាំក្រោយមក ត្រូវបានគេរកឃើញថាប្រជាជនទាំងអស់នោះ ឬក៏បុគ្គលទាំងអស់នោះធ្លាប់ធ្វើការនៅក្រុមហ៊ុនអាមេរិក ឬក៏សាព័ត៌មានអាមេរិក ហើយគេយកទៅសម្លាប់ចោលដោយសារគាត់ធ្លាប់ធ្វើការជាមួយពួកអាមេរិកជាដើម។ ហើយអ្នកបើកឡើងឲ្យខ្ញុំម្នាក់ក៏ត្រូវបានគេសម្លាប់ដែរ។

[០៩:៥៦:៥៩]

ខ្ញុំដឹងរឿងអស់នេះនៅពេលដែលសង្គ្រាមបានចប់ គឺថានៅពេលដែលក្រោយមកទេ ទើបខ្ញុំដឹង ខ្ញុំទាក់ទងជាមួយគ្រួសាររបស់ពួកគាត់។ ដូច្នេះខ្ញុំបានឃើញរបាយការណ៍ជាច្រើន របាយការណ៍អំពីបុគ្គលដែលជាអតីតទាហានខ្មែរក្រហមដែលគេនិយាយថា គេចូលចិត្តខ្មែរក្រហម ប៉ុន្តែខ្ញុំមិនដែលធ្លាប់ឮដោយផ្ទាល់នោះទេ។ ប៉ុន្តែចំពោះអ្នកដែលរត់គេចពីរបបខ្មែរក្រហម ខ្ញុំអត់ដែលឮគាត់និយាយថា និយាយពីអ្វីផ្សេងទេ និយាយតែពីការសម្លាប់មនុស្ស។ ហើយខ្ញុំប្រាកដណាស់ថាវាជាការប្រល័យពូជសាសន៍។ ប៉ុន្តែនេះវាជាទស្សនៈរបស់ខ្ញុំផ្ទាល់។ ភស្តុតាងទាំងអស់ដែលខ្ញុំមាន ឬក៏អាចនិយាយថាភ្លាមៗក្រោយពីចប់សង្គ្រាមហ្នឹង គឺថាភស្តុតាងទាំងអស់នោះ បង្ហាញមកខ្ញុំថា វាជាការប្រល័យពូជសាសន៍។ ប្រសិនបើផ្អែកទៅតាមនិយមន័យរបស់ពាក្យថា “ប្រល័យពូជសាសន៍” នោះ។

[០៩:៥៨:៣២]

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

លោក ស្តេនប៊ឺក សូមអរគុណច្រើនណាស់ដែលលោកបានឆ្លើយទៅនឹងសំណួររបស់យើងខ្ញុំ។

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានដើម្បីជាប្រតិចារឹក ខ្ញុំសូមរំឭកថា ទោះបីជាលោក ស្តេនប៊ឺក មានបទពិសោធន៍យ៉ាងណាក៏ដោយនោះ គឺថាគាត់មិនអាចនិយាយអំពីបទពិសោធន៍របស់គាត់ទៅលើអ្វីដែលបានកើតឡើងនោះទេ។ គាត់មិនអាចបញ្ចេញយោបល់ទេ ព្រោះថាគាត់មិនមែនជាអ្នកជំនាញទេ។ ដូច្នេះ យើងមិនអាចឲ្យគាត់និយាយយ៉ាងណា ដើម្បីឲ្យគាត់ផ្តល់យោបល់ទេ។ ដូច្នេះគាត់មិនអាចកំណត់ប្រភេទឲ្យបានច្បាស់លាស់នោះទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមរំឭកដល់លោក ស៊ីដនី ស្តេនប៊ឺកថា លោក ស៊ីដនី ស្តេនប៊ឺក ក្នុងនាមលោកជាសាក្សី លោកមិនគប្បីប្រើប្រាស់នូវការវិភាគ ឬក៏ការផ្តល់នូវមតិ បញ្ចេញនូវមតិយោបល់ឯកជនរបស់លោកវិភាគលើបញ្ហាដែលឡាយដែលកើតមានឡើង ដែលអង្គជំនុំជម្រះកំពុងដេញដោលនោះទេ។ នេះជាកិច្ចការដំណើរការរបស់អង្គជំនុំជម្រះ ហើយអង្គជំនុំជម្រះនឹងវិភាគពិចារណាសម្រេចលើបញ្ហានេះជាក្រោយ ដោយវិភាគលើអង្គហេតុ អង្គច្បាប់ និងភស្តុតាងជាច្រើនដែលយើងបាន ដែលមាននៅក្នុងសំណុំរឿង ហើយកំពុងដាក់ដេញដោលនេះ។

[១០:០០:០២]

បាទ អរគុណលោក ស្តេនប៊ឺក។ ឥឡូវនេះដល់ពេលសម្រាកហើយ ហើយអង្គជំនុំជម្រះសម្រាក ២០នាទីណ៎ា លោក ស្តេនប៊ឺក។ ២០នាទីក្រោយនេះ យើងនឹងបន្តកិច្ចដំណើរការសវនាការទៀត។

បាទ ហើយមុននឹងសម្រាកហ្នឹង អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងទៅលោក នួន ជា និងក្រុមមេធាវីការពារក្តីលោក នួន ជា ថាតាមសំណើរដែលលើកឡើងដោយ តាមរយៈលោកមេធាវី សុន អរុណ កាលពីព្រឹកមិញ គឺលោក នួន ជា សុំធ្វើអត្ថាធិប្បាយពាក់ព័ន្ធទៅនឹងអង្គហេតុនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជនមួយចំនួនទៀត។ អង្គជំនុំជម្រះសម្រេចយល់ព្រម ហើយ និងផ្តល់ឱកាសជូនទៅលោក នួន ជា គឺឡើងធ្វើអត្ថាធិប្បាយនៅពេលដើមដំបូងនៃវគ្គពីរ នៃសវនាការ

ព្រឹកនេះ។ បានន័យថា សម្រាករួចចូលមក គឺឲ្យគាត់ផ្ដល់ឱកាស ឲ្យគាត់ថ្លែងធ្វើអត្ថាធិប្បាយលើបញ្ហានេះតែម្ដង។

បាទឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់ និងម្ភៃនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:០១ នាទី ដល់ម៉ោង ១០:២២ នាទី)*

[១០:២២:១០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅលោក នួន ជា ដើម្បីឡើងធ្វើអត្ថាធិប្បាយពាក់ព័ន្ធទៅនឹងអង្គហេតុនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ កាលពីថ្ងៃអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយនិងទីប្រជុំជនមួយចំនួនផ្សេងទៀត។

លោក នួន ជា អង្គជំនុំជម្រះផ្ដល់វេទិកាជូនលោកធ្វើអត្ថាធិប្បាយហើយ។ សូមអញ្ជើញលោក នួន ជា!

**លោក នួន ជា៖**

សូមអរគុណលោកប្រធាន។ សូមគោរពអង្គប្រជុំ សូមគោរពបងប្អូនរួមជាតិទាំងអស់ ពិសេសសូមគោរពលោកប្រធាន។

[១០:២៣:១៦]

ខ្ញុំមានសេចក្ដីរីករាយដែលមានឱកាសបំភ្លឺដល់តុលាការ ដល់ជនរួមជាតិរបស់ខ្ញុំទាំងនៅក្នុងប្រទេស និងក្រៅប្រទេស។ អំពីហេតុនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ក្រោយពីបានរំដោះថ្ងៃ១៧ មេសា ១៩៧៥។ តាមខ្ញុំចាំមតិរបស់គណៈអចិន្ត្រៃយ៍នៃកម្ពុជាប្រជាធិបតេយ្យ ឬនិយាយឲ្យ

ច្បាស់របស់បក្សកុម្មុយនីស្តកម្ពុជាសម្រេចដូចតទៅនេះ៖ ពេលណារំដោះទីក្រុងភ្នំពេញ តើយើងត្រូវជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ឬទេ?

ពីព្រោះ ខទី១ បើកងទ័ពយើងចូលទៅក្នុងទីក្រុង កាន់កាប់ទីក្រុងភ្នំពេញ តើអាមេរិកទម្លាក់គ្រាប់បែកឬទេ? បញ្ហានេះយើងមិនអាចប៉ាន់ស្មានបានទេ ពីព្រោះអាមេរិកធ្លាប់ទម្លាក់គ្រាប់បែកនៅតាមជនបទមកហើយចំនួន២-៣០០ថ្ងៃ -- ៣០០យប់ ដើម្បីកម្ទេចកម្លាំងតស៊ូ ស្នេហាជាតិ និងកម្ទេចសេដ្ឋកិច្ចរបស់យើង។

[១០:២៥:០២]

ខទី២ មូលហេតុទី២ ហេតុទី២ បើប្រសិនជាអាមេរិកទម្លាក់គ្រាប់បែកអ៊ីចឹងមែន តើវៀតណាមឈរឱបដៃមើលទេ? គណៈអចិន្ត្រៃយ៍មានមតិថា វៀតណាមចាំតែឱកាសដើម្បីគេចូល គេធ្វើជាចូលទៅជួយកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះក្នុងឱកាសនោះ វៀតណាមក៏បញ្ជូនកងទ័ពដោយយកលេសថាទៅជួយកម្ពុជាក៏ប៉ុន្តែគេទៅគ្រប់គ្រងកម្ពុជា។

ដោយហេតុផលទាំងនេះហើយ មានពីរហេតុផល បើយើងជម្លៀសវាមានការស្រួលការលំបាកយ៉ាងម៉េច? បញ្ហានេះគណៈអចិន្ត្រៃយ៍បានអញ្ជើញប្រធានភូមិភាគមកជម្រាប តើភូមិ -- បើមាន -- មុខជាមានការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញហើយ ពេលណាដែលយើងបានរំដោះ? តើភាគណាអាចយកប្រជាជនបានប៉ុន្មាន? តាមខ្ញុំចាំគឺថា ភូមិភាគដែលមានភោគផល ស្រូវអង្ករ ធ្វើស្រែចម្ការបានច្រើនគឺភូមិភាគពាយ័ព្យ។ ដូច្នោះបានពិភាក្សាជាមួយគណៈភូមិភាគពាយ័ព្យ។ គណៈភូមិភាគពាយ័ព្យបានសម្រេចចិត្តថា យក១លាន៥សែននាក់។ ឯសល់ពីនេះ ប្រជាជនភ្នំពេញដែលពេលនោះមានចំនួន២លាននាក់ត្រូវចែកទៅតាមភាគផ្សេងៗ នីរតីយកប៉ុន្មាន? បូព៌ាយកប៉ុន្មាន? តែបញ្ហានេះក៏បានចែកគ្នាដាច់ស្រេចហើយបានបញ្ជាក់ទៀតថា ប្រជាជនយើងនៅក្នុងមូលដ្ឋានចាស់ត្រូវមានអាកប្បកិរិយាឲ្យត្រឹមត្រូវចំពោះប្រជាជនដែលជម្លៀសទៅនៅថ្មី ជាពិសេសខាងស្មារតីសាមគ្គីរាប់អានគ្នាជាបងជាប្អូន ជាជាតិមួយជាតិខ្មែរ កម្ពុជា ជាតិខ្មែរដូចគ្នា។ ដូច្នេះមិនត្រូវរើសអើងថាអ្នកនេះមកក្រោយ អ្នកនោះជាអ្នកមូលដ្ឋានអីទេ។ បញ្ហានេះគណៈភូមិភាគបានប្រជុំហើយបានធ្វើការងារសតិអារម្មណ៍ជាមួយសហករណ៍ជាមួយអីទាំងអស់ សព្វគ្រប់។

[១០:២៧:៥៦]

ដូច្នោះមិនមែនកម្ពុជាប្រជាធិបតេយ្យ លេងៗ -- សម្រេចការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ

នេះដោយអារម្មណ៍មិនទទួលខុសត្រូវនោះទេ គឺទទួលខុសត្រូវពេញទី។ ហេតុដូច្នោះហើយបានជាប្រជុំឡើងប្រជុំចុះសម្រេចឡើងសម្រេចចុះ។ នេះខ្ញុំសូមជម្រាប។

ប៉ុន្តែយើងឃើញច្បាស់ហើយថា ពេលណាដែលរំដោះហើយ ៗច្បាស់ហើយគឺថារំដោះត្រូវតែជម្លៀស បើមិនជម្លៀសទេ បង្ការក្រែងលោអាមេរិកមកទម្លាក់គ្រាប់បែក ព្រោះអាមេរិកធ្លាប់ទម្លាក់គ្រាប់បែកមកហើយ។ ២-៣០០លានតោន ២០០ថ្ងៃ ៣០០ថ្ងៃ ៣០០យប់ រណ្ដៅប៉ុនស្រះ។ ហើយពេលនោះប្រយ័ត្នមិត្តដែលទំនាស់។ អ្នកណាមិត្តដែលមានទំនាស់? គឺវៀតណាម។ នេះតាមមតិរបស់លេខាបក្ស គឺ ប៉ុល ពត គាត់បានសម្រេចថាវៀតណាមគឺជាមិត្ត ប៉ុន្តែមានទំនាស់។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹងតើវៀតណាមមើលឃ្លីងស្អែកទេ? អត់ទេ វៀតណាមមុខជាយកលេសធ្វើជាទៅជួយកម្ពុជា ហើយពេលនោះគេរៀបចំចាត់តាំងរដ្ឋអំណាចគេតាមកម្លាំងកងទ័ពគេចូលទៅក្នុងប្រទេសកម្ពុជាយើង។ នេះបញ្ហាស្មុគស្មាញណាស់ ខ្ញុំសូមជម្រាបបងប្អូនរួមជាតិឲ្យយល់។ ដូច្នេះមិនមែនបញ្ហាធ្វើអីធ្វើតាមចិត្តទេ សុទ្ធតែវិភាគ។

[១០:២៩:៤៦]

ខទី២ បើប្រជាជននៅទីក្រុងភ្នំពេញ តើមធ្យោបាយដឹកជញ្ជូនស្បៀងយកទៅចែកចាយជូនប្រជាជនយ៉ាងម៉េច? យើងពេលនោះតាមក្ដាប់បាន គឺថាក្នុងទីក្រុងភ្នំពេញ ១) គ្មានប្រេង។ ២) មធ្យោ-បាយដឹកជញ្ជូន ឡានខ្វះខាត។ ដូច្នោះ បើយើងទុកឲ្យប្រជាជននៅទីក្រុងភ្នំពេញយ៉ាងនេះ គឺមុខជាមានការវេទនា អត់ស្បៀង អត់អាហារ។ ហើយទោះបីជាផ្ដល់បានខ្លះក៏ដោយ ស្បៀងអាហារនេះធ្លាក់លើដៃអ្នកណា? មិនមែនលើដៃប្រជាពលករ អ្នកក្រីក្រលំបាកតោកយ៉ាកទេ ធ្លាក់លើដៃអ្នកដែលគេមានលុយទិញណ៎ះ គេទិញដើម្បីគេមានគ្រប់គ្រាន់បរិភោគ។ ឯអ្នកដែលក្រគ្មាន គឺគ្នាអត់ដូចដើម។ នេះជាហេតុផលទី២ គឺបញ្ហាមធ្យោបាយដឹកជញ្ជូន ខ្ញុំសូមជម្រាប។ ហើយជាពិសេសទៀតណ៎ះ ដូចខ្ញុំជម្រាបហើយជម្រាបទៀត គឺថាបញ្ជាក់តាមភូមិភាគត្រូវអប់រំសហករណ៍ឲ្យមានអាកប្បកិរិយា មាននយោបាយឲ្យត្រឹមត្រូវចំពោះអ្នកជម្លៀសមកថ្មី។ ដូច្នោះឲ្យគេធ្វើពលកម្មដូចយើងធ្វើមិនបានទេ គឺត្រូវចេះអធ្យាស្រ័យគ្នា ចេះស្រឡាញ់រាប់អានគ្នា។ ក៏ប៉ុន្តែបញ្ហានេះកន្លែងខ្លះធ្វើបានល្អ ប៉ុន្តែកន្លែងខ្លះមានការខ្វះខាតច្រើនតាមខ្ញុំចាំបាន។ ទោះបីមានការណែនាំហើយណែនាំទៀតក៏ដោយ ក៏ប៉ុន្តែបញ្ហាពួកបំផ្លាញក៏មាន។ ខ្ញុំសូមជម្រាបអង្គប្រជុំ សូមជម្រាបដូចតទៅនេះ។

[១០:៣១:៣៧]

សរុបមកវិញ មតិខ្ញុំក្នុងឋានៈពេលនោះ ខ្ញុំក៏ជាអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជាដែរ។ ខ្ញុំចាំមតិហ្នឹងគឺមានពីរខធំ។ ១) បញ្ហាអាមេរិកកាំងទម្លាក់គ្រាប់បែកឬទេ? គឺថាបញ្ហាទី២ គឺមធ្យោបាយដឹកជញ្ជូនយ៉ាងម៉េចដើម្បីផ្តល់ស្បៀងឲ្យអ្នកនៅទីក្រុង? ដូច្នោះសុខចិត្តឃើញការលំបាកហើយ ការឈឺថ្កាត់អីខ្លះក៏មាន ហើយយើងចេះជួយដោះស្រាយតាមលទ្ធភាពរបស់យើងទៅ។ ដូច្នោះសុខចិត្តជម្លៀសមកឲ្យប្រជាជនមករស់នៅតាមសហករណ៍ល្អជាងយើងទុកឲ្យប្រជាជនលំបាកវេទនានៅទីក្រុង។

មូលហេតុនេះហើយ ដូចខ្ញុំបានជម្រាបមកហើយ គឺដោយមនុស្សធម៌ មិនមែនដោយចង់យកប្រជាជនមកឲ្យលំបាកវេទនាដូចជាអ្នកខ្លះបានប៉ាន់ប្រមាណនោះទេ។ ការណ៍នេះ ខ្ញុំសូមជម្រាបដោយសេចក្តីស្មោះត្រង់អស់ពីដួងចិត្តរបស់ខ្ញុំក្នុងឋានៈទទួលខុសត្រូវពេលនោះដែរ។នេះខ្ញុំសូមជម្រាបប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក នួន ជា។

បាទ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សី ស៊ីដនី ស្កេនប៊ឺក។ សូមអញ្ជើញ!

[១០:៣៣:៤៣]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សួស្តីលោក ស្កេនប៊ឺក តើលោកស្តាប់ខ្ញុំឮដែរឬទេ?

**លោក ស៊ីដនី ស្កេនប៊ឺក៖**

**ឆ៖** បាទ ខ្ញុំស្តាប់ឮលោកច្បាស់។

**ស៖** សំណួរដំបូង មុនពេលដែលខ្ញុំចូលទៅដល់បរិបទសំណួររបស់ខ្ញុំនេះ គឺតើអម្បាញ់មិញលោកបានស្តាប់ឮអ្វីដែល នួន ជា បានឆ្លើយដែរឬទេ?

**ឆ៖** ខ្ញុំឮអំពីការឆ្លើយរបស់គាត់តាមរយៈការបកប្រែ។

**ស៖** ដូច្នេះលោកបានស្តាប់ឮគាត់និយាយអំពីប្រធានបទពីរបី ពាក់ព័ន្ធទៅនឹងហេតុការណ៍ ខែមេសា ឆ្នាំ៧៥។ ដូច្នេះខ្ញុំក៏សូមសួរលោកអំពីបញ្ហានេះផងដែរ។ ប្រធានបទដែលខ្ញុំចង់សាកសួរនៅក្នុងថ្ងៃនេះ គឺយ៉ាងហោចណាស់ពាក់ព័ន្ធទៅនឹងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក និងការខ្វះស្បៀងអាហារ ស្ថានភាពជនភៀសខ្លួននៅតាមជំរំ ហើយក៏ប្រហែលសាកសួរអំពីការគំរាមកំហែងដែល

អាចកើតមានពីខាងវៀតណាម។

មុនពេលដែលខ្ញុំចូលសួរទៅដល់សំណួរទាំងអស់នេះ ខ្ញុំសូមសួរលោកដោយខ្លីៗជាសំណួរផ្ដើម។ ជាពិសេស ថាតើខ្ញុំអាចសួរទេត្រង់ចំណុចទាំងអស់នេះ? ជាដំបូង ខ្ញុំកត់សម្គាល់ឃើញថា ព្រឹកមិញនេះ លោកបានសួរអ្នកណានៅក្នុងបន្ទប់ជាមួយនឹងលោកនោះ សូមឲ្យលោក ឲ្យគាត់នៅជិតលោកនោះ ជួយនឹកឈ្មោះ ប៊ីហ្ស។ ខ្ញុំឆ្ងល់ដែរ តើនៅក្នុងបន្ទប់វីដេអូនោះ នរណានៅជាមួយលោកដែរ?

[១០:៣៥:២៨]

**ឆ៖** ប្រពន្ធ – ភរិយារបស់ខ្ញុំ និងមន្ត្រីអង្គការសហប្រជាជាតិដែលបានជួយដំឡើងប្រព័ន្ធទំនាក់ទំនងនេះ ដើម្បីឲ្យខ្ញុំអាចផ្ដល់សក្ខីកម្មពីបុរីញូវយ៉កជាជាងធ្វើដំណើរទៅប្រទេសកម្ពុជា ផ្ដល់សក្ខីកម្មដោយផ្ទាល់។

**ស៖** សូមអរគុណ។ សំណួរដំបូងមួយទៀតនោះ គឺតើនៅចន្លោះ៧០ ដល់៧៥ លោកនៅទីណាដែរ? ទីតាំងធ្វើការរបស់លោកនៅទីណាដែរ? ខ្ញុំយល់លោកគ្របដណ្ដប់ព័ត៌មាននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ក៏ប៉ុន្តែទីតាំងដែលលោកតាំងនៅពេលធ្វើការនៅណាដែរ អំឡុងឆ្នាំ៧០ ដល់៧៥?

**ឆ៖** ទីតាំងដើមរបស់ខ្ញុំ គឺការិយាល័យនៅញូវឌេលី ដោយគ្របដណ្ដប់ព័ត៌មានពាក់ព័ន្ធទៅនឹងតំបន់អាស៊ីភាគខាងត្បូង។ ដូចជាប្រទេសឥណ្ឌា ភូមា ប៉ាគីស្ថង់ និងប្រទេសនានា នៅក្នុងភាគខាងត្បូងនោះ ហើយខ្ញុំក៏នៅជិតប្រទេសកម្ពុជាផងដែរនៅពេលនោះ ជាពិសេសនៅក្នុងទស្សវត្សឆ្នាំ៧០ នៅពេលដែលសម្ដេច សីហនុ ត្រូវបានបណ្ដេញចេញពីតំណែង ហើយរដ្ឋាភិបាលកាន់កាប់ដោយរបបលន់ នល់។ នៅពេលនោះ ខ្ញុំបានមកគ្របដណ្ដប់ផ្សាយព័ត៌មានផងដែរ ពាក់ព័ន្ធទៅនឹងស្ថានភាពនេះ។ ហើយបន្ទាប់មកខ្ញុំត្រឡប់ទៅញូវឌេលី រៀបចំនិពន្ធរឿងរ៉ាវនេះ នៅទីនោះ។ បន្ទាប់មកគេស្នើសុំខ្ញុំឲ្យត្រឡប់មកអាស៊ីអាគ្នេយ៍វិញ។

[១០:៣៧:៣០]

នៅពេលដែលវៀតណាមខាងជើងបានចាប់ផ្ដើមវាយប្រយុទ្ធ យើងហៅថាការវាយប្រយុទ្ធ-- "*អ៊ីស្ទើ អូហ្វេនស៊ីវ*"នៅក្នុងឆ្នាំ១៩៧៤។ ខ្ញុំគិតថាឆ្នាំ ប្រហែលខ្ញុំគិតថាខ្ញុំឆ្លើយទៅដូចជាមិនត្រូវនោះទេ ខ្ញុំនឹកមិនឃើញ។ ខ្ញុំចំណាយពេលក្នុងឆ្នាំនោះរៀបរាប់គ្របដណ្ដប់ព័ត៌មានទាក់ទងទៅនឹងការវាយសម្រុករបស់វៀតណាមខាងជើង។ ខ្ញុំមកប្រទេសកម្ពុជាសាជាថ្មី ហើយបានចំណាយពេលយ៉ាងយូរ ហើយគឺអ្វីដែលខ្ញុំនិយាយបាននោះ គឺថាខ្ញុំមិនអាចវិលត្រឡប់មកប្រទេសកម្ពុជាវិញបាននោះទេ។ ព័ត៌មានពាក់ព័ន្ធ

នឹងសង្គ្រាមនៅក្នុងប្រទេសកម្ពុជានោះ មិនបានផ្សព្វផ្សាយបានលម្អិតនោះទេ។ ដូច្នេះខ្ញុំចង់ក្តោបរឿងនេះឲ្យបានរឿងលម្អិត។ ដូច្នេះនេះជាស្ថានភាពទីតាំងដែលខ្ញុំធ្វើការងារ។

[១០:៣៨:៣៣]

**ស៖** ខ្ញុំសូមសង្ខេប បានន័យថាលោកគ្របដណ្តប់ព័ត៌មានសម្រាប់កាសែតញូវយ៉កថាមស៍អំពីសង្គ្រាមនៅប្រទេសកម្ពុជាចន្លោះឆ្នាំ៧០ ទៅដល់៧៥។ តើលោកមានបានផ្សាយព័ត៌មានគ្របដណ្តប់ពាក់ព័ន្ធទៅនឹងប្រទេសវៀតណាមដែលនៅជិតកម្ពុជាដែរឬទេ?

**ឆ៖** មានរយៈពេលមួយវែងដែរ ដែលខ្ញុំស្នាក់នៅវៀតណាម។ នៅក្នុងអំឡុងប្រយុទ្ធ "*អ៊ីស្ទើអូហ្វេនស៊ីវ*"នេះ។ ហើយខ្ញុំក៏បានធ្វើដំណើរទៅភាគខាងជើងវៀតណាម ទៅភាគខាងជើងផងដែរ ដែលនៅទីនោះគឺថាវៀតណាមបានឆ្លងកាត់ទីតាំងភាគខាងជើង ចូលមកវៀតណាមខាងត្បូង។ ដូចលោកបានដឹងហើយនៅទីនោះខ្ញុំនៅប៉ុន្មានខែដែរ ហើយខ្ញុំកាន់តែចាប់អារម្មណ៍ខ្លាំងៗឡើងលើស្ថានការណ៍ប្រទេសកម្ពុជា។ មូលហេតុនោះគឺដោយសារតែប្រទេសកម្ពុជាគឺជាប្រទេសមួយមិនមានលទ្ធភាពការពារប្រទេសដោយខ្លួនឯងបាន។ ជាប្រទេសមួយដែលខ្ញុំមិនដឹងព័ត៌មានច្រើននោះទេ ខ្ញុំចាប់ផ្តើមឆ្ងល់ ចាប់អារម្មណ៍កាន់តែច្រើន ព្យាយាមរៀបរាប់ សរសេរព័ត៌មានពាក់ព័ន្ធនឹងប្រទេសកម្ពុជាតែម្តង។

[១០:៣៩:៥៩]

**ស៖** លោកបានផ្តល់សក្ខីកម្មមុននេះថា លោកបានមកប្រទេសកម្ពុជាក្នុងឆ្នាំ៧០ ដល់៧៥ ញឹកញាប់ដែរ។ នៅក្នុងកំណត់ហេតុប្រចាំថ្ងៃរបស់លោកនៅត្រង់ទំព័រ១១១, ត្រង់ទំព័រ -- ត្រង់កថាខណ្ឌទី២ ERN 00898319។ កថាខណ្ឌទី២ គឺលើកឡើងថាខ្ញុំដកស្រង់សម្តី "នៅតាមផ្លូវ យើងឃើញមានការកម្ទេចវត្តដោយសារតែមានការបំផ្លាញវត្ត ដោយសារតែបេ-៥២នៅក្នុងឆ្នាំ១៩៧៣។ តើនេះជាស្ថាន-ភាពដែលលោកបានរៀបរាប់អ្វីដែលលោកបានឃើញនៅក្នុងឆ្នាំ៧៣ ឬក៏យ៉ាងណា? តើការទម្លាក់គ្រាប់បែកបេ-៥២នេះគឺលោកបានឃើញដែរឬទេ? ហើយលទ្ធផលដែលកើតឡើងនៅក្នុងពេលនោះលោកបានឃើញទេ ចន្លោះឆ្នាំ៧៣ទៅដល់៧៥នោះ ការបំផ្លិចបំផ្លាញដែលកើតឡើងដោយបេ-៥២នេះ?

**ឆ៖** ខ្ញុំឃើញនៅតាមកន្លែងច្រើនដែរ ការបផ្លិចបំផ្លាញបណ្តាលមកពីការទម្លាក់គ្រាប់បែកបេ-៥២ ហើយខ្ញុំបានរាយការណ៍ទៅលើព័ត៌មាននេះ។

[១០:៤១:២៩]

ខ្ញុំគ្មានភាពលម្អៀងទេ ថាតើអ្នកណាគេធ្វើការងារណា។ ខ្ញុំក្តោបផ្សព្វផ្សាយព័ត៌មានទាំងសងខាង

តែម្តង។ ហើយចំពោះព័ត៌មានពាក់ព័ន្ធនឹងស្ថានការណ៍អាមេរិកនេះ គឺថាខ្ញុំក្តោបព័ត៌មានយ៉ាងលម្អិត ហើយប្រុងប្រយ័ត្នណាស់។

**ស៖** តើលោកអាចពន្យល់បន្ថែមទៅលើហេតុការណ៍ដែលលោកបានឃើញ ជាពិសេសលទ្ធផលដែលកើតចេញពីការទម្លាក់គ្រាប់បែកបេ-៥២ ក្នុងអំឡុងពេលឆ្នាំ៧០ ដល់៧៣នោះ?

**ឆ៖** អ្វីដែលខ្ញុំបានឃើញ គឺទីកន្លែងនោះគឺគ្មានអ្នកណារស់នៅទៀតទេ កន្លែងដែលទម្លាក់គ្រាប់បែកនោះ។ ខ្ញុំមិនបាន -- ខ្ញុំបានទៅតាមទីជនបទដែលនៅទីនោះអ្នកកាសែត ដែលទៅតាមទីជនបទនោះ គឺថាត្រូវបានគេចាប់សម្លាប់ចោល ខ្ញុំមិនបានទៅតាមទីជនបទទាំងនោះទេ។ ហើយខ្ញុំមិនបានរៀបរាប់អំពីបញ្ហាហ្នឹងទេ ប៉ុន្តែខ្ញុំបានជួបជាមួយនឹងអ្នកភូមិ ហើយនិយាយអំពីហេតុការណ៍ដែលកើតឡើងចំពោះអ្នកកាសែតទាំងអស់នោះ។ ខ្ញុំបានរាយការណ៍លើបញ្ហានេះ។ ហើយខ្ញុំគិតថានៅបណ្ណសារដ្ឋានកាសែតញូវយ៉កថាមស៍ គឺមានរឿងរ៉ាវដែលខ្ញុំរៀបរាប់ទាំងអស់នេះ។

[១០:៤៣:០៣]

ខ្ញុំបានក្តោបព័ត៌មានច្រើនណាស់ ជាពិសេសអំពីបញ្ហានៃការទម្លាក់គ្រាប់បែករបស់អាមេរិក។ អាមេរិកនោះមិនសប្បាយចិត្តទេ នៅពេលដែលខ្ញុំរាយកាណ៍ព័ត៌មានទាំងអស់នេះនោះ។

**ស៖** នៅពេលដែលលោករៀបរាប់ដោយផ្ទាល់ទៅលើផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងអ្នករស់នៅក្នុងប្រទេសកម្ពុជានោះ ថាតើមានផលប៉ះពាល់អ្វីខ្លះទៅលើអ្នកទាំងអស់នោះ ដោយសារការទម្លាក់គ្រាប់បែករបស់អាមេរិក?

**ឆ៖** ខ្ញុំគ្មានបាន -- គ្មានមធ្យោបាយណាមួយអាចដឹងទេ--

**លោក អាប់ឌុលឡាក់ ថារីក៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

លោក ស្កេនប៊ឺក កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១០:៤៣:៤០]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមជំទាស់ដោយសារនេះជាសំណួរជាក់លាក់ ដូចដែលមេធាវីបានជំទាស់ខ្ញុំកាលពីម្សិលមិញ។

ដូច្នេះហើយគឺថាខ្ញុំក៏ក្រោកឈរជំទាស់ជាមួយនឹងការជ្រើសតាំងសំណួរជាក់លាក់ដូច្នេះចំពោះគាត់ផងដែរ។

**លោក វ៉ិចទ័រ កូប៉េ៖**

ម្សិលមិញខ្ញុំដូចជាអត់មានជំទាស់អីទេ។ គឺឆ្នាំមុនឆ្នាំ៧៥ គឺហេតុការណ៍ដែលពាក់ព័ន្ធ ដូច្នេះហើយអាចខ្ញុំសួរបាន។ ហើយប្រហែលជាលោកច្រឡំទេ មេធាវីខាងស្ដាំខ្ញុំទេដែលជាអ្នកជំទាស់ ខ្ញុំដូចជាអត់មានជំទាស់អីផង។

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ចំពោះមេធាវី ការជំទាស់នោះគឺលើកឡើងអំពីការស្នើសុំការសន្និដ្ឋាន និងមតិយោបល់ពីសាក្សី។ ដូច្នេះហើយនៅពេលនោះគឺមានការជំទាស់។ ដូច្នេះការសួរសំណួរបែបនេះគឺជាការទាញ ឲ្យមានទាញសន្និដ្ឋាន និងផ្ដល់ជាយោបល់។ ខ្ញុំសូមឡើងជំទាស់ចំពោះការសួរសំណួរបែបនេះដែរ។

[១០:៤៤:៤០]

**លោក វ៉ិចទ័រ កូប៉េ៖**

មិនអីទេ ដូច្នេះខ្ញុំអាចរៀបចំសំណួរឡើងវិញបាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើលោក ស្ពេនប៊ឹក បានឃើញលទ្ធផល ផលប៉ះពាល់លទ្ធផលកើតចេញដោយសារការទម្លាក់គ្រាប់បែករបស់អាមេរិកដែរឬទេ? ឬក៏លោកបានឃើញដោយផ្ទាល់ភ្នែក ស្ដាប់ឮផ្ទាល់ត្រចៀកអំពីផលប៉ះពាល់កើតចេញពីការទម្លាក់គ្រាប់បែកអាមេរិកដែរឬទេ?

**លោក ស៊ីដនី ស្ពេនប៊ឹក៖**

**ឆ៖** ខ្ញុំបានឃើញភូមិករណ៍នៅតាមផ្លូវត្រូវបានបំផ្លិចបំផ្លាញដោយការទម្លាក់គ្រាប់បែកនោះ។ ខ្ញុំគ្មានមធ្យោបាយណាមួយនោះទេ បើសិនបើខ្ញុំបាននោះ ខ្ញុំនឹងត្រូវគេសម្លាប់ចោលផងដែរ។ ខ្ញុំគ្មានមធ្យោបាយចូលទៅតាមតំបន់ទីតាំងដែលកាន់កាប់ដោយខ្មែរក្រហមនោះទេ។ ភស្តុតាងបានបង្ហាញច្រើនដែរ បង្ហាញថាអ្នកដែលទៅមើលនៅក្នុងដើមខែដែលទម្លាក់គ្រាប់បែក ឬឆ្នាំដែលទម្លាប់គ្រាប់ខែដំបូងៗនៅតាមតំបន់ទាំងអស់នោះ គឺនឹងត្រូវគេសម្លាប់ចោល។ ដូច្នេះហើយខ្ញុំក៏មិនដឹងដែរ តើប៉ះពាល់សេដ្ឋកិច្ចយ៉ាងម៉េច សម្លាប់មនុស្សប៉ុន្មាននាក់នោះឡើយ។ ខ្ញុំមិនដឹងថាតើការទម្លាក់គ្រាប់បែកមានផលវិជ្ជមាន

ចំពោះខាងខ្មែរក្រហម ឬក៏យ៉ាងណានោះទេ។ ហើយការទម្លាក់គ្រាប់បែកនេះជាការជំរុញឲ្យបុរសក្មេងៗ នេះចូលវាយប្រយុទ្ធជាមួយខ្មែរក្រហម ឬក៏យ៉ាងណាផងដែរ? ខ្ញុំគ្មានព័ត៌មានទេពាក់ព័ន្ធចំណុចនេះ។ នៅចុងក្រោយ លោកប្រាកដជាជ្រាបហើយ ក្រោយសង្គ្រាមគឺគេក៏មិនអាចឲ្យចូលទៅតាមតំបន់ទាំងអស់ នោះផងដែរ។

[១០:៤៦:៣៥]

**ស៖** សូមអរគុណលោក ស្កេនបឺក។

**ឆ៖** ខ្ញុំមិនអាចរៀបរាប់ចំណុចនេះបានទេ។

**ស៖** ខ្ញុំសូមសួរបន្តទៅលើប្រធានបទមួយនេះ។ សូមឲ្យលោកមើលទៅលើអ្វីដែលលោកបាន សរសេរនៅក្នុងកំណត់ហេតុប្រចាំថ្ងៃរបស់លោក ត្រង់ទំព័រ៧ គឺខែមករា ថ្ងៃ១១។ ឯកសារមានលេខ ERN 00898215, ត្រង់ថ្ងៃ១១ ខែមករា លោកបានសរសេរដូចតទៅ៖

"ផ្តេកបន្ទោរវន្ទះបានធ្វើឲ្យខ្ញុំភ្ញាក់ ថាមានសំឡេងផ្លង់អំពីការទម្លាក់គ្រាប់បែក។ នេះគឺជាគ្រាប់ បែកប្រឆាំងទៅនឹងបុគ្គលិកទាហាន ហើយមានការផ្ទុះនៅតាមតំបន់ជាច្រើន បានសម្លាប់ប្រជាជនច្រើន ផងដែរ។ ហើយវាខុសពីទម្លាក់គ្រាប់បែកសាមញ្ញដែលវាកម្ទេចតែទីដៅ ទីតាំងយោធាមួយចំនួនតូចៗ តែប៉ុណ្ណោះ។ នេះគឺជាលើកទី១ហើយដែលកងកម្លាំងកម្ពុជាបានប្រើប្រាប់អាវុធអាមេរិកនោះ ដើម្បី ធ្វើការទម្លាក់គ្រាប់បែកទៅលើប្រទេសកម្ពុជា"។ តើលោកផ្អែកព័ត៌មាននេះនៅប្រភពណាដែរនៅពេល ដែលលោកសរសេរនៅក្នុងកំណត់ហេតុរបស់លោក?

[១០:៤៨:០២]

**ឆ៖** ខ្ញុំស្តាប់អត់ឮសំណួរចុងក្រោយរបស់លោកនោះទេ។ សាក្សីបានសួរ។

**ស៖** តើលោកផ្អែកប្រភពព័ត៌មានមកពីណាដែរ នៅក្នុងកំណត់ហេតុរបស់លោក?

**ឆ៖** ប្រភពព័ត៌មានដែលខ្ញុំផ្អែក ប្រហែលជាអាចប្រភពចេញមកពីប្រទេសកម្ពុជា ហើយនិង ចេញមកពីប្រភពយោធាសហរដ្ឋអាមេរិក វាមិនមែនជាព័ត៌មានសម្ងាត់នោះទេ។ នេះប្រហែលជាអាច ប្រភពព័ត៌មានដែលខ្ញុំយកមកផ្អែកនៅក្នុងកំណត់ហេតុរបស់ខ្ញុំ។

**ស៖** បន្តទៅតាម ទៅបន្តទៅនឹងសំណួរដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសូមសួរដែលវាពាក់ព័ន្ធទៅ នឹងការផ្តល់ប្រឹក្សាយោបល់យោធាអាមេរិកនៅត្រង់ទំព័រ៨, នៅខាងក្រោម ថ្ងៃ១៤ ខែមករា ERN ជា ភាសាអង់គ្លេស 00898216 លោកបានសរសេរដូចតទៅ៖ "ស័ក្តិ៥ គឺទទួលខុសត្រូវទៅលើបញ្ហាហ្នឹង

ហើយនិយាយអំពីបញ្ហាសន្តិសុខ។ ហើយមិនមានការប្រឹក្សាយោបល់ដែលថាកម្ពុជាធ្វើសង្គ្រាមដោយខ្លួនឯងនោះទេ ក៏ប៉ុន្តែស័ក្តិ៥របស់អាមេរិកនោះ គឺថាបញ្ហាកងកម្លាំងយន្តហោះនៅក្នុងប្រទេសកម្ពុជា”។ នេះជាអ្វីដែលលោកបានសង្កេតឃើញដោយខ្លួនឯងផងដែរ ឬក៏យ៉ាងណា?

[១០:៤៩:៤២]

**ផ៖** ខ្ញុំសង្កេតឃើញនៅថ្ងៃនោះ ហើយខ្ញុំបានសរសេរចូលមែន។ ហើយខ្ញុំបានធ្វើការងារសរសេរអំពីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា។

**ស៖** តើលោកអាចរៀបរាប់យ៉ាងម៉េច ជាពិសេសចំពោះការដែលមានការប្រឹក្សាយោបល់ពីខាងយោធា អំពីសង្គ្រាមវាយប្រយុទ្ធរវាង លន់ នល់ និងទាហានបះបោរខ្មែរក្រហមនោះ?

**ផ៖** ខ្ញុំមិនយល់សំណួររបស់របស់លោកនោះទេ។ លោកសួរថាតើខ្ញុំដឹងដោយរបៀបណា ឬក៏យ៉ាងណាចំពោះអាមេរិកាំង។

**ស៖** សំណួររបស់ខ្ញុំនោះគឺថាតើលោកដឹងអ្វីខ្លះអំពីការចូលរួមយ៉ាងសកម្មរបស់អាមេរិកនៅក្នុងសង្គ្រាម លន់ នល់ ជាមួយនឹងពួកឧទ្ទាមបះបោរខ្មែរក្រហមនោះ?

**ផ៖** អ្វីដែលខ្ញុំបានដឹង មន្ទីរយោធានៅក្នុងស្ថានទូតអាមេរិកបានបញ្ជូនបុរស -- បុគ្គលិករបស់គេទៅពិភាក្សាអំពីការវាយប្រយុទ្ធឲ្យបានជោគជ័យ។ បានន័យថាមន្ត្រីយោធាពីស្ថានទូតនោះទៅពិភាក្សាជាមួយមន្ត្រីរបស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។ ខ្ញុំមិនមានព័ត៌មានណាមួយអំពីបុគ្គលណាមួយជាមន្ត្រីយោធាអាមេរិកដែលបានចូលរួមវាយប្រយុទ្ធជាមួយនឹងក្រុមទាហានសាធារណរដ្ឋខ្មែរ ហើយដឹកនាំការវាយប្រហារនោះទេ។

[១០:៥១:១៣]

ការពិភាក្សានោះ គឺគ្រាន់តែលើកឡើងអំពីមធ្យោបាយវាយសង្គ្រាមឲ្យបានទទួលជោគជ័យតែប៉ុណ្ណោះតាមតែខ្ញុំចាំ។ គ្មានអង្គភាពយោធាត្រូវបានបញ្ជូនទៅជួយនោះទេ លើកលែងតែក្នុងឆ្នាំ១៩៧០ ដូចដែលខ្ញុំបានសរសេរបញ្ជាក់នៅក្នុងកំណត់ហេតុរបស់ខ្ញុំ។

**ស៖** នៅក្នុងកំណត់ហេតុរបស់លោកទំព័រ៤៣ គឺមុនថ្ងៃ១២ ខែមេសាបន្តិច, ERN 00898251 លោកបានសរសេរថា “ក្រោយមក ខ្ញុំបានពិភាក្សាជាមួយសេនាព័ន្ធយោធា ក៏ប៉ុន្តែបានឃើញចំណុចមួយការណ៍សមរភូមិដែលបានកើតឡើងនៅក្នុងទីក្រុងនាថ្ងៃនោះ។ យើងបានសម្លាប់២២នាក់នៅលើ នៅក្នុងសង្គ្រាម។ ដូច្នេះវាជាឱកាសល្អណាស់”។ តើលោកនៅចាំទេការសន្ទនានេះ ជាពិសេសការសន្ទនាជាមួយ

នឹងសេនាព័ន្ធយោធា?

**ឆ៖** បាទនៅក្នុងកំណត់ហេតុខ្ញុំ ខ្ញុំបានសរសេរចំណុចនេះ។

**ស៖** តើលោកនៅចាំអ្វីខ្លះទៀតអំពីសន្ទនានេះ?

**ឆ៖** គេបានលើកឡើងអំពីចំណុចហ្នឹង។ នេះគឺអ្វីដែលគេបាននិយាយសប្បាយចំពោះបញ្ហាសង្គ្រាមនោះ តើវាយ៉ាងម៉េច? នេះគឺជាបញ្ហានៃការធ្វើសង្គ្រាម។ ដូច្នេះខ្ញុំបានសរសេរក្តោបទៅលើព័ត៌មានហ្នឹង។ អ្នកណាដែលគេបាននិយាយ និងអ្នកណាដែលមិនបាននិយាយ។

[១០:៥២:៥៧]

**ស៖** សំណួររបស់ខ្ញុំចំពោះលោក គឺខ្ញុំចង់សួរផងដែរ តើលោកអាចរៀបរាប់ជូនយើងយ៉ាងម៉េចដែរ អំពីការចូលរួមយ៉ាងសកម្មពីរដ្ឋាភិបាលអាមេរិកនៅក្នុងសង្គ្រាមវាយប្រយុទ្ធជាមួយនឹងពួកខ្មាំងបះបោរនោះ?

**ឆ៖** អ្វីដែលខ្ញុំដឹងនោះគឺ អាមេរិកប្រើកងទ័ពទាហានរបស់គេ និងឧបករណ៍ជាមគ្គុទេសក៍ក្នុងការធ្វើសង្គ្រាម គឺឧបករណ៍មកពីប្រទេសថៃចូលមកប្រទេសកម្ពុជា។ ហើយអាមេរិកនេះ គឺគេបានពិភាក្សាជាមួយនឹងកម្ពុជា ថាតើត្រូវធ្វើយ៉ាងម៉េចនៅលើការធ្វើសង្គ្រាមនេះ? នាពេលនោះ គេបានរកឃើញថាអាមេរិកធ្វើការទាក់ទងបញ្ហានេះពីស្ថានទូត។ ដូច្នេះវាជាការរំលោភសិទ្ធិ រំលោភច្បាប់ដែលសភាអាមេរិកអនុម័ត។ ហើយអាមេរិកនោះ បុគ្គលិកអាមេរិក យោធាត្រូវតែចេញពីស្ថានទូតដើម្បីទាក់ទងគ្នាពាក់ព័ន្ធទៅនឹងសង្គ្រាមនេះមិនអាចធ្វើការទាក់ទងនៅក្នុងស្ថានទូតនោះទេ។ អាមេរិកព្យាយាមជួយ យើងឃើញច្បាស់អ៊ីចឹង។ ក៏ប៉ុន្តែខ្ញុំមិនដឹងនិយមន័យនៃសង្គ្រាមនោះ វាមានន័យយ៉ាងម៉េចទេចំពោះសកម្មភាពនេះថាតើវាជាការចូលរួមក្នុងសង្គ្រាម ឬក៏យ៉ាងណា?

[១០:៥៤:៤០]

**ស៖** តើលោកចាំអ្វីខ្លះ អំពីការយល់ស្របផ្តល់ជំនួយរបស់អាមេរិកនៅក្នុងអំឡុងឆ្នាំ៧៤ និង៧៥នោះ?

**ឆ៖** គេបានដឹងថា សភារបស់អាមេរិកយល់ជាបញ្ហាបន្ទាន់អំពីតួនាទីរបស់អាមេរិកនៅក្នុងប្រទេសកម្ពុជា។ ហើយសភាបានសម្រេចថា ការទម្លាក់គ្រាប់បែកត្រូវតែបញ្ឈប់ ហើយខ្ញុំជឿថាដូចជាឈប់ទម្លាក់គ្រាប់បែកនៅក្នុងខែកក្កដា ឆ្នាំ១៩៧៣ តាមខ្ញុំចាំ។ ក្រោយមក សភាបានបដិសេធមិន គឺមិនបដិសេធមិនចូលរួមវាយទៅលើខ្មែរក្រហម។ ដូច្នេះហើយគឺនេះជាព័ត៌មានដែលខ្ញុំមាន។ ខ្ញុំបានសរសេរ

អំពីចំណុចហ្នឹង។ ហើយលោកលើកឡើងថា អ្នកណាគេជាអ្នករងរបួស រងនូវការបំផ្លិចបំផ្លាញនោះគឺថាខ្ញុំក៏បានសរសេរដែរ។ សង្គ្រាមមិនមែនថាចេះតែគ្រប់គ្រងដោយមនសិការនោះទេ ពេលខ្លះត្រូវគ្រប់គ្រងដោយគ្មានមនសិការតែម្ដង។ ដូច្នេះហើយបានន័យថាត្រូវគ្រប់គ្រងដោយឆ្លតលីលា។ ខ្ញុំបានរៀបរាប់អំពីព័ត៌មានហ្នឹង។ អ្វីដែលខ្ញុំសរសេរហ្នឹងគឺតាមបទពិសោធន៍របស់ខ្ញុំនិងអ្វីដែលខ្ញុំបានឃើញ ហើយខ្ញុំបានយកទៅសរសេរនៅក្នុងរឿងរ៉ាវដែលខ្ញុំរៀបរាប់។

[១០:៥៦:៤៩]

**ស៖** តើលោកចាំទេ លោកចាំថានៅក្នុងឆ្នាំ៧៣, ៧៤ ឬក៏៧៥នោះ លោកបានរៀបរាប់អំពីប្រភពដែលថាការទម្លាក់គ្រាប់បែករបស់អាមេរិកនោះអាចចាប់ផ្ដើមឡើងវិញ?

**ឆ៖** ខ្ញុំមិនបានដឹងថាមានការពិភាក្សាគ្នាឡើងវិញ អំពីការចាប់ផ្ដើមទម្លាក់គ្រាប់បែកឡើងវិញនោះទេ។ វាអាចមានការពិភាក្សា ក៏ប៉ុន្តែខ្ញុំមិនបានទទួលព័ត៌មាននោះទេ។ មិនមានបុគ្គលិកណាមួយនៅក្នុងស្ថានទូតអាមេរិកនៅក្នុងប្រទេសកម្ពុជាលើកឡើងអំពីការពិភាក្សាឲ្យទម្លាក់គ្រាប់បែកឡើងវិញនោះទេ។ ដូច្នេះខ្ញុំមិនបានដឹងទេព័ត៌មានហ្នឹង។

**ស៖** ក៏ប៉ុន្តែនៅកំណត់ហេតុរបស់លោកទំព័រ៣៦, ថ្ងៃទី៥ ខែមេសា, នៅកថាខ័ណ្ឌទី៤, ERN 00898244 លោកបានសរសេរថា ពាក្យចចាមអារ៉ាមនៅក្នុងអង្គភាពយោធាខ្លះថា អាមេរិកនឹង ជួយរដ្ឋាភិបាលក្នុងរយៈពេលប៉ុន្មានថ្ងៃនេះតាមរយៈការទម្លាក់គ្រាប់បែកទ្រង់ទ្រាយធំ បេ-៥២សាជាថ្មី។ តើលោកសរសេរព័ត៌មាននេះយ៉ាងម៉េចដែរ ប្រសិនបើលោកគិតថាមិនមានលទ្ធភាពអ៊ីចឹងកើតឡើងនោះ?

[១០:៥៨:២៣]

**ឆ៖** ខ្ញុំគិតថាលោក ប្រហែលជាមិនធ្លាប់ចូលរួមក្នុងសង្គ្រាម ធ្វើសង្គ្រាមនោះទេ។ នៅពេលធ្វើសង្គ្រាមនោះមានពាក្យចចាមអារ៉ាមច្រើនណាស់លើកឡើង។ ម្នាក់ៗនោះមានក្ដីសង្ឃឹមថាសង្គ្រាម នឹងបញ្ចប់។ ដូច្នេះហើយពាក្យចចាមអារ៉ាមមាននៅរប៉ាត់រប៉ាយអ៊ីចឹង លេចឮដូចគ្នា។ ខ្ញុំគ្រាន់តែរៀបរាប់លោកអំពីបរិយាកាសនាពេលនោះយ៉ាងម៉េចទេ នៅក្នុងទសវត្សរ៍ទី៧០ ទើបខ្ញុំរៀបរាប់ដូច្នេះ។ គ្មានអ្វីក្រៅពីហ្នឹងនោះឡើយ។

**ស៖** តើលោកអាចជម្រាប ឬក៏លោកអាចនឹកឃើញឡើងវិញ ថាតើគេយកបញ្ហាពាក្យចចាមអារ៉ាមទៅគិតពិចារណាយ៉ាង់ម៉ត់ចត់ដែរឬទេ?

**ឆ៖** ខ្ញុំមិនដឹងទេ។ ខ្ញុំមិនបានរត់ផ្ដេកផ្ដាទៅសួរគេសួរឯង ថាតើវាជាពាក្យចចាមអារ៉ាម ឬក៏ពាក្យ

ពិតនោះទេ។ វាជាពាក្យចចាមអារ៉ាម ដូច្នេះខ្ញុំសរសេរថាចចាមអារ៉ាមអ៊ីចឹងទៅ។

**ស៖** ខ្ញុំសូមសួរអ៊ីចេះវិញ ថាតើលោកដឹងថាព័ត៌មានចចាមអារ៉ាមនោះ មកពីណាដែរឬទេ?

[១០:៥៩:២៩]

**ឆ៖** អត់ដឹងទេ។ គឺវាលេចចេញពីកន្លែងណាមួយមកមិនដឹង ហើយខ្ញុំបានទទួលព័ត៌មានហ្នឹងតែម្តង។ ខ្ញុំមិនដឹងថាចេញមកពីកន្ថុកកន្លៀតណានោះទេ ពាក្យចចាមអារ៉ាមហ្នឹង?

**ស៖** តើលោកធ្លាប់និយាយជាមួយនឹងគេឯងនៅក្នុងពេលនោះ ដែលអ្នកទាំងអស់នោះជឿថាការទម្លាក់គ្រាប់បែកអាមេរិកអាចចាប់ផ្តើមក្នុងពេលណាមួយជាមិនខាន?

**ឆ៖** អត់ទេ ខ្ញុំអត់បានពិភាក្សាជាមួយគេទេ។ បញ្ហាជាក់ស្តែងនោះ គឺថាអ៊ីចេះលោកមេធាវី។ អ្វីដែលខ្ញុំបានដឹងអំពីអ្វីដែលរៀបចំផែនការនៅក្នុងស្ថានទូតអាមេរិកក្នុងប្រទេសកម្ពុជា គឺអគ្គរដ្ឋទូត ចននោះព្យាយាមឲ្យវ៉ាស៊ីនតោន គឺ ឃីងហ្សិន -- និកសុន ហើយ ឃីស៊ីងហ្គ័រ នេះទៅពិភាក្សាចរចាជាមួយនឹងខ្មែរក្រហមទៅ។ ខ្ញុំបានសរសេរអំពីព័ត៌មានហ្នឹងដែរ គឺអគ្គរដ្ឋទូតហ្នឹងធ្វើការតវ៉ាឲ្យទៅពិភាក្សាគ្នាម្តងហើយម្តងទៀត ហើយលើកលែងតែលោកគិត -- គាត់បានលើកឡើងថា លើកលែងតែលោកគិតថាទាល់តែមានហេតុផលថាឈ្នះទើបយើងមិនទៅចរចា។ អគ្គរដ្ឋទូតនោះគឺយល់ឃើញថាវាជាការមួយមិនប្រសើរដែរ ប្រសិនបើធ្វើការទាក់ទងជាមួយនឹងមេដឹកនាំខ្មែរក្រហមនាពេលនោះ។ ហើយរដ្ឋាភិបាលអាមេរិកនៅពេលនោះ ជំទាស់ទៅលើសំណើសុំរបស់អគ្គរដ្ឋទូតហ្នឹងម្តងហើយម្តងទៀត។

[១១:០១:២២]

**ស៖** ខ្ញុំនិយាយអំពីអគ្គរដ្ឋទូត ឌីន ដែលលោកបានលើកឡើងអម្បាញ់មិញហ្នឹង លោក ស្តេនប៊ីកនៅក្នុងទំព័រទី១០ នៃកំណត់ហេតុរបស់លោក ថ្ងៃទី២៩ ខែមករា លោកបានសរសេរដូចតទៅក្នុង ERN 00898218, កថាខណ្ឌទី៤ ពីខាងក្រោម។ លោកសរសេរដូចតទៅថា “សួរថាអាមេរិកាំងដឹងអ្វីខ្លះអំពីជួរដឹកនាំខ្មែរក្រហម ហើយថាអាចចរចាជាមួយនរណាគេនោះ? លោកឯកឧត្តម ឌីន បានលើកឡើងថា យើងដឹងតិចតួចណាស់ តិចតួចមែនទែនអំពីបញ្ហាខ្មែរក្រហមនេះ”។ តើលោកចាំថា គាត់និយាយអ៊ីចឹងជាមួយលោកដែរឬទេ?

**ឆ៖** បាទ ខ្ញុំចាំ។

**ស៖** តើលោកនៅចាំថា គាត់និយាយពន្យល់បន្ថែមលើកចំណុចនេះទៀតដែរឬទេ? គាត់និយាយអី -- អ្វីបន្ថែមដែរឬទេ?

**ផ៖** អត់ -- ដូចអត់មានទេ។ អត់មាននិយាយបន្ថែមនោះទេ។

[១១:០២:២៦]

**ស៖** ពីខាងដើមលោកបានឆ្លើយថា លោកមិនបាននិយាយជាមួយនឹងកម្មាភិបាលខ្មែរក្រហម មិនថាថ្នាក់លើ និងថ្នាក់ក្រោម។ គាត់បាននិយាយអ៊ីចឹងដែរឬទេ?

**ផ៖** គឺគាត់បាននិយាយអ៊ីចឹងមែន។ គឺអត់ទេ អត់មានទៅនិយាយទេ។

**ស៖** តើត្រឹមត្រូវដែរឬទេ តាមការចងចាំរបស់លោក លោកក៏បានដឹងតិចតួចដែរអំពីបញ្ហាខ្មែរក្រហមនេះ?

**ផ៖** ជាការពិត យើងមិនដឹងរឿងរ៉ាវរាក់ជ្រៅអ្វីដែលពួកគេធ្វើនោះទេ។ ហើយអ្នកធ្វើរបាយ-ការណ៍សារព័ត៌មានក៏មិនអនុញ្ញាតឲ្យទៅតំបន់កាន់កាប់របស់ពួកគេផងដែរ ដោយសារបើសិនប៉ានទៅគេសម្លាប់ចោលភ្លាម។ ដូច្នេះយើងមិនដឹងរាក់ជ្រៅច្រើនទេ លើកលែងតែសារទូរលេខដែលយើងទទួលបានពីមនុស្សម្នាទាំងឡាយដែលត្រូវបានគេបំភិតបំភ័យសម្លាប់ចោល ឬក៏ត្រូវបានគេបង្ខំឲ្យចូលរួមនៅក្នុងសង្គ្រាម គឺអ្នកទាំងអស់នោះ គេប្រាប់យើង។

[១១:០៣:៥១]

**ស៖** តើអាចដែរឬទេ បើសិនតាមលោកចាំក៏ដូចជាបទពិសោធន៍របស់លោក នៅពេលដែលលោកឆ្លើយសំណួរហ្នឹង តើវាអាចដែរឬទេ នៅពេលដែលយើងនិយាយថា ទស្សនៈអំពីខ្មែរក្រហមចន្លោះពីឆ្នាំ៧០ ដល់៧៥ ជាពិសេសនៅក្នុងឆ្នាំ៧៥ ទាក់ទងទៅនឹងលទ្ធភាពនៃការទម្លាក់គ្រាប់បែក -- មិនមែនខ្ញុំចង់ឲ្យលោកស្មាន ឬក៏សន្មតទេ ក៏ប៉ុន្តែតាមសមត្ថភាព តាមចំណេះដឹងរបស់លោកនោះ ក៏ដូចជាតាមរយៈការសន្ទនារបស់លោកជាមួយអ្នកដទៃទៀត ថាតើវាអាចដែរឬទេ ដែលថាខ្មែរក្រហមបារម្ភថាអាមេរិកអាចនឹងចាប់ផ្ដើមទម្លាក់គ្រាប់បែកសាជាថ្មីឡើងវិញនោះប្រសិនបើវាអាចមាននោះ?

**ផ៖** --

**ប្រធានអង្គជំនុំ៖**

លោក ស្ដេនប៊ីក កុំអាលទាន់ឆ្លើយតប! មានការជំទាស់តវ៉ាពីតំណាងសហព្រះរាជអាជ្ញា។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថាវីក៖**

ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ ហើយសហ -- ហើយមេធាវីគឺគាត់ត្រឹមត្រូវហើយដែលគាត់

ស្ទាក់ស្ទើរមិនហ៊ានសួរ ប៉ុន្តែវានេះមិនមែនជាសំណួរដែលត្រឹមត្រូវ។ ដូច្នេះយើងមិនគួរអនុញ្ញាតឲ្យការសួរសំណួរបែបនេះទេ។

[១១:០៥:០៧]

**លោក វ៉ិចទ័រ កូប៉េះ**

លោកប្រធាន អ្វីដែលខ្ញុំចង់និយាយ គឺថាខ្ញុំចង់ព្យាយាមបង្រួមសំណួរខ្ញុំឲ្យបានត្រឹមត្រូវតាមដែលអាចធ្វើទៅបាន។ ប៉ុន្តែខ្ញុំទទួលស្គាល់ថា សាក្សីនេះមិនមែនជាអ្នកជំនាញ ប៉ុន្តែខ្ញុំគិតថាវានៅក្នុងរង្វង់នៃការសួរដេញដោលផ្អែកទៅលើការសង្កេតរបស់គាត់ តាមការសន្ទនារបស់គាត់ ថាតើគាត់នៅតែគិតថាវាអាចដែរឬទេ ដែលថាមេដឹកនាំខ្មែរក្រហមគិតថា ការទម្លាក់គ្រាប់បែកសាជាថ្មីឡើងវិញនៅទីក្រុងភ្នំពេញនោះ វាអាចកើតមានឡើង។ តើវាអាចដែរឬទេ?

**លោក ស៊ីដនី ស្កេនប៊ឺក៖**

តើលោកប្រធាន ចង់ឲ្យខ្ញុំឆ្លើយតប ឬមួយក៏យ៉ាងដូចម្ដេច?

[១១:០៥:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:០៦:១៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចថា សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាចំពោះសំណួរចុងក្រោយ ដែលសួរឡើងដោយមេធាវីអន្តរជាតិការពារក្ដី នួន ជា ហ្នឹងគឺមានមូលហេតុសមស្រប។

សំណួរប្រភេទនេះ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យប្រើប្រាស់ទេ នៅក្នុងកិច្ចដំណើរការសវនាការយើងនេះ។ ហើយលោកមេធាវីការពារក្ដីលោក នួន ជា បានយល់ដឹងច្បាស់លាស់ហើយ ហើយមានការជំទាស់តវ៉ាជាច្រើនកាលពីម្សិលមិញ។ រាល់សំណួរទាំងឡាយឯណាដែលសួរសំដៅឲ្យសាក្សីផ្ដល់ចម្លើយជាការបញ្ចេញនូវមតិយោបល់របស់ខ្លួន ឬបែបសេចក្ដីសន្និដ្ឋាននេះ គឺអង្គជំនុំជម្រះមិនអនុញ្ញាតឡើយ។ ដូច្នេះ សាក្សីមិនចាំបាច់ឆ្លើយតបទៅនឹងសំណួរដែលសួរចុងក្រោយដោយលោកមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា នេះទេ។ សូមលោករៀបចំសំណួរថ្មី ឬក៏បន្តសំណួរថ្មីតទៅទៀត។

[១១:០៧:០៩]

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** ខ្ញុំនឹងបន្តទៅប្រធានបទទី២របស់ខ្ញុំ ហើយប្រធានបទទី២របស់ខ្ញុំក៏ត្រូវបានលើកឡើងដោយសង្កេតរួចទៅហើយ ដោយនៅក្នុងសេចក្ដី -- នៅក្នុងចម្លើយរបស់លោក នួន ជា ដែលបានធ្វើពីមុននេះរួចមកហើយ។ ទាក់ទងទៅនឹងបញ្ហាការផ្គត់ផ្គង់ចំណីអាហារនៅក្នុងទីក្រុងភ្នំពេញក្នុងឆ្នាំ៧៥។ គឺនៅក្នុងកំណត់ត្រារបស់លោក គឺមានការរៀបរាប់ច្រើនអំពីកង្វះចំណីអាហារ ក៏ដូចជាកង្វះអាហារូបត្ថម្ភ និងភាពអត់ឃ្លានដែលកាន់តែកើនឡើងច្រើនឡើងៗ។

ដើម្បីជាកំណត់ត្រាប្រតិចារឹក ខ្ញុំសូមបង្ហាញលោកអំពីកំណត់ត្រារបស់លោក ហើយខ្ញុំនឹងលើកឡើងនូវចំណុចមួយចំនួនដែលលោកបានលើកឡើង។ ជាឧទាហរណ៍ នៅទំព័រទី១០ នៃកំណត់ត្រារបស់លោក គឺខណ្ឌចុងក្រោយនៅថ្ងៃ៣០ គឺលេខ 00898218 គឺលោកនិយាយអំពីការផ្គត់ផ្គង់ចុងក្រោយនៃចំណីអាហារ គឺការផ្គត់ផ្គង់ចំណីអាហារនិងគ្រាប់ និងគ្រឿងសព្វាវុធ ហើយមួយជួរខាងលើ គឺលោកបាននិយាយដូចតទៅនេះ គឺថាការផ្គត់ផ្គង់បានមកដល់ នៅទំព័រទី១៤ នៃកំណត់ត្រារបស់លោកនៅដើមខាងលើបំផុតនោះ។ លោកបាននិយាយថា "ខ្ញុំបានចូលទៅក្នុងគ្លីនិករបស់ខាងលោកខាងលិច ហើយបញ្ហាកង្វះចំណីអាហារគឺមានយ៉ាងច្រើន ហើយក្មេងៗ គឺឃើញក្មេងស្លាប់នៅលើគ្រែព្យាបាលជំងឺជាដើម។ ហើយនៅលើគ្រែមួយ គឺមានក្មេងម្នាក់អាយុប្រាំបួនដណ្ដប់ខែ ស្លាប់"។ ហើយលោកនិយាយបន្តរៀបរាប់តទៅទៀត ហើយនិយាយថា "ភាពអត់ឃ្លានរបស់ប្រជាជនកម្ពុជាកាន់តែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ"។

[១១:០៩:២៣]

ហើយនៅទំព័រទី១៦ គឺនៅថ្ងៃទី២៣ ខែកុម្ភៈ 00898224 ហើយលោកសរសេរនៅកថាខណ្ឌទី២ ខាងក្រោម "ទោះបីជាស្ថានភាពរស់នៅវាមានការខុសក៏ដោយ ប៉ុន្តែកង្វះខាតចំណីអាហារ ក៏ដូចជាការស្លាប់ គឺវាមានកាន់តែធ្ងន់ឡើង។ ក្មេងៗទាំងអស់ គឺទទួលរងនូវផលប៉ះពាល់ពីកង្វះអាហារូបត្ថម្ភ ហើយស្ថានភាពវាហាក់ដូចជាកាន់តែអាក្រក់ឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ"។

នៅទំព័រ២៧ នៅថ្ងៃទី១៤ ខែមីនា, មានលេខ 00898235 នៅក្នុងកថាខណ្ឌទី៣ គឺលោកសរសេរដូចតទៅនេះ "ភ្នាក់ងារសង្គ្រោះអន្តរជាតិបានធ្វើការប្រជុំអំពីបញ្ហាកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ"។

ហើយមួយទំព័របន្ទាប់គឺទំព័រ២៨ លោកនិយាយអំពីថ្ងៃ១៦ ខែមីនា "គឺមានផ្លែអនាថាជាច្រើន ហើយយើងព្យាយាមគេចមិនឲ្យជួបផ្លែ ប៉ុន្តែឥឡូវហ្នឹងគឺលែងមានផ្លែអនាថាទៀតហើយ បញ្ហាសំខាន់គឺដោយសារការអត់ឃ្លាន។ ព្រោះថាជនជាតិវៀតណាមហូបផ្លែ ដូច្នេះផ្លែឥឡូវហ្នឹងមានលក់នៅលើទីផ្សារ ជាជាងឲ្យវារត់ចោលអត់ប្រយោជន៍"។

[១១:១១:០០]

ហើយខ្ញុំសូមធ្វើការដកស្រង់ចំណុចមួយទៀត គឺទំព័រ៣២នៅខាងចុងបំផុតនៃទំព័រ៣២ គឺថ្ងៃទី២៤ ខែមីនា គឺលោកបាននិយាយអំពីគ្លីនិក កង្វះអាហារូបត្ថម្ភ គឺមានម្តាយ ស្ត្រីជាម្តាយប្រហែលជា១៥០០នាក់បានមកចូលរួម ហើយស្នើសុំឲ្យគ្រូពេទ្យព្យាលបាលកូនដែលខ្វះអាហារូបត្ថម្ភរបស់ពួកគាត់។ ហើយទំព័រ៣៣ គឺថ្ងៃដដែលនេះគឺលោកបាននិយាយនៅកថាខណ្ឌទី៣ថា ចំណីអាហារកាន់តែខ្វះខាត រដ្ឋាភិបាលបានបន្ថយនូវអត្រាបែងចែកស្រូវអង្ករ។

ហើយជាចុងក្រោយលោក ស្កេនប៊ីក នៅថ្ងៃទី២៧ ខែមីនា លោកបាននិយាយបន្តទៅទៀតថា "ខាងជើងភ្នំពេញគឺមានព័ត៌មានកាន់តែអាក្រក់ឡើង។ ទាហានដែលត្រូវបានដែលរបួស គឺបានជម្លៀសមកពីតំបន់ជុំវិញ ហើយបង្ហាញប្រាប់គេថាទាហានមានតែដើមចេកទេហូប អត់មានអ្វីហូបទេ មានតែដើមចេក ដើមល្ហុងប៉ុណ្ណោះហូប។ ហើយពួកគេនិយាយថា យើងស៊ីចំណីដូចជ្រូនអីចឹង"។

[១១:១២:២០]

ហើយនៅក្នុងកថាខណ្ឌដដែលលោកបាននិយាយថា "ពួកទាហានប៉ះបោរមួយចំនួនផ្តល់ស្រូវអង្ករឲ្យពួកគេហូប ហើយឲ្យពួកគេសម្រាកដើម្បីសម្រាកកម្លាំង"។

លោក ស្កេនប៊ីក ព័ត៌មានទាំងអស់ហ្នឹង គឺខ្ញុំរំឭកឲ្យលោកដើម្បីឲ្យនឹកឃើញ ហើយតើលោកអាចពន្យល់ប្រាប់បានទេថា នៅថ្ងៃនេះ ថាផលប៉ះពាល់នៃកង្វះចំណីអាហារ ហើយនិងកង្វះអាហារូបត្ថម្ភ តើលោកឃើញថាតើវាមានផលប៉ះពាល់អ្វីខ្លះនៅក្នុងខែមេសា ឆ្នាំ៧៥នោះ?

**ឆ៖** ជាដំបូងហេតុផលដែលថា ចំណីអាហារ ហើយនិងអាហារូបត្ថម្ភនានាគឺមានការខ្វះខាត។ បញ្ហាសំខាន់ គឺថាមិនមានការផ្គត់ផ្គង់មកទីក្រុងភ្នំពេញ។ ពួកខ្មែរក្រហម គឺថាគេអាចផ្តាច់ការផ្គត់ផ្គង់ស្បៀង បានន័យថាគឺគេជោគជ័យក្នុងការរារាំងមិនឲ្យមានការផ្គត់ផ្គង់ស្បៀងមកភ្នំពេញ។ គឺថាគេគ្រប់គ្រងទាំងផ្លូវគោកទាំងផ្លូវទឹក គឺទន្លេមេគង្គ។

ដូច្នេះហើយវាប្រាកដណាស់ថា អត់មានអ្វីអាចដឹកជញ្ជូនចូលមកភ្នំពេញបាន ហើយក៏អត់មាន

យន្តហោះទម្លាក់ចំណីអាហារ ម្ហូបអាហារនៅពេលនោះដែរ។ ដូច្នេះហើយនេះគឺជាហេតុផលសំខាន់មួយ។ ដូច្នេះខ្ញុំមិនយល់ថា ហេតុអ្វីបានជាលោក ឬក៏លោកមានចម្ងល់អ្វីច្រើនក្នុងចិត្តរបស់លោក ដែលលោកសួរថា ហេតុអីបានជាមិនមានចំណីអាហារគ្រប់គ្រាន់? យើងឃើញថាទីក្រុងភ្នំពេញមានប្រជាជនប្រហែលជា១លាន ទៅ២លាននាក់ឯណោះ។ ដូច្នេះវាប្រាកដហើយ គឺមិនមានចំណីអាហារគ្រប់គ្រាន់។

[១១:១៤:២៧]

**ស៖** តើមានហេតុផលដទៃទៀតដែរឬទេ ដែលថាហេតុអ្វីបានដោយសារមានជនភៀសខ្លួនច្រើនទើបឲ្យមានកង្វះអាហារ ឬក៏ឲ្យមានភាពអត់ឃ្លានហ្នឹងដែរឬទេ?

**ឆ៖** លោកសួរថាហេតុអ្វីបានមានជនភៀសខ្លួន? ឥឡូវខ្ញុំសួរថាហេតុអ្វីបានជាគេរត់គេចមកវិញ? ព្រោះថាខ្មែរក្រហម ព្រោះទាហានខ្មែរក្រហម ទើបពួកគាត់រត់គេច ព្រោះទាហានខ្មែរក្រហមចាប់ដណ្ដើមកាន់កាប់ដីរបស់គេ ទើបដូច្នេះ។ ហេតុដូច្នេះហើយទើបគេរត់ជាមួយកូនចៅរបស់ពួកគេ។ អាហ្នឹងហើយគឺជាផលទួលផលនៃសង្គ្រាម។ វាមិនមែនជាពិធីជប់លៀងផឹកតែ ជជែកកំសាន្តនោះទេ។ ប្រសិនបើលោកមើលត្រឡប់ទៅវិញ ទៅលើសង្គ្រាមប្រវត្តិសាស្ត្រនៃសង្គ្រាម គឺវាមានលក្ខណៈបែបនេះ។ គឺទាហានធ្វើបែបនេះ រាំងខ្ទប់ចំណោះអាហារ រាំងខ្ទប់ការផ្គត់ផ្គង់ស្បៀងអាហារ រាំងខ្ទប់ការផ្គត់ផ្គង់គ្រឿងសព្វាវុធ--

**ស៖** សូមទោសខ្ញុំសូមកាត់លោក។ តើលោកចង់និយាយថា មុនពេលដែលគេរាំងស្កាត់ការផ្គត់ផ្គង់ចំណីអាហារ គឺអត់មានបញ្ហាអត់ឃ្លាន កង្វះអាហាររូបត្ថម្ភមែនទេ?

[១១:១៦:៤៥]

**ឆ៖** គឺពិតហើយ។ ខ្ញុំចង់ប្រាប់លោកថា មិនមានអាហារគ្រប់គ្រាន់ មិនមានស្រូវអង្ករគ្រប់គ្រាន់។ ប៉ុន្តែមុនពេលដែលខ្មែរក្រហមគ្រប់គ្រងហ្នឹង គឺថាវាមានការផ្គត់ផ្គង់។ លោកអាចឃើញគ្រប់ទីកន្លែង វាជាការពិតជាក់ស្ដែងនោះ គឺ--

**ស៖** តើលោកៗ ស្ដេនបឺក តើលោកចង់និយាយអំពីជនភៀសខ្លួន ជនភៀសសឹកដែលរត់មកទីក្រុងភ្នំពេញហ្នឹង គឺដោយសារតែការទម្លាក់គ្រាប់បែកអាមេរិក ដោយសារការទម្លាក់គ្រប់បែកណាប៉ាល់ ឬមួយក៏យ៉ាងដូចម្ដេច?

**ឆ៖** បាទ ខ្ញុំអាចប្រាប់លោកបានថាខ្ញុំសម្ភាសជនភៀសសឹកជាច្រើន ហើយពួកគាត់មិននិយាយ

អំពីការទម្លាក់គ្រាប់បែកទេ។ គាត់និយាយអំពីការវាយប្រហារទៅលើដីធ្លី ទៅលើផ្ទះសម្បែងរបស់គាត់។ ប្រហែលជាមានការមិននឹកឃើញ ឬក៏ការមិនរំពឹក ប៉ុន្តែអ្វីដែលពួកគាត់និយាយភាគច្រើន គឺខ្មែរក្រហមនោះទេ។

**ស៖** អាចថាដោយសារតែលោកមិនបាននិយាយជាមួយនឹងជនភៀសខ្លួនដែលទទួលរងគ្រោះដោយសារការទម្លាក់គ្រប់បែក?

**ផ៖** តើឲ្យខ្ញុំធ្វើយ៉ាងម៉េច? តើខ្ញុំយ៉ាងម៉េចដឹងថាតើជនភៀសខ្លួនមួយណា ជាជនភៀសខ្លួនដោយសារគ្រាប់បែក ដោយសារខ្មែរក្រហម ដោយសារនេះ។

[១១:១៧:២៥]

**ស៖** បើអ៊ីចឹងហេតុអ្វីក៏លោកនិយាយថាពួកគាត់ភៀសខ្លួនដោយសារតែមានការគ្រប់គ្រងរបស់ពួកបះបោរ? ប្រហែលជាលោកអាចនិយាយជាមួយជនភៀសឲ្យបានច្រើន ទើបវាជាការត្រឹមត្រូវ។

**ផ៖** នេះជាការលើកឡើងសមស្របមួយដែរ ប៉ុន្តែវាជារឿងគួរឲ្យចង់សើច។

**ស៖** ហេតុអីបានលោកសើច?

**ផ៖** ព្រោះថាប្រជាជនគេចចេញពីការបះបោរ។

**ស៖** ដូច្នេះលោកចង់និយាយថា គ្មានជនភៀសខ្លួន ភៀសសឹកដោយសារគ្រាប់បែកទេ?

**ផ៖** បាទ ប្រហែលជាអាចខ្លះ ព្រោះថាប្រសិនបើយើងមិនគេចចេញពីផ្ទះ គឺនឹងមានការទម្លាក់គ្រាប់បែកស្លាប់។ ប៉ុន្តែខ្ញុំចង់និយាយថាគ្មានជនភៀសណាមួយនិយាយអំពីបញ្ហានេះទេ។

**ស៖** ប្រហែលជាដោយសារតែលោកមិនបាននិយាយជាមួយអ្នកដែលទទួលរងគ្រោះដោយសារតែគ្រាប់បែកអាមេរិកនោះហើយមើលទៅ?

[១១:១៨:២៣]

**ផ៖** ការពិតពួកគាត់រត់គេពីគ្រាប់បែក។ តើលោកចង់និយាយអ៊ីចឹង?

**ស៖** បាទ។

**ផ៖** បាទ តើលោកអានកន្លែងហ្នឹង បានព័ត៌មានពីកន្លែងណា?

**ស៖** គឺថាមានភស្តុតាងជាច្រើនលោក ស្តេនប៊ីក។ ប៉ុន្តែប្រហែលជាលោកមិនបានពិនិត្យមើលមើល៍ទៅ។

**ផ៖** *(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន យើងសង្កេតឃើញថាមេធាវី គាត់កំពុងតែព្យាយាមដណ្ដើមជជែកជាមួយសាក្សី។ ដូច្នេះគឺថាមេធាវីគួរតែទុកឱកាសឲ្យសាក្សីគាត់ឆ្លើយសិន ជាជាងការទៅដណ្ដើមជជែកគ្នាអ៊ីចឹង វាអត់ជាការត្រឹមត្រូវនោះទេ។

[១១:១៩:២២]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាននេះមិនមែនជាការជំទាស់នោះទេ។ ប៉ុន្តែខ្ញុំនឹងព្យាយាមធ្វើតាមការសង្កេតនេះ ប៉ុន្តែពេលខ្លះ សាក្សីក៏គាត់និយាយកាត់ខ្ញុំដែរ ប៉ុន្តែវាអត់បញ្ហានោះទេ។ បញ្ហាសំខាន់គឺខ្ញុំ ឥឡូវនេះខ្ញុំកំពុងតែប្រយ័ត្នទៅលើប្រធានបទមួយនេះផងដែរ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** គឺថាពាក់ព័ន្ធទៅនឹងជនភៀសសឹកដែលរត់ចេញពីការបំផ្លាញ ការទម្លាក់គ្រាប់បែកអាមេរិក តើលោកមានយោបល់អ្វីដែរ?

**លោក ស៊ីដនី ស្កេនប៊ឺក៖**

**ឆ៖** ប្រហែលជាមានជនភៀសខ្លួនបែបហ្នឹងមែន គឺជនភៀសខ្លួនដែលរត់គេចពីគ្រាប់បែក។ អាចថាពួកគាត់រត់គេចដើម្បីសុវត្ថិភាព។ ប្រសិនបើលោកមានភស្តុតាង ដែលថាការទម្លាក់គ្រាប់បែកហ្នឹងគឺជាហេតុផលដែលធ្វើឲ្យប្រជាជនភៀសសឹក អាហ្នឹងវាជារឿងត្រឹមត្រូវ។ លោកគួរតែបង្ហាញលោកបង្ហាញយើងមកថាភស្តុតាងហ្នឹងមានលក្ខណៈបែបណា? ព្រោះខ្ញុំអត់ដែលឃើញ។ ខ្ញុំជាអ្នកសារព័ត៌មាន។ ដូច្នេះខ្ញុំមិនមានហេតុផលអ្វីដែលសរសេរបែបនេះ។ ហើយខ្ញុំក៏មិនមានហេតុផលអ្វីដែលសរសេរឲ្យជាការកាន់ជើង ឬក៏ជាការគាំទ្រអ្វីនោះទេ។ អ្វីដែលខ្ញុំមើលឃើញម៉េច ខ្ញុំសរសេរបែបនេះនៅក្នុងអត្ថបទរបស់ខ្ញុំ។ ដូច្នេះហើយវាជាការមិនត្រឹមត្រូវទេដែលលោកនិយាយថា លោកមានភស្តុតាងហើយលោកមិនអាចបង្ហាញបាន។ ខ្ញុំបង្ហាញតែការពិតប៉ុណ្ណោះ។

[១១:២០:៥៣]

**ស៖** ដោយសារតែយើងពិភាក្សាអស់រយៈពេលយូរហើយ។ ឥឡូវនេះខ្ញុំថាចង់ទុកថ្ងៃស្អែក ប៉ុន្តែឥឡូវហ្នឹង យើងចាប់ផ្ដើមនិយាយអំពីបញ្ហានេះសិន។ ខ្ញុំគិតថាលោកហាក់ដូចជាគាំទ្រ ឬក៏លោកបង្ហាញលក្ខណៈជាការគាំទ្រអាមេរិកយ៉ាងខ្លាំង។ ដូច្នេះគឺបានន័យថា លោកកំពុងតែបង្ហាញឬក៏គាំទ្រនូវទស្សនៈរបស់ពួកអាមេរិកនៅកម្ពុជា។

**ឆ៖** លោកមេធាវី ខ្ញុំចង់ប្រាប់លោកអ៊ីចេះ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

សាក្សីកុំទាន់អាល់ឆ្លើយតប!

[១១:២១:៤៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំត្រូវតែជំទាស់ ព្រោះថាមេធាវី គាត់ធ្វើការចោទប្រកាន់ ធ្វើការបន្ទោសរិះគន់ទៅលើសាក្សី រិះគន់ទៅលើការងាររបស់សាក្សី។ ហើយសាក្សីខ្លួនគាត់ក៏បានបង្ហាញច្បាស់ថា ព័ត៌មានប្រសិនបើមានគួរតែយកមកឲ្យគាត់ឃើញ ដើម្បីឲ្យគាត់បញ្ចេញមតិយោបល់ ជាជាងការចោទប្រកាន់ដូចដែលមេធាវីបានធ្វើទាក់ទងនឹងសក្ខីកម្ម។ ដូច្នេះការដែលមេធាវីធ្វើ វាជាការមិនសមស្របនៅចំពោះមុខអង្គជំនុំជម្រះឡើយ លោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន យើងសង្កេតឃើញថាឥឡូវនេះ យើងមានសាក្សីដែលមិនខ្លាច មិនប៉ានិយាយអ្វីនោះឡើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូច្នេះហើយ ខ្ញុំនឹងព្យាយាមនិយាយឲ្យបានយុត្តិ -- ឲ្យបានអព្យាក្រឹតបន្តិច គឺថាខ្ញុំមិនជាការរិះគន់អ្វីទៅលើរបាយការណ៍របស់លោកណាស់ណានោះទេ។

[១១:២២:៣៨]

**លោក ស៊ីដនី ស្កេនប៊ឹក៖**

**ឆ៖** លោកត្រូវតែនិយាយឲ្យបានច្បាស់ ថាតើការរិះគន់យ៉ាងម៉េច?

**ស៖** គឺការរិះគន់អំពីរបាយការណ៍ដែលថាលោករាយការណ៍កាន់ជើងតែម្ខាង គឺកាន់ជើងទៅ

លើគោលជំហររបស់អាមេរិកនៅក្នុងប្រទេសកម្ពុជា គឺលោកហាក់ដូចជាគាំទ្រយ៉ាងខ្លាំង ហើយលោកព្យាយាមមិនលើកនិយាយអំពីបញ្ហាខ្មែរក្រហម អំពីគោលជំហររបស់ខ្មែរក្រហម។

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមជំទាស់។

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរបែបនេះទេ។ សំណួរក្រៅអង្គហេតុ មិនពាក់ព័ន្ធទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការ។ សំណួរធ្វើឱ្យសាក្សីមិនមានជំនឿចិត្តដោយបង្ហាញអំពីភាពមិនជឿជាក់ទៅលើសាក្សីក្នុងការតាំងសំណួរបែបនេះ។ អង្គជំនុំជម្រះមិនអនុញ្ញាតទេ។ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរបែបនេះដែលសួរដោយមេធាវីរូបនេះ ឬក៏ភាគីដទៃទៀតនោះទេ។

[១១:២៣:៤៧]

មេធាវីរៀបចំនឹងសំណួរឱ្យបានត្រឹមត្រូវ ឱ្យបានច្បាស់លាស់ ឱ្យល្អ ឱ្យតាមវិធានដែលយើងបានកំណត់រួចហើយ នៅក្នុងសំណួរទាំងប៉ុន្មានដែលអាចសួរដេញដោលបាន ហើយនិងសំណួរទាំងឡាយដែលអង្គជំនុំជម្រះបានហាមមិនឱ្យប្រើប្រាស់ក្នុងការសួរដេញដោលនៅក្នុងតុលាការនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ យើង--

**ប្រធានអង្គជំនុំ៖**

សម្រាកបន្តិចសិន យើងពិភាក្សាគ្នាបន្តិច!

[១១:២៤:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២៥:៥១]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះផ្ដល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីបញ្ជាក់បន្ថែមនូវរបៀបនៃការតាំងសំណួរដោយមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា ចំពោះសាក្សី។

សូមអញ្ជើញលោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៌៖**

សូមអរគុណលោកប្រធាន។ ជាផ្អែកទៅលើការសម្រេចរបស់លោកប្រធាន មេធាវីការពារក្តី នួន ជា គឺមានសិទ្ធិសួរដេញដោលទៅលើសាក្សីរូបនេះ អំពីតុល្យភាពនៃរបាយការណ៍របស់គាត់ដើម្បីស្វែងរកភាពត្រឹមត្រូវ។ ប៉ុន្តែគាត់មិនអាចធ្វើការដេញដោលដោយទាំងដុលៗទៅលើអ្វីដែលគាត់បាននិយាយនោះទេ។ គឺថាត្រូវតែលើកឡើងនៅការបញ្ជាក់ឲ្យបានច្បាស់លាស់ ហើយសាក្សីក៏គាត់អាចផ្តល់នូវព័ត៌មានលម្អិត។ ដូច្នេះលោក កូប៉េ ដូច្នេះប្រសិនបើលោកចង់សួរសំណួរបែបនេះ សូមលោកសួរឲ្យបានជាក់ច្បាស់។

[១១:២៦:៥៧]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណចៅក្រម ខាតវ៉ាយថ៌។ ខ្ញុំយល់ថានេះគឺជាប្រធានបទដែលខ្ញុំចង់លើកឡើងនៅថ្ងៃស្អែកដើម្បីឲ្យបានលម្អិតទេ។ ដោយនិយាយអំពីការរិះគន់ ប៉ុន្តែខ្ញុំគិតថា ដោយសារតែមានការជជែកគ្នាទៅខ្ញុំហាក់ដូចជារៀងជ្រុលបន្តិច។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោក ស្តេនប៊ឺក ឥឡូវនេះ ខ្ញុំនឹងបន្តទៅថ្ងៃ១៧ មេសា ហើយនិងអ្វីៗដែលលោកបានសង្កេតឃើញនៅថ្ងៃ១៧ មេសា នោះ។ នៅទំព័រ៩១ នៃកំណត់ត្រារបស់លោក លោកបានសរសេរដូចតទៅនេះ៖

[១១:២៧:៤៩]

គឺនៅទំព័រកណ្តាលខ្មែរមានលេខ 00898299 គឺថា "បេកឃ័រ បានរាយការណ៍បន្ថែមទៀតថា ទីក្រុង គឺមានលក្ខណៈទទេស្អាត ហើយត្រូវបានគេលួច ហើយមានការបាញ់ផ្តោងខ្លះ។ គាត់បានមិនមានឃើញការវាយប្រយុទ្ធគ្នារវាងទាហានខ្មែរក្រហមជាមួយនោះទេ ប៉ុន្តែទាហាន -- ប៉ុន្តែប្រជាជនខ្មែរក្រហមមួយចំនួនប្រាប់ថា វាមានការបែងចែកតំបន់នៅក្នុងទីក្រុង"។ តើលោកចាំទេថា លោកបានជួបពិភាក្សាបែបនេះ?

**លោក ស៊ីដនី ស្តេនប៊ឺក៖**

**ឆ៖** បាទ។

**ស៖** តើលោកអាចពន្យល់បន្ថែមបានទៀតទេអំពីការសន្ទនានេះ។ ថាតើលោកមានន័យយ៉ាង

ម៉េចដែរថា គេធ្វើការបែងចែក ឬក៏ខណ្ឌចែកជាតំបន់នៅក្នុងទីក្រុងភ្នំពេញ?

**ឆ៖** បាទ ប្រសិនបើខ្ញុំចង់នេះ ទាល់តែខ្ញុំបើកមើលសៀវភៅកំណត់ត្រារបស់ខ្ញុំវិញ ឬក៏លោកអាចសួរគាត់បានច្បាស់ ថាតើគាត់និយាយបានន័យ -- មានន័យថាម៉េច? ប៉ុន្តែអ្វីដែលសោកស្ដាយ គឺខ្ញុំអត់មានសៀវភៅកំណត់ត្រារបស់ខ្ញុំនៅពេលនេះទេ។ ដូច្នេះខ្ញុំមិនអាចឆ្លើយប្រាប់លោកឲ្យបានច្បាស់នៅពេលនេះទេ។

**ស៖** តើលោកចាំថា មានប្រភពដទៃទៀតនិយាយអំពីអាកប្បកិរិយាផ្សេងៗគ្នា អាកប្បកិរិយាខុសៗគ្នារបស់ក្រុមបះបោរដែលមកពីក្រុមផ្សេងៗគ្នាចូលទៅក្នុងទីក្រុងភ្នំពេញនៅតាមតំបន់ផ្សេងៗគ្នា។ តើលោកធ្លាប់ឮដែរឬទេ?

[១១:២៩:៣១]

**ឆ៖** ខ្ញុំគិតថានៅពេលដែលទាហានចូលមកទីក្រុង គឺចូលមកទីក្រុងភ្នំពេញនោះ ទាហានរបស់លោក នួន ជា គឺជាយុវជនក្មេងៗ គឺដូចជាទាហានថ្មីៗ មើលទៅគឺហាក់ដូចជាមិនមានទាហានដែលមានបទពិសោធន៍ដែលមានការបណ្ដុះបណ្ដាលខ្ពស់អ្វីនោះទេ។ គឺមើលទៅហាក់ដូចជាទាហានដែលគេជួល ឬក៏ទាហានដែលទើបនឹងរើសថ្មីៗ។ ប៉ុន្តែយ៉ាងណាក៏ដោយខ្ញុំមើលទៅ ខ្ញុំមិនភ្ញាក់ផ្អើលអីនោះទេ។

**ស៖** តើលោកអាចនិយាយឲ្យបានច្បាស់ដែរឬទេ? តើលោកធ្លាប់ឮគេនិយាយអំពីវិន័យ ឬក៏អំពីអាកប្បកិរិយា ឧទាហរណ៍ទាហានមកពីខាងបូព៌ាយ៉ាងម៉េច? ខាងភាគខាងពាយ័ព្យ ឬក៏អីយ៉ាងម៉េចដែរ?

**ឆ៖** បើតាមដែលខ្ញុំដឹង គឺថានៅក្នុងពេលមានសង្គ្រាម គឺខាងកុម្មុយនីស្ដបានជម្លៀសប្រជាជនពីខាងបូព៌ា គឺនៅក្បែរព្រំដែនវៀតណាម ហើយជម្លៀសពួកគាត់ទៅខាងបស្ចិម គឺទៅខាងជិតព្រំដែនថៃ។ ហើយនេះគឺជាផែនការមួយដែលពួកគេធ្វើឡើង ប៉ុន្តែមិនមានការពន្យល់លម្អិតនោះឡើយ។ ព្រោះថាគេហាក់ដូចជាមិនសូវស្និទ្ធស្នាល ជិតស្និទ្ធជាមួយវៀតណាម។

[១១:៣១:៣២]

ហើយ ហ៊ុន សែន ដែលឥឡូវនេះ ជានាយករដ្ឋមន្ត្រីប្រទេសកម្ពុជា គឺជាអ្នកតវ៉ាមួយរូបប្រឆាំងទៅនឹងការគ្រប់គ្រង ក៏ដូចជាការដាក់ទណ្ឌកម្មរបស់ពួកខ្មែរក្រហមនៅក្នុងតំបន់នោះផងដែរ គឺដាក់ទាន់កម្មទៅលើប្រជាជនខ្លួនឯងផ្ទាល់នោះ។ ដូច្នេះហើយ វាគឺជាហេតុផលមួយដែលថាការធ្វើទុំងមានលក្ខណៈព្រៃផ្សៃ។

**ស៖** នៅពេលដែលលោកសរសេរនៅក្នុងកំណត់ត្រាៗរបស់លោកហ្នឹង នៅក្នុងចន្លោះឆ្នាំ -- ចន្លោះថ្ងៃ១៧ មេសា និងមុនហ្នឹងបន្តិចបន្តួចហ្នឹង តើលោកដឹងដែរឬទេថា តើមានអ្នកណាខ្លះ ឬក៏ដឹងឈ្មោះមេបញ្ជាការខ្មែរក្រហមណាខ្លះដែរឬទេ? គឺឈ្មោះមេបញ្ជាការដែលដឹកនាំពួកបះបោរចូលមករំដោះទីក្រុងភ្នំពេញនោះ?

**ឆ៖** ខ្ញុំដឹងអត់ដឹងទេ ខ្ញុំអត់ដែលស្គាល់ឈ្មោះពួកឧត្តមសេនីយ៍ ឬក៏ពួកអ្នកដែលដឹកនាំការវាយរំដោះនោះទេ។ ខ្ញុំអត់ដឹងថា ពួកគេជាអ្នកណានោះទេ។

[១១:៣២:៥៨]

**ស៖** តើលោកចាំដែរឬទេ? តើលោកដឹងដែរឬទេ? តើមន្ត្រីយោធា ឬក៏អនុសេនានុព័ន្ធយោធារបស់អាមេរិក ឬក៏បុគ្គលិកអាមេរិកធ្លាប់និយាយអំពីឈ្មោះមេបញ្ជាការកងកម្លាំងដែលចូលមករំដោះភ្នំពេញនោះដែរឬទេ?

**ឆ៖** អត់ទេ។ ខ្ញុំមិនដែលជជែកជាមួយនឹងមន្ត្រីយោធា ឬក៏ពួកអ្នកដឹកនាំយោធាអ្វីណានោះទេ។

**ស៖** នៅពេលដែលលោកស្នាក់នៅទូតបារាំង តើលោកធ្លាប់ឮអំពីភាពខុសគ្នា ឬក៏អំពីការស្លាប់ ឬក៏អំពីហេតុហេតុការណ៍លួចឆក់ប្លន់ ដែលខុសប្លែកគ្នាពីមួយតំបន់ទៅមួយតំបន់នៅក្នុងទីក្រុងភ្នំពេញ។ ឧទាហរណ៍ថា មានការលួចឆក់ប្លន់ ឬក៏មានគ្រោះថ្នាក់ច្រើនជាងនៅក្នុងតំបន់មេគង្គ ឬក៏នៅខាងត្បូងភ្នំពេញ ឬក៏នៅតំបន់ព្រលានយន្តហោះអីជាដើមនេះ។ តើវាមានលក្ខណៈយ៉ាងម៉េចដែរ?

[១១:៣៣:៥០]

**ឆ៖** ខ្ញុំមិនដែលឮរឿងរ៉ាវបែបនេះទេ។ ខ្ញុំឮថា មានការលួចឆក់ប្លន់ ប៉ុន្តែខ្ញុំមិនដែលឮថា អត់មានការបែងចែក ឬក៏ការ -- អ្វីដែលខ្ញុំដឹង គឺថាមានការលួចឆក់ប្លន់ ព្រោះថាយើងបានឆ្លងកាត់ទីក្រុងនៅពេលដែលយើងជិះរថយន្តឆ្លងកាត់ទីក្រុងហ្នឹង យើងឃើញៗអំពីការឆក់ប្លន់ អំពីការលួច ប៉ុន្តែនៅថ្ងៃទី១ នៅពេលដែលគេដោះលែងយើង នៅពេលដែលខ្មែរក្រហមដោះលែងយើងៗដើរចេញពីកន្លែងដែលគេឃុំខ្លួនយើង ហើយយើងដើរមកថ្នល់ ហើយពួកទាហានខ្មែរក្រហមហ្នឹង គេប្រគល់អីវ៉ាន់មួយចំនួនមកឲ្យយើងវិញ។ ហើយមនុស្សមួយចំនួនគេបង្ហាញខ្លួនឡើង ហើយគេហុចដបកូកាកូឡា ឬក៏ប៊ិបស៊ីកូឡាមួយដបមកឲ្យពួកយើង។ ខ្ញុំគិតថា វាជាការស្វាគមន៍ ឬក៏ជាការ -- ហើយគេហុចឲ្យយើង ហើយគេទាញទៅវិញ ហើយគេសើច។ ដូច្នេះ វាមិនមានអ្វីជាលក្ខណៈនោះទេ។ ខ្ញុំមិនមានជំនាញអ្វី ឬក៏លក្ខណៈអ្វីពិសេស ប្រហែលជាលោកអាចប្រាប់យើងបន្ថែមអំពីភាពខុសភាពគ្នា ឬក៏អំពីតំបន់ខុសគ្នា

របស់ពួកទាហានដែលទាហានហ្នឹង គេធ្វើអំពើល្អជាដើមអី។

**ស៖** ខ្ញុំគិតថា វាជាការសមស្របដែលយើងអាចបញ្ចប់នូវប្រធានបទនេះ គឺថាលោកមិនបានឃើញនៅក្នុងថ្ងៃ នៅក្នុងហេតុការណ៍ទាំងអស់នោះ គឺនៅថ្ងៃ១៧ មេសា ៧៥ ហ្នឹងគឺលោកនៅខាងក្រៅ ឬក៏បន្ទាប់ពីលោកបាន ត្រូវបានគេជម្លៀសទៅប្រទេសថៃ គឺលោកឃើញតាមផ្លូវ។ គឺលោកឃើញតែប៉ុណ្ណឹងទេឬ នៅពេលដែលធ្វើដំណើរ?

[១១:៣៦:២១]

**ឆ៖** បាទ គឺខ្ញុំមិនបានឃើញអ្វីជាលក្ខណៈអរិជ្ជមាននោះទេ។ នៅពេលដើម -- នៅពេលដំបូង យើងឃើញមានសាកសពនៅតាមផ្លូវ ប៉ុន្តែប្រហែលនៅពេលក្រោយមក វាមានលក្ខណៈយ៉ាងដូចម្តេចអាចថាទាហានខ្មែរ ឬក៏ជាជនស៊ីវិល ប៉ុន្តែឃើញសាកសពពួកគេនៅតាមផ្លូវ។ ប៉ុន្តែនៅពេលដែលយើងធ្វើដំណើរតាមក្បួន គឺពួកគេមិនមានធ្វើបាបអីយើងទេ គេចែក គេផ្តល់អាហារឲ្យយើង។ អត់មានអ្នកណាស្រែក អត់មានអ្នកណាសម្លុត អត់មានអ្នកណាធ្វើអ្វីធ្ងន់ធ្ងរចំពោះពួកយើងទេ។ ហើយយើងធ្វើដំណើរប្រហែលជា៣ថ្ងៃ។ ខ្ញុំឃើញមានក្រុមកុម្មុយនីស្តរបស់ខ្មែរក្រហម ហើយមានការរៀបចំផ្លូវ ឬក៏មានការធ្វើផ្លូវដោយអត់មានផែនទីបង្ហាញផ្លូវហ្នឹងទេ ប៉ុន្តែវាដូចជាផ្លូវធ្វើថ្មី។ ដូច្នេះ និយាយខ្លីគឺថាអត់មានអ្នកណាធ្វើអាក្រក់អីដាក់ពួកយើងទេ។ បើនិយាយតាមពិតទៅ មានអ្នកខ្លះគាត់ខឹងជាមួយអ្នកសារព័ត៌មាន ហើយគេហៅពួកយើងថាណាហ្ស៊ី។ គេ--

**ប្រធានអង្គជំនុំ៖**

អរគុណសាក្សី។

បាទ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយ និងសាមសិបនាទីរសៀលនេះ អញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយសវនាការនៅរសៀលនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មអ្នកជំនាញដែលមានរហស្សនាម -- អ្នកជំនាញដែលមានរហស្សនាម TCE-12 ដែលនឹងសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីពីរក្រុមទៀត។

[១១:៣៨:៤៣]

ឯសវនាការស្តាប់សក្ខីកម្មសាក្សី ស៊ីដនី ស្កេនប៊ឺក ផ្អាកត្រឹមនេះសិន។ សវនាការស្តាប់សក្ខីកម្ម

សាក្សី ស៊ីដនី ស្កេនប៊ឹក នឹងបន្តធ្វើនៅព្រឹកថ្ងៃស្អែក ថ្ងៃសុក្រ ទី០៧ ខែមិថុនា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបី និងសាមសិបនាទីព្រឹក ម៉ោងនៅកម្ពុជា។

លោក ស៊ីដនី ស្កេនប៊ឹក សវនាការស្តាប់សក្ខីកម្មរបស់លោកដល់ពេលនេះ ត្រូវផ្អាកសិន ហើយការស្តាប់សក្ខីកម្មរបស់លោកនឹងបន្តនៅព្រឹកថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោកបន្តផ្តល់សក្ខីកម្មតាមមធ្យោបាយសោតទស្សន៍ពីទីក្រុងញូវយ៉កនៅថ្ងៃស្អែកទៀត។ ពេលវេលានឹងចាប់ផ្តើមដូចនឹងថ្ងៃនេះ គឺត្រូវនឹងម៉ោងប្រាំបី និងសាមសិបនាទីព្រឹក ម៉ោងនៅកម្ពុជា។

លោក ស្កេនប៊ឹក ស្តាប់បានទេ?

**លោក ស៊ីដនី ស្កេនប៊ឹក៖**

បាទសូមអរគុណលោកប្រធាន។ ខ្ញុំស្តាប់បាន។ ខ្ញុំច្បាស់ហើយ ហើយខ្ញុំនឹងមករង់ចាំជួបលោកប្រធាននៅថ្ងៃស្អែក នៅទីនេះទៀត។

[១១:៣៩:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមជម្រាបលា លោក ស្កេនប៊ឹក។

អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់សម្រាកនៅខាងក្រោម ហើយបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលារសៀលឲ្យមុនម៉ោងមួយ និងសាមសិបនាទី!

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៤០ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនៅថ្ងៃនេះ នៅរសៀលនេះ

អង្គជំនុំជម្រះបន្តសវនាការស្តាប់សក្ខីកម្មអ្នកជំនាញ សុធារ៉ា ដែលនឹងបន្តដោយតំណាងសហព្រះរាជអាជ្ញាដែលមានរយៈពេល២០នាទី។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះប្រគល់វេទិកាជូន!

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។

[១៣:៣១:៥១]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** លោក ឈឹម សុធារ៉ា ខ្ញុំនឹងសួរសំណួរលោកក្នុងរយៈពេល២០នាទី ហើយខ្ញុំនឹងត្រឡប់មកនិយាយអំពីប្រធានបទពីរ។ ទី១ គឺពាក់ព័ន្ធនឹងសមត្ថភាព និងគុណវុឌ្ឍិរបស់លោក។ ទី២ គឺជាសំណួរស៊ីជម្រៅពាក់ព័ន្ធទៅនឹងការអនុវត្តរបស់លោកជាមួយនឹងជនរងគ្រោះខ្មែរក្រហម។ ខ្ញុំចង់និយាយឥឡូវនេះអំពីគុណវុឌ្ឍិរបស់លោក ហើយចង់ឲ្យលោកធ្វើការសង្ខេបតូចមួយ ដែលចេញ -- គឺនូវអ្វីដែលលោកបានផ្តល់សក្ខីកម្មកាលពីឆ្នាំ២០០៩។ ហើយប្រសិនបើមានការខុសឆ្គងអីនោះ សូមឲ្យលោកកែលម្អខ្ញុំ។

ខ្ញុំដឹងថាលោកជាគ្រូពេទ្យវះកាត់តាំងពីឆ្នាំ៩២។ បន្ទាប់មកទៀតលោកជំនាញខាងវិកលវិទ្យា។ លោកទទួលបានសញ្ញាបត្រនៅឆ្នាំ៩៨ មកពីទីក្រុងអូស្លូ។ បន្ទាប់មកលោកសិក្សាជាន់ខ្ពស់នៅឆ្នាំ៩៩ នៅអូស្ត្រាលី រយៈពេល១៨ខែ ហើយលោកបញ្ចប់វេជ្ជបណ្ឌិតខាងវិកលវិទ្យានៅសាកលវិទ្យាល័យម៉ូណាស់នៅម៉ែលប៊ន ហើយលោកធ្វើជាគ្រូពេទ្យខាងវិកលវិទ្យានេះអស់រយៈពេល១៩មកហើយ។ ហើយមួយទៀតនោះ លោកគឺជាប្រធានអង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជាហ្នឹងគឺថាអស់រយៈពេលប្រហែលជា១១ឆ្នាំមកហើយ។ តើការសង្ខេបនេះគឺត្រឹមត្រូវដែរឬទេលោក?

[១៣:៣៣:៣៣]

**លោក ឈឹម សុធារ៉ា៖**

**ឆ៖** បាទ ខ្ញុំជាទូទៅត្រឹមត្រូវ ប៉ុន្តែខ្ញុំសូមកែចំណុចនូវការទទួលសញ្ញាបត្រខាងឯកទេសវិកលវិទ្យាហ្នឹងគឺមិនមែនពីសាកលវិទ្យាអូស្លូទេ គឺជា *ប្រូក្រាម* ដែលរួមគ្នារវាងសាកលវិទ្យាល័យអូស្លូនៅ

ប្រទេសន័រវែស និងសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលនៅកម្ពុជា បាទអាហ្នឹងទី១។ ទី២ មិនមែនសញ្ញាបត្រវេជ្ជបណ្ឌិតនៅសាកលវិទ្យាល័យម៉ូណាស់ទេ គឺខ្ញុំធ្វើជាបណ្ឌិតទស្សនវិជ្ជាខាងផ្នែកសុខភាពផ្លូវចិត្ត ភី.អេច.ឌី – *ត្រេនស្កាល់ឆឺរ៉ល សាយខាយទ្រីស (តាមសូរស័ព្ទ)* នៅសាលវិទ្យាល័យម៉ូណាស។ ហើយឥឡូវហ្នឹងខ្ញុំនៅដំណាក់កាលចុងក្រោយ ខ្ញុំមិនទាន់ចប់ទេ។ សូមអរគុណ។

**ស៖** បាទ សូមអរគុណចំពោះការកែតម្រូវនេះ។ លោកបានបញ្ជាក់ថា ធី.ភី.អូ បង្កើតឡើងនៅឆ្នាំ៩៤ ហើយនៅឆ្នាំ២០០៩ នៅចំពោះមុខតុលាការនេះ លោកថា កម្មវិធីរបស់ ធី.ភី.អូ នេះគឺថាបំពេញទៅនឹងតម្រូវការផ្នែកចិត្តសាស្ត្ររបស់ប្រជាជនកម្ពុជា ដែលទទួលរងឥទ្ធិពលចិត្តសង្គម និងចិត្តសាស្ត្រនៃរបបខ្មែរក្រហម។ ជាពិសេសនោះគឺពាក់ព័ន្ធទៅនឹងរោគសញ្ញានៃវិបត្តិផ្លូវចិត្តក្រោយការប៉ះទង្គិច។

[១៣:៣៥:០១]

លោកបញ្ជាក់ថា ធី.ភី.អូ មិនមែនតែនៅភ្នំពេញទេ គឺថាអាចជួយទៅដល់អ្នកដែលទទួលរងនូវការប៉ះទង្គិចផ្លូវចិត្ត ក៏ដូចជាជនរងគ្រោះផ្សេងៗទៀតដែលរស់នៅតាមមូលដ្ឋានផ្សេងៗនៅក្នុងប្រទេសកម្ពុជា។ តើការសង្ខេបនេះត្រឹមត្រូវដែរឬទេលោក?

**ឆ៖** បាទ ពិតជាត្រឹមត្រូវ។

**ស៖** ខ្ញុំដឹងថាលោកជាមនុស្សដាក់ខ្លួនណាស់។ ក៏ប៉ុន្តែយើងអាចនិយាយបានទេថានៅកម្ពុជានោះគឺថាលោកគឺជាគ្រូពេទ្យខាងវិកលវិទ្យា មានបទពិសោធន៍ខ្ពស់ជាងគេ ជាពិសេសពាក់ព័ន្ធទៅនឹងវិបត្តិផ្លូវចិត្តរបស់ជនរងគ្រោះ ដែលនៅក្នុងរបបខ្មែរក្រហម។ តើខ្ញុំអាចនិយាយអ៊ីចឹងបានទេ?

**ឆ៖** ខ្ញុំគិតថាលោកអាចនិយាយបានបាទ។

[១៣:៣៦:០២]

**ស៖** តើលោកអាចប្រាប់អំពីសមមាត្រនៃការងាររបស់លោកជាគ្រូពេទ្យវិកលវិទ្យា ហើយនិងជានាយកអង្គការ ធី.ភី.អូ គឺមានន័យថាជាការព្យាបាល ហើយនិងការត្រួតពិនិត្យទៅលើសកម្មភាពជួយដល់ការព្យាបាលផ្លូវចិត្តរបស់ជនរងគ្រោះរបបខ្មែរក្រហម។ តើនេះជាកិច្ចការប្រចាំថ្ងៃរបស់លោកអ៊ីចឹងមែនទេ?

**ឆ៖** បាទ ចំពោះការងារប្រចាំថ្ងៃគឺប្រហែលជា៥០ភាគរយទៅលើការងារគ្រប់គ្រង ប្រហែល៣០ភាគរយទៅលើការងារ ប្រហែលជា២០ភាគរយលើការងារស្រាវជ្រាវ ការងារគ្លីនិក។ បូកសរុបទៅទាំងបីហ្នឹង ការងារគ្លីនិក ស្រាវជ្រាវនិងការបណ្តុះបណ្តាលហ្នឹងគឺប្រហែលជា៥០ភាគរយដែរបាទ។

**ស៖** សូមអរគុណ។ នៅក្នុងសំណុំរឿងមានអត្ថបទមួយដែលលោកសរសេរ ដែលមានលេខ E285.1.4។ ឯកសារនេះត្រូវបានចុះផ្សាយនៅក្នុង *“ជើរណេល អូហ្វ អេហ្វ្រិកធីវ ឌីសអរឌ័រ”* ដែលមានចំណងជើងជាភាសាអង់គ្លេស *“ខូឡុន ប្រ៊ីហ្វ ឌីសអរឌ័រ”*--

**អ្នកបកប្រែ៖**

លោកប្រធាន សហព្រះរាជអាជ្ញាគាត់អានជាភាសាអង់គ្លេស អ្នកបកប្រែពិបាកក្នុងការតាមណាស់ លោកប្រធាន។

[១៣:៣៧:៥៦]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ឯកសារនេះគឺលេខ E285.1.4 អត្ថបទនេះគឺចុះផ្សាយនៅក្នុង *“ជើរណេល អូហ្វ អេហ្វ្រិកធីវ ឌីស-អរឌ័រ”* -- “ពាក់ព័ន្ធទៅនឹងជន ផលប៉ះពាល់ទៅនឹងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា”។ ក្រៅពីការសរសេរអត្ថបទនេះ តើលោកបានសរសេរ ហើយនិងការចូលរួមក្នុងការសរសេររួមអត្ថបទផ្សេងទៀតនៅក្នុងទស្សនាវដ្ដីអន្តរជាតិដែលមានជំនាញខ្ពស់ និងមានកេរ្តិ៍ឈ្មោះនៅក្នុង -- និងក៏ដូចជាសៀវភៅផងដែរនោះ។ តើមានទេ?

**លោក ឈឹម សុធារ៉ា៖**

**ឆ៖** បាទ មានបាទ។

**ស៖** នៅក្នុងអ៊ីនធឺណេត ខ្ញុំរកឃើញនូវអត្ថបទបោះពុម្ពផ្សាយពីរដែលមានចុះហត្ថលេខារបស់លោក។ ឯកសារហ្នឹងអត់មាននៅក្នុងសំណុំរឿងទេ។ ហើយសុំឲ្យលោកបញ្ជាក់អំពីអត្ថបទផ្សេងទៀតដែលលោកសរសេរ។ មានអត្ថបទមួយដែលលោកសរសេរតែម្នាក់ឯង ដែលចុះនៅក្នុងអ៊ីនធឺណេតនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ ដោយសាកលវិទ្យាល័យម៉ូណាស ដែលមានចំណងជើងថា “បាក់ស្បាត: ហើយនិង ត្រូម៉ា-បេស... អ៊ីន ខេមបូឌា”។ ដូច្នេះក្នុងអត្ថបទហ្នឹង គឺលោកនិយាយអំពីរោគសញ្ញារបស់ប្រជាជនកម្ពុជាដែលទទួលរងនូវការប៉ះទង្គិចផ្លូវចិត្ត។

[១៣:៣៩:៣២]

ហើយមួយទៀតហ្នឹងគឺនៅខែមិថុនា ឆ្នាំ២០០៨ នៅក្នុង *“ជើរណេល អូហ្វ ឡូស អេន ត្រូម៉ា”*។ អត្ថបទនោះមានចំណងជើងថា “ការចង់សងសឹក ហើយនិងឥរិយាបថរបស់កម្ពុជាមួយចំនួនចំពោះតុលាការ”។

ក្រៅពីអត្ថបទទាំងអស់នេះ តើមានអត្ថបទផ្សេងៗណាទៀតដែលលោកទើបតែបោះពុម្ពផ្សាយនាពេលថ្មីៗនេះទេ?

**ឆ៖** ត្រឹមត្រូវហើយ ហើយមានអត្ថបទមួយដែលខ្ញុំសរសេរហើយ ហើយទទួលស្គាល់ ទទួលយកនូវការបោះពុម្ពដោយ *ជីវណាល* មួយឈ្មោះថា “*សាយខាយទ្រីស សាយខូឡូជី អេន ឡ*” ហើយគេទើបតែទទួលស្គាល់នូវអត្ថបទហ្នឹងទេ ហើយប្រហែលជានឹងបោះផ្សាយនៅក្នុងពេលប្រហែលជា៦ខែទៀត។ អត្ថបទនោះមានន័យថា មានចំណងជើងថា “ជំងឺបាក់ស្បាត” ហៅថា “*ប្រូកខិន ខៅរេក*” ហ្នឹងជាបានន័យថាជា *ហ្វូរិនស៊ិក អេវីឌិន* – ជាភស្តុតាងកោសល្យវិច័យនៅក្នុងជនរងគ្រោះរបស់របបខ្មែរក្រហមនឹងឯង។ អ៊ីចឹងខ្ញុំចង់យកថា បាក់ស្បាតគឺជាភស្តុតាងខាងផ្នែកកោសល្យវិច័យមួយសម្រាប់វាយតម្លៃជនរងគ្រោះដោយរបបខ្មែរក្រហម។ ហើយត្រូវបានទទួលស្គាល់បោះពុម្ពហើយបាទ។ ហើយខ្ញុំបោះពុម្ពម្នាក់ឯង ឈរឈ្មោះម្នាក់ឯង។

[១៣:៤១:១២]

**ស៖** សូមអរគុណ។ នៅក្នុងសារព័ត៌មាននៅក្នុងឆ្នាំ២០១២ ហើយនៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ ធី.ភី.អូ ដែលយើងអាចរកឃើញនៅក្នុងអ៊ីនធឺណេត ខ្ញុំបានឃើញថា លោក និង ធី.ភី.អូ បានទទួលពានរង្វាន់សិទ្ធិមនុស្សនៅឆ្នាំ២០១២ ពីវិទ្យាស្ថានដើម្បីសិទ្ធិមនុស្សនិងយុត្តិធម៌អន្តរជាតិនៃសាកលវិទ្យាល័យហ្វូលហាំ ទីក្រុងញូវយ៉កសហរដ្ឋអាមេរិក ជាការទទួលស្គាល់ចំពោះការខិតខំប្រឹងប្រែងរបស់លោកក្នុងការលើកស្ទួយសិទ្ធិរបស់បុគ្គលដែលប៉ះពាល់ -- ដែលមានជំងឺផ្លូវចិត្ត។ តើក្រោយពីពានរង្វាន់នេះ តើលោកមានទទួលបានពានរង្វាន់អីផ្សេងទៀតទេ នៅក្នុងអាជីពការងាររបស់លោក?

**ឆ៖** អត់មានទេបាទ។

**ស៖** តើលោកបញ្ជាក់ថាអំមិញនេះលោកបញ្ជាក់ថា ទទួលបានតែពានរង្វាន់នឹងមួយទេ អត់មានពានរង្វាន់ផ្សេងទៀតទេ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំបានទទួលពានរង្វាន់ហ្នឹងពិតប្រាកដមែន ហើយមិនទាន់មានពានរង្វាន់អីផ្សេងទៀតទេបាទ។

**ស៖** សូមអរគុណ។ កាលពីម្សិលមិញ លោកនិយាយថាប្រជាជនកម្ពុជានៅបរទេសត្រូវបានព្យាបាលដោយសារជំងឺវិបត្តិផ្លូវចិត្តក៏ប៉ុន្តែមិនមានលទ្ធផលទេ។ តើគ្រូពេទ្យវិកលវិទ្យាដែលធ្វើការជាមួយនឹងជនរងគ្រោះកម្ពុជា ដូចជារូបលោកជាដើមនេះ ដែលយល់ច្បាស់អំពីភាសាខ្មែរ និងវប្បធម៌សាសនា

ឬក៏ស្គាល់អំពីរោគសញ្ញាបាក់ស្បាតដែលលោកនិយាយថាជា រោគសញ្ញាមួយដែលប្រហាក់ប្រហែល ក៏ប៉ុន្តែខុសពីវិបត្តិផ្លូវចិត្តក្រោយការប៉ះទង្គិចនោះ?

[១៣:៤៣:២០]

**ឆ៖** បាទ ពិតប្រាកដមែន ពីព្រោះគ្រូពេទ្យវេជ្ជបណ្ឌិតឯកទេសនៅប្រទេសលោកខាងលិច គាត់បានយល់ដឹងអំពីផ្នែក *បាយអូមេឌីខល* ផ្នែកវេជ្ជសាស្ត្រខាងពិតប្រាកដមែន ប៉ុន្តែវាមានផ្នែកប្រតិកម្មផ្លូវចិត្តតាមបែបលក្ខណៈវប្បធម៌ និងការបញ្ចេញនូវអារម្មណ៍តាមជាសារ – ការប្រើ *អ៊ីឌាម អូហ្វ ឌីស-ស្ត្រេស* – ភាសាអីជាដើមហ្នឹង គាត់មិនបានយល់ទេ។ ដូច្នេះជាការបាច់ដែលគាត់ត្រូវយល់ច្បាស់អំពីវប្បធម៌ *អ៊ីឌាម អូហ្វ ឌីសស្ត្រេស* របស់កម្ពុជាយើង។ ជាពិសេសទៀតបើសិនគាត់អាចធ្វើការជាមួយអ្នកជំនាញរបស់កម្ពុជាយើង ធ្វើឲ្យការព្យាបាលហ្នឹងនឹងមានប្រសិទ្ធិភាពខ្លាំងជាងមុន។ អ៊ីចឹងហើយបានជាអតិថិជនដែលខ្ញុំលើកម្សិលមិញហ្នឹងគឺ គាត់សម្រេចចូលរួមនៅក្នុងការព្យាបាលតាមបែបវប្បធម៌សាសនាដែលធ្វើឲ្យគាត់ហ្នឹងមានការធូរស្រាលលឿនបាទ។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅដល់ប្រធានបទផ្សេងទៀតដែលភ្ជាប់ទៅនឹងសំណួរដែលខ្ញុំសួរកាលពីម្សិលមិញ។ ខ្ញុំចង់ដឹងអំពីលក្ខណៈពិសេសនៃហេតុការណ៍ដែលធ្វើឲ្យមានការតក់ស្លុតរន្ធត់ ធៀបទៅនឹងបុគ្គលទទួលការប៉ះទង្គិចដោយសារហេតុការណ៍ធម្មតា។ ឧទាហរណ៍ដូចជាគ្រោះថ្នាក់ចរាចរណ៍ ការស្លាប់ ឬក៏ការបំពាន រំលោភបំពានជាដើមហ្នឹង។ អ៊ីចឹងខ្ញុំចង់ដឹងថា តើលក្ខណៈពិសេសខុសគ្នាយ៉ាងម៉េចរវាងអ្នកដែលទទួលរងនូវការប៉ះទង្គិចផ្លូវចិត្តដោយសាររបបខ្មែរក្រហម ហើយនិងអ្នកទទួលរងនូវការប៉ះទង្គិចដោយសារសកម្មភាពផ្សេងៗក្នុងជីវភាពប្រចាំថ្ងៃធម្មតានោះ?

[១៣:៤៥:២០]

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំបាទសូមបញ្ជាក់ថាមានលក្ខណៈពីរ។ ទី១ គេហៅថា "ស្ត្រេស"។ ស្ត្រេសហ្នឹងគឺជាព្រឹត្តិការណ៍តូចតាចបន្តិចបន្តួចជាការបម្រែបម្រួល ដែលយើងជួបប្រទះនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ ជម្លោះ ឃើញនេះឃើញនោះបន្តិចបន្តួច មានការប្រែប្រួលអីហ្នឹង បាត់ការងារធ្វើ ឬក៏ត្រូវគេស្តីបន្ទោស។ អាហ្នឹងគឺជាស្ត្រេសដែលស្ថិតនៅក្នុងកម្រិតមួយទាប ហើយមានលក្ខណៈបណ្តោះអាសន្ន ហើយវានឹងបាត់នៅក្នុងរយៈពេលឆាប់ទៅវិញ។ ចំណែកឯការប៉ះទង្គិចផ្លូវចិត្តធ្ងន់ មកពីត្រូម៉ាហ្នឹងគឺជានិយមន័យរបស់ ឌី.អេស.អឹម នៅក្នុងសៀវភៅដែលទទួលស្គាល់ដោយពិភពលោកហ្នឹងគឺថាគឺជាព្រឹត្តិការណ៍ដែលរន្ធត់ខ្លាំងដែលជាព្រឹត្តិការណ៍ហ្នឹងវាទាក់ទងទៅនឹងការគំរាមកំហែងដល់អាយុជីវិត។

[១៣:៤៦:១៦]

ទាក់ទងទៅនឹងការរបួសដល់រាងកាយ ទាក់ទងទៅនឹងដូចជាសង្គ្រាម ការធ្វើទារុណកម្ម។ និយាយទៅរឿងរ៉ាវណាដែលមិនមែនជារឿងរ៉ាវដែលធ្លាប់ជួបប្រចាំថ្ងៃ ហើយរឿងរ៉ាវទាំងអស់ហ្នឹង យើងអាចថាបុគ្គលអាចជួបផ្ទាល់តែម្តងខ្លួនឯងហ្នឹងរងនឹងបញ្ហាហ្នឹងតែម្តង ឬមួយក៏បានឃើញ ឬមួយក៏បានឮ។ ហើយក្រោយពីទទួលបាន ជួបប្រទះនូវព្រឹត្តិការណ៍ទាំងអស់ហ្នឹង បុគ្គលហ្នឹងគឺមានការរន្ធត់ខ្លាំងណាស់។ រន្ធត់ហ្នឹងគឺវាហួសហេតុ ដែលគាត់ ដែលធ្វើឲ្យគាត់ហ្នឹងសមត្ថភាពរបស់គាត់ហ្នឹងនៅក្នុងការដោះស្រាយនឹងបញ្ហាផ្សេងៗនៅក្នុងការគិត នៅក្នុងទំនាក់ទំនងអីហ្នឹង គឺវាមានការផ្លាស់ប្តូរហើយ។ អ៊ីចឹងខ្ញុំសូមលើកឧទាហរណ៍ថា ទារុណកម្ម ឬក៏ព្រឹត្តិការណ៍ផ្សេងៗដែលកើតមាននៅសម័យខ្មែរក្រហមហ្នឹងមិនមែនជាស្ត្រេសដែលយើងជួបនៅក្នុងការរស់នៅប្រចាំថ្ងៃទេ គឺជា*ត្រូម៉ាទិក អ៊ីវិន* ដែលមនុស្សយើងហ្នឹងកម្រជួបប្រទះ ហើយការជួបប្រទះនោះ វាធ្វើឲ្យមនុស្សហ្នឹងពិបាក បាត់បង់សមត្ថភាពនៅក្នុងការដោះស្រាយ ធ្វើឲ្យមនុស្សហ្នឹងមិនអាច*ខន់ត្រូល* ខ្លួនឯងបាន។

[១៣:៤៧:៤១]

**ស៖** តើការប្រឈមមុខទៅនឹងការប៉ះទង្គិចផ្លូវចិត្តជាបន្តបន្ទាប់គ្នាមកនោះ ក្នុងរយៈពេលមួយឧទាហរណ៍ដូចថាក្នុងរយៈពេល៣ឆ្នាំ គឺថាមិនមែនជាហេតុការណ៍ដែលកើតឡើងតែម្តងនោះទេ គឺថាវាមានការតបន្តគ្នារហូត ទទួលរងប៉ះទង្គិចតគ្នាមករហូត។ ដូច្នេះតើវាមានផលប៉ះពាល់អ្វីខ្លះចំពោះការដែលទទួលរងប៉ះទង្គិចផ្លូវចិត្តជាបន្តរហូតហ្នឹង បើធៀបទៅនឹងការប៉ះទង្គិចផ្លូវចិត្តតែនឹងហេតុការណ៍អ្វីដែលកើតឡើងតែមួយភ្លែតនោះ?

**ឆ៖** បាទ សូមអរគុណចំពោះសំណួរដ៏ល្អ។ ខ្ញុំសូមបញ្ជាក់ថា ភី.ធី.អេស.ឌី រោគសញ្ញាដែលបង្កើតដោយលោកខាងលិចនោះ គឺគេសម្រាប់ធ្វើរោគវិនិច្ឆ័យទៅលើជំងឺផ្លូវចិត្ត ដែលក្រោយពីជួបប្រទះនូវត្រូម៉ាតែម្តងទេ មិនបានជួបប្រទះនូវត្រូម៉ាដែល *រីភីតធីត*–ដដែលៗច្រើនដង ហើយក្នុងរយៈពេលយូរទេ។

អ៊ីចឹងហើយខ្ញុំធ្វើការសន្និដ្ឋាននៅក្នុងទ្រឹស្តីរបស់ខ្ញុំទាក់ទងនឹងជំងឺបាក់ស្បាត ថាដល់ពេលយើងប្រើ ភី.ធី.អេស.ឌី នៅក្នុងការវាស់វែងការឈឺចាប់ផ្លូវចិត្តរបស់ប្រជាជនខ្មែរដែលរងនូវព្រឹត្តិការណ៍ដដែលៗបន្តបន្ទាប់រយៈពេលយូរហ្នឹងគឺអាចវាស់វែងបានកម្រិតទាបទេ តូចទេ។ អ៊ីចឹងវាមានលក្ខណៈមួយចំនួនទៀតដែលមិនអាចយក ភី.ធី.អេស.ឌី យកមកវាស់វែងបាន ពីព្រោះលក្ខណៈដែលទាក់ទងនឹងវប្បធម៌

អីៗជាដើមហ្នឹង។ ហើយមានអ្នកចិត្តវិទ្យាពិភពលោកជាច្រើនដែលគេទទួលស្គាល់ថា ភី.ធី.អេស.ឌី មិនអាចទៅវាស់វែងអ្នកដែលមានជួបប្រទះ *ត្រូម៉ា -- រីភីតធីធីវ ត្រូម៉ា* ទេ ដូចជា *ជូឌីត ហ៊ើមិន* ជាដើម ហើយ *សែលវ៉ាន់ដេកុល* អីជាដើម។

អ៊ីចឹងខ្ញុំស្នើនូវប្រភេទជំងឺថ្មីមួយដែលខ្ញុំបានសិក្សាហ្នឹង ដែលហៅថា "ជំងឺបាក់ស្បាត" ដែលសមស្របតាមលក្ខណៈវប្បធម៌ហ្នឹង គឺខ្ញុំគិតថាជំងឺហ្នឹងអាចវាស់វែងទំហំនៃការឈឺចាប់របស់ប្រជាជនកម្ពុជាយើងបានច្រើនជាង ភី.ធី.អេស.ឌី។

[១៣:៥០:១៣]

**ស៖** សូមអរគុណ។ ដោយសារតែពេលវេលខ្លី ខ្ញុំសូមសួរលោកតែពីរសំណួរទៀតទេ។ ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីជាច្រើននៅក្នុងតុលាការនេះ ហើយនិងមាននៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់សហចៅក្រមស៊ើបអង្កេតផងដែរ ពួកគេគាត់ឆ្លើយថា "នៅក្នុងរបបខ្មែរក្រហមនោះ គាត់ទទួលរងនូវការជម្លៀសជាបន្តបន្ទាប់។ ឧទាហរណ៍ ជម្លៀសចេញពីភ្នំពេញទៅតាកែវ ហើយបន្ទាប់មកប៉ុន្មានខែក្រោយមកជម្លៀសបន្តទៅទៀតទៅតំបន់ ឧទាហរណ៍ទៅខេត្តបាត់ដំបង នៅជាដើមនោះ"។

ដូច្នេះ ខ្ញុំចង់ដឹងថា តើនៅពេលដែលមានការកាត់ផ្ដាច់ឫសគល់ជាបន្តបន្ទាប់បែបនេះនោះ តើមានផលប៉ះពាល់អ្វីខ្លះទៅលើជនរងគ្រោះនៅពេលដែលយើងជម្លៀសគាត់ដោយបង្ខំ ដោយមិនមានការយល់ព្រមពីពួកគាត់នោះ? ហើយគាត់ដឹងថា ខ្មែរក្រហមកុហកហើយ ឧទាហរណ៍ដូចថាឲ្យហេតុផលថា ជម្លៀសចេញតែ៣ថ្ងៃទេ ប៉ុន្តែតាមពិតពួកហ្នឹងកុហកទេ។ ហើយដូចជាអ្នកជម្លៀសទៅបាត់ដំបងអីអ៊ីចឹងជាដើម គេប្រាប់ថាជម្លៀសទៅខាងហ្នឹងទៅមានម្ហូបអាហារ មានចំណីអាហារច្រើន។ អ៊ីចឹងតើនៅពេលដែលទទួលរងនូវការភូតកុហក ហើយនៅពេលដែលពួកគាត់កាត់ផ្ដាច់ឫសគល់ខ្លួនទាំងស្រុងបែបនេះហ្នឹង តើពួកគាត់ទទួលរងនូវផលប៉ះពាល់យ៉ាងម៉េចខ្លះដែរ?

[១៣:៥១:៣៨]

**ឆ៖** បាទ ពួកខ្មែរក្រហមមានយុទ្ធសាស្ត្រមួយគឺចង់ធ្វើឲ្យប្រជាជនយើងហ្នឹង គឺបាត់បង់លំនឹង។ បាត់បង់នូវសមត្ថភាពនៅក្នុងការដោះស្រាយនូវបញ្ហា ក្នុងការតតាំង នៅក្នុងអីជាដើម។ អ៊ីចឹងយុទ្ធ-សាស្ត្រហ្នឹង វាធ្វើឲ្យប្រជាជនយើងហ្នឹងមានជំងឺបាក់ស្បាត។ អ៊ីចឹងបានខ្ញុំថា បាក់ស្បាតហ្នឹងគឺវាលើសពី ភី.ធី.អេស.ឌី។ អ៊ីចឹងមានជំងឺបាក់ស្បាត។ អ៊ីចឹងអាជំងឺបាក់ស្បាតហ្នឹងហើយដែលធ្វើឲ្យបងប្អូនយើងលែងហ៊ានតតាំងតែម្ដង។

យើងមើលសម័យឆ្នាំ៧៩ អំ! ៧៥ យើងស្ម័គ្រចិត្តចេញពីទីក្រុងដោយៗអត់មានតតាំងអីបន្តិចសោះ។ ស្រមៃមើលទីក្រុងបាងកក បើសិនជាគេបញ្ជូនមនុស្សឲ្យចេញ តើនឹងមានការណ៍នេះប៉ុន្មាន? អ៊ីចឹងការដែលបាក់ស្បាត ដែលប្រជាជនយើងបាក់ស្បាតអាសង្គ្រាមមុននឹងជាមួយខ្មែរក្រហម ហើយសម័យខ្មែរក្រហម។ អាការព្យាយាមខ្ញុំបំបាក់ស្មារតីជម្លៀសប្រជាជនពីមួយកន្លែងទៅមួយកន្លែង បង្ខំឲ្យធ្វើការទាំងយប់ទាំងថ្ងៃ អត់មានសម្រាក អត់មានបាយហូប។ អ៊ីចឹងវាធ្វើឲ្យប្រជាជនយើងបាក់តែម្តង។ អ៊ីចឹងការដែលបាក់ហ្នឹងហើយ ដែលធ្វើឲ្យប្រជាជនហ្នឹងមិនងាយនឹងងើបតតាំង។ អ៊ីចឹងហើយបានខ្ញុំគិតថា បាក់ស្បាតហ្នឹង គឺជាជំងឺមួយដែលល្អ ដែលរៀបរាប់អំពីការប៉ះទង្គិចផ្លូវចិត្ត ពីរបបខ្មែរក្រហមជាង ភី.ធី.អេស.ឌី ទៀត។

[១៣:៥៣:០៥]

**ស៖** បាទ សំណួរបន្តពីចម្លើយរបស់លោកពាក់ព័ន្ធទៅនឹងការភូតកុហករបស់ខ្មែរក្រហមគឺថា ទោះបីជាការពិត ឬក៏មិនពិតក៏ដោយ តើប្រជាជនមានអារម្មណ៍ថា ខ្មែរក្រហមភូតកុហក? អ៊ីចឹងតើវាមានឥទ្ធិពលទៅលើប្រជាជនយ៉ាងម៉េចខ្លះ នៅពេលដែលខ្លួនត្រូវបានគេកុហក ហើយទទួលរងនូវអារម្មណ៍មួយដែលថា ចេញពីមួយកន្លែងទៅមួយកន្លែងនោះគ្មានសុវត្ថិភាពនោះ?

**ឆ៖** សូមបញ្ជាក់ថា ដោយសារឥទ្ធិពលហ្នឹងហើយ ដែលធ្វើឲ្យពួកប្រជាជនយើងលែង -- បាត់បង់នៅទំនុកចិត្តគ្នា លែងសូវទុកចិត្តគ្នា។ លាក់នូវអត្តសញ្ញាណគ្នា មិននិយាយត្រង់ គឺមិនប៉ានបញ្ចេញពីព្រោះដោយសារមិនទុកចិត្តៗថាខ្លាច ដឹងថាគេនិយាយកុហកហ្នឹងហើយមិនទុកចិត្ត ពាក្យបាក់ស្មារតីបាក់ស្បាតហ្នឹងក៏ធ្វើឲ្យគាត់ហ្នឹងមិនទុកចិត្ត។ អ៊ីចឹងកត្តាទាំងអស់ហ្នឹងវាអាចទាក់ទងទៅនឹងរឿងរ៉ាវដែលកើតឡើង។

[១៣:៥៤:១១]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាននេះជាសំណួរចុងក្រោយហើយ ហើយមុននឹងសួរខ្ញុំសូមអរគុណដែលលោកអញ្ជើញមកឆ្លើយ --

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ជនរងគ្រោះបានឆ្លើយថា គេមិនចាត់ទុកពួកគាត់ជាមនុស្សទេនៅក្នុងរបបខ្មែរក្រហមនោះគឺដូចជាទាសករ ឬក៏ដូចជាសត្វធាតុ ហើយពួកគាត់រស់នៅហ្នឹងគឺដាក់ក្នុងគុកឥតជញ្ជាំង។ តើជនរង

គ្រោះនោះ គាត់មានបាននិយាយប្រាប់លោកអំពីអារម្មណ៍ដែលថាមិនមែនជាមនុស្ស ដែលថាគេមិនចាត់ទុកជាមនុស្សនោះ តើ -- ហើយតើសង្គមកម្ពុជាហ្នឹងនៅតែទទួលរងផលវិបាកនៃដំណើរការដែលថា ធ្វើឱ្យមនុស្សក្លាយទៅជាសត្វធាតុបែបនេះនោះ? តើមានអ៊ីចឹងទេ?

[១៣:៥៤:៥៧]

**ឆ៖** បាទ មាន។ បងប្អូនមួយចំនួនគាត់បានត្អូញត្អែរថា គាត់ហ្នឹងហាក់ដូចជាអន់ជាងមនុស្សទៅទៀត។ ពីព្រោះមនុស្សគឺយើងអាចស្តាប់គ្នាបាន។ មនុស្សយើងអាចមានទំនាក់ទំនងគ្នា។ ប៉ុន្តែ នៅក្នុងសម័យខ្មែរក្រហមហាក់ដូចជាមិនមាននូវការ *ទ្រីត* – ដូចថាការយកចិត្តទុកដាក់គ្នា – ឱ្យលក្ខណៈដូចជាមនុស្ស គឺហាក់ដូចជាមិនមែនជាមនុស្ស។ អ៊ីចឹងអាលក្ខណៈទាំងអស់ហ្នឹងហើយ ដែលខ្ញុំគិតថាវារួមផ្សំនឹងទារុណកម្ម រួមផ្សំទាំងអត់បាយទឹក ក្រហាយទឹក ធ្វើបាប ព្យាយាមតាមដានសព្វបែបយ៉ាង។ អាហ្នឹងហើយ គឺជាព្រឹត្តិការណ៍រន្ធត់ដែលធ្វើឱ្យប្រជាជនយើងបាក់ស្បាត។ ហើយខ្ញុំជឿថាការបាក់ស្បាតហ្នឹង នៅតែបន្តមានរហូតមកដល់ឥឡូវហ្នឹង។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកអ្នកជំនាញ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

[១៣:៥៥:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះអ្នកជំនាញរូបនេះ។

សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកអ្នកជំនាញ! ខ្ញុំមានសំណួរមួយចំនួនតូចទេសម្រាប់លោកថ្ងៃនេះ។ ដំបូងខ្ញុំសូមសួរសំណួរមួយចំនួនទៅកាន់លោក អំពីប្រវត្តិសិក្សា និងប្រវត្តិវិជ្ជាជីវៈរបស់លោក។ ម្សិលមិញលោកបានផ្តល់សក្ខីកម្មម្តងរួចមកហើយ ដែលថាលោកធ្វើការនៅក្នុងជំនាញផ្នែកចិត្តសាស្ត្រនេះជិត១៩

ឆ្នាំហើយ។ បើខ្ញុំយល់មិនច្រឡំទេ លោកចាប់ផ្តើមសិក្សាផ្នែកវេជ្ជសាស្ត្រតាំងពីឆ្នាំ១៩៨៦ ដល់៩២។ នៅក្នុងចន្លោះពេលហ្នឹង តើមានសិក្សាផ្នែកចិត្តសាស្ត្រនេះដែរឬទេលោក? ឬហើយនៅពេលហ្នឹង ថាតើជំនាញផ្នែកចិត្តសាស្ត្រនេះ មានគេមានបង្រៀនៅក្នុងប្រទេសកម្ពុជាហើយឬនៅ?

**លោក ឈឹម សុធារ៉ា៖**

**ឆ៖** នៅពេលហ្នឹង មិនទាន់មានជំនាញចិត្តសាស្ត្រទេ គឺរបបខ្មែរក្រហមសម្លាប់អ្នកជំនាញចិត្តសាស្ត្រដែលមានពីរនាក់នៅមុនសម័យខ្មែរក្រហមហ្នឹងហើយ។

[១៣:៥៧:៥៣]

**ស៖** បើអ៊ីចឹង នៅក្នុងឆ្នាំ១៩៨២ លោកក៏បានចាប់ផ្តើមធ្វើការងារជាគ្រូពេទ្យរះកាត់មួយមែនទេ នៅក្នុងឆ្នាំ រហូតមកដល់៩២?

**ឆ៖** បាទ ពីឆ្នាំ៩២ ទៅដល់ឆ្នាំ៩៤។

**ស៖** បន្ទាប់មកនៅក្នុងឆ្នាំ១៩៩៩ លោកបានទៅប្រទេសន័រវេស។ តើលោកអញ្ជើញទៅសិក្សារៀនយកសញ្ញាបត្រអនុបណ្ឌិត ឬក៏ផ្នែកវេជ្ជសាស្ត្រ ឬក៏ខាងផ្នែកមុខវិជ្ជាអីដែរ នៅក្នុងប្រទេសន័រវេសហ្នឹង?

**ឆ៖** ខ្ញុំអត់បានទៅប្រទេសន័រវេសទេ។ សាលកវិទ្យាល័យអូស្លូនៃប្រទេសន័រវេស គាត់បានមកបង្កើតកម្មវិធី *ស្ពេស្យាល់លីស ត្រេននីង ប្រូក្រាម អ៊ីន សាយខាយទ្រីស* នៅក្នុងកម្ពុជា ដោយសហការជាមួយនឹងសាលកវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល។ ហើយការសិក្សាហ្នឹង គឺចាប់ឆ្នាំពី១៩៩៤ ទៅឆ្នាំ១៩៩៨។ នៅក្នុងពេលសិក្សានោះ គឺយើងសិក្សាក្នុងលក្ខណៈ *ប្រូវ្លេម បេស ឡឺនទីង*។ អ៊ីចឹង *ប្រូវ្លេម បេស ឡឺនទីង* ហ្នឹង គឺយើងរៀនទ្រឹស្តីផង គឺយើងមើលអ្នកជំងឺផង។ អ៊ីចឹងនៅក្នុងរយៈពេលចាប់តាំងពីថ្ងៃទី១ នៃឆ្នាំទី១ ឆ្នាំ៩៤ហ្នឹង គឺពួកខ្ញុំចាប់ផ្តើមមើលជំងឺហើយ ក្រោមការត្រួតពិនិត្យយ៉ាងជិតដិត យ៉ាងជាប់របស់សាស្ត្រាចារ្យជំនាញវិកលវិទ្យារបស់ប្រទេសន័រវេស។

**ស៖** ប៉ុន្តែគឺថាវាជាកម្មវិធីសិក្សាមួយ តើត្រឹមត្រូវទេ?

**ឆ៖** ជាកម្មវិធីសិក្សាប្ញកនឹងការអនុវត្តជាក់ស្តែង។ ពីព្រោះយើងត្រូវបានបញ្ជាឲ្យ -- ត្រូវបាន -- ដូចថាឲ្យមើលអ្នកជំងឺតាំងពីថ្ងៃទី១ គឺយើងចាប់ផ្តើមមើល --*ប្រាទិក* តែម្តង បាទ។

[១៤:០០:០៥]

**ស៖** ហើយលោកបញ្ចប់កម្មវិធីសិក្សានៅក្នុងឆ្នាំ១៩៩៨ ហើយក្រោយមកលោកបញ្ចប់ការសិក្សា

ថ្នាក់អនុបណ្ឌិតនៅប្រទេសអូស្ត្រាលី។ តើត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ហើយក្រោយលោកបញ្ចប់ថ្នាក់អនុបណ្ឌិត លោកក្លាយទៅជានាយកប្រតិបត្តិរបស់អង្គការ ធី.ភី.អូ នេះតែម្តង ឬក៏យ៉ាងណា?

**ឆ៖** អត់ទាន់ទេ ខ្ញុំត្រឡប់មកធ្វើការនៅក្នុងមន្ទីរពេទ្យខាងផ្នែកជំងឺផ្លូវចិត្តហ្នឹងដដែល នៅមន្ទីរពេទ្យខ្មែរសូវៀត ហើយឆ្នាំ២០០២ បានខ្ញុំចាប់ផ្តើមមកធ្វើនាយកអង្គការ ធី.ភី.អូ។

**ស៖** សំណួររបស់ខ្ញុំគឺសួរថាតើលោកជាគ្រូពេទ្យចិត្តសាស្ត្រដែលទទួលបានគុណវុឌ្ឍិពេញលេញតែម្តង ឬក៏លោកគ្រាន់តែជាអ្នកសិក្សាៗផ្នែកខាងវិកលវិទ្យាតែប៉ុណ្ណោះ?

[១៤:០១:២៦]

**ឆ៖** ខ្ញុំបានទទួលសញ្ញាបត្រពេញលេញ ទទួលស្គាល់ពីក្រសួងសុខាភិបាល គឺក្នុងចំណោម១០នាក់ដំបូងនៃក្នុងប្រទេសកម្ពុជា។

**ស៖** សួរឡើងវិញ ថាតើលោកជាគ្រូពេទ្យខាងផ្នែកវិកលវិទ្យា ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំជាវេជ្ជបណ្ឌិតឯកទេសវិកលវិទ្យា។ *អែម អឺ ខោនសាលធែន សោខាយទ្រីស*។

**ស៖** តើលោកមានការអនុវត្តព្យាបាលជំងឺវិកលវិទ្យាហ្នឹងជាក់ស្តែងតែម្តងទេ នៅក្នុងភ្នំពេញយើងនេះ?

**ឆ៖** បាទ ប្រាកដណាស់ខ្ញុំអនុវត្តជាក់ស្តែងទាំងនៅកន្លែងធ្វើការ ទាំងនៅគ្លីនិកឯកជន។

**ស៖** តើនៅពេលណាដែលលោកអញ្ជើញទៅប្រទេសអូស្ត្រាលី ដើម្បីទៅសិក្សាទទួលយកសញ្ញាបត្រថ្នាក់អនុបណ្ឌិតនោះ? សូមកែប្រែ គឺសញ្ញាបត្រថ្នាក់បណ្ឌិតរបស់លោកនោះ?

**ឆ៖** សញ្ញាបត្រថ្នាក់បណ្ឌិត ខ្ញុំចេញទៅឆ្នាំ២០០៨។

[១៤:០៣:២៧]

**ស៖** តើលោកសិក្សាពេញម៉ោងតែម្តងនៅប្រទេសអូស្ត្រាលី ឬក៏គ្រាន់តែវាមានកម្មវិធីណាដែលឲ្យលោកសិក្សានៅក្នុងប្រទេសកម្ពុជាទៅបានផងដែរនោះ?

**ឆ៖** ខ្ញុំមិនមែនសិក្សា*ហ្វូលថាម* នៅកម្ពុជាទេ គឺខ្ញុំមានកម្មវិធីទៅខ្លះ មកខ្លះ ហើយជាពិសេសនៅក្នុង*វីស៊ើច* គឺខ្ញុំធ្វើ *វីស៊ើច* នៅក្នុងប្រទេសកម្ពុជាតែម្តង។

**ស៖** កាលពីសប្តាហ៍មុន លោកបានទទួលលិខិតមួយច្បាប់ពីមេធាវីមួយរូប មេធាវីដើមបណ្តឹង

វេជ្ជបណ្ឌិតមួយរូបដែលស្នើសុំឲ្យផ្តល់សក្ខីកម្មទៅ -- ដោយលើកឡើងពីប្រធានឲ្យលោកមកផ្តល់សក្ខីកម្ម ហើយគឺប្រធានបទនេះគឺផ្ញើជូនទៅវេជ្ជបណ្ឌិត ឈឹម សុធារ៉ា។ ថាតើៗពាក្យថា "បណ្ឌិត" កន្លែងនេះ "ឌុកទ័រ" កន្លែងនេះគឺលោកជាផ្នែកខាងវេជ្ជសាស្ត្រ ឬក៏ផ្នែកខាងបណ្ឌិតនោះ?

**ឆ៖** ឌុកទ័រ ហ្នឹងគឺវេជ្ជបណ្ឌិត ព្រោះខ្ញុំមិនទាន់បានសញ្ញាបត្របណ្ឌិតទេ។

[១៤:០៥:០៥]

**ស៖** អ៊ីចឹងលោកចង់ជម្រាបថា អ៊ីចឹងមានន័យថាបើសិនណាគិតទៅតាម *ទីព* ឬមុខងារនៅក្នុងការរៀនសូត្រនោះ គឺលោកមិនទាន់អាច គេមិនទាន់អាចហៅលោកថាជា "បណ្ឌិត សុធារ៉ា" បានទេ មែនទេ?

**ឆ៖** សព្វថ្ងៃវេជ្ជបណ្ឌិត ប៉ុន្តែបណ្ឌិតខ្ញុំគិតថា ខ្ញុំជិតបានហើយ ពីព្រោះខ្ញុំដល់ដំណាក់កាលចុងក្រោយហើយ។

**ស៖** អ៊ីចឹងគិតពីតាមការសិក្សារៀនសូត្រនោះ គឺថាយើងខ្ញុំមិនទាន់អាចថាហៅលោកថាជាបណ្ឌិតបានទេ។ អ៊ីចឹងលោកយល់ស្របជាមួយយើងខ្ញុំដែរទេ?

**ឆ៖** បាទខ្ញុំក៏មិនទាន់ហៅខ្លួនឯងថាជាបណ្ឌិតដែរ។ ខ្ញុំហៅខ្លួនឯងជាវេជ្ជបណ្ឌិតឯកទេស។

[១៤:០៦:១៧]

**ស៖** ក្នុងសមត្ថភាពចុងក្រោយ ក្នុងជាគឺនាមលោកជាគ្រូពេទ្យអនុវត្តជាក់ស្តែង ថាតើលោកអនុវត្តផ្នែកខាងវេជ្ជសាស្ត្រនេះជាក់ស្តែងនេះ បានប៉ុន្មានឆ្នាំដែរ?

**ឆ៖** ដូចខ្ញុំជម្រាបពីដើមអ៊ីចឹង គឺខ្ញុំចាប់ផ្តើមមើលជំងឺតាំងពីថ្ងៃទី១នៃការសិក្សាថ្នាក់ឯកទេស។ អ៊ីចឹងរហូតមកដល់ថ្ងៃនេះ គឺខ្ញុំនៅមើលជំងឺទៀត ខ្ញុំនៅមើលអ្នកជំងឺរហូត។ អ៊ីចឹងសរុបទៅប្រហែលជាជិត១៩ឆ្នាំហើយ។

**ស៖** ពេលដែលលោកថា លោកធ្វើការអនុវត្តផ្នែកខាងវិកលវិទ្យានេះជិត១៩ឆ្នាំហើយ រួមទាំងអំឡុងពេលនេះ គឺរួមទាំងការសិក្សារៀនសូត្ររបស់លោកផងដែរ។ ខ្ញុំយល់អ៊ីចឹង តើត្រឹមត្រូវទេ?

**ឆ៖** បាទ ខ្ញុំបានបញ្ជាក់ថាខ្ញុំចាប់ផ្តើមធ្វើការនៅក្នុងវិស័យនេះរយៈពេលជិត១៩ឆ្នាំហើយ។ អ៊ីចឹងបូកសរុបទាំងការសិក្សានៅពេលចុងក្រោយនេះផងដែរ។ សូម្បីតែការសិក្សាក៏យើង ក៏ខ្ញុំនៅតែអនុវត្តដែរ។ អ៊ីចឹងការសិក្សា ហើយនិងការអនុវត្តនៅជាមួយគ្នា។

[១៤:០៧:៤៦]

**ស៖** សំណួរខ្ញុំប្រហែលជាលោកមានការ ដោយសារតែខ្ញុំយល់ច្រឡំក្នុងប្រព័ន្ធសិក្សានៅក្នុងប្រទេសកម្ពុជា ខ្ញុំជឿថានៅអាមេរិកខាងជើង និងប្រព័ន្ធអឺរ៉ុបនោះ គឺក្រោយពីធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលមួយចំនួនជាក់លាក់ ទើបគាត់អាចក្លាយទៅជាគ្រូពេទ្យព្យាបាលផ្នែករិកលវិទ្យា។ តើអ៊ីចឹងដែរឬទេនៅក្នុងកម្ពុជា ទាល់តែទទួលការបណ្តុះបណ្តាលជាក់លាក់សិនទើបក្លាយទៅជាគ្រូពេទ្យព្យាបាលរិកលវិទ្យាដែរ? តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ តាមពិតណាស់ ត្រូវហើយ ទាល់តែទទួលសញ្ញាបត្របានយើងថាអ្នកហ្នឹងមានបច្ចេកទេសជាក់លាក់ បានន័យថាទទួលស្គាល់។ ប៉ុន្តែនៅក្នុងប្រទេសដែល *រីសិស* – ធនធានតូចហ្នឹងគឺយើងមានកម្មវិធីបណ្តុះបណ្តាលតាំងពីកម្រិតទាប ដើម្បីឲ្យពួកគាត់អាចព្យាបាលបាន។ ឧទាហរណ៍ថាយើងការបណ្តុះបណ្តាលរយៈពេល៣ខែ ឬក៏១ឆ្នាំ អាហ្នឹងក៏យើងអាចទទួលស្គាល់ក្នុងកម្រិតមួយដែលគាត់អាចមានបច្ចេកទេសក្នុងការព្យាបាលដែរ។

[១៤:០៩:០៧]

**ស៖** ខ្ញុំយល់ ក៏ប៉ុន្តែប្រសិនបើលោកបានសិក្សាតាមកម្មវិធីដំបូង ហើយនៅពេលនេះលោកកំពុងសិក្សាថ្នាក់អនុ -- ថ្នាក់បណ្ឌិតនៅប្រទេសអូស្ត្រាលីទៀត។ តាមច្បាប់នៅប្រទេសទាំងអស់នោះ តើនៅពេលណាទើបលោកអាចក្លាយទៅជាគ្រូពេទ្យព្យាបាលផ្នែករិកលវិទ្យានោះ? ក្រោយពីការសិក្សាទាំងអស់នោះទើបលោកក្លាយ ឬក៏ក្លាយទៅជាគ្រូពេទ្យហ្នឹង ឬក៏លោកក្លាយទៅជាគ្រូពេទ្យរិកលវិទ្យារួចទៅហើយ?

**ឆ៖** ខ្ញុំក្លាយទៅជាគ្រូពេទ្យរិកលវិទ្យារួចហើយមុនពេលទៅចេញទៅសិក្សា។

**ស៖** ខ្ញុំមិនដឹងថាយើងយល់គ្នាទៅតាមការសួរសំណួរនេះឬក៏យ៉ាងណានោះទេ ក៏ប៉ុន្តែនៅពេលនេះខ្ញុំសូមបន្តសួរទៅលើប្រធានបទមួយទៀត គឺខ្ញុំសូមលើកឡើងប្រធានបទដូចតទៅនេះ។ តើតាមការយល់ឃើញរបស់លោកនៅចន្លោះឆ្នាំ១៩៧៥ និង៧៩ យើងដឹងថាគ្រប់ទិដ្ឋភាព គ្រប់វិស័យនៅក្នុងប្រទេសកម្ពុជាត្រូវបានបំផ្លិចបំផ្លាញនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ បានន័យថា ការយល់ឃើញរបស់លោកនោះ គឺបានន័យថាខ្មែរក្រហមនេះកម្ទេចបំផ្លាញគ្រប់ស្រទាប់នៅក្នុងប្រទេសកម្ពុជាទាំងអស់ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ គឺទាំងស្រុង។

[១៤:១១:០១]

**ស៖** តើលោកយល់ឃើញ តើជាការយល់ឃើញរបស់លោកនោះ តើលោកយល់ថារបបខ្មែរក្រហមជារបបប្រល័យពូជសាសន៍ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ! នេះជាបញ្ហាផ្លូវច្បាប់ ជាមុខងាររបស់តុលាការ ហើយសំណួរនេះមិនមែនជាភាពជំនាញរបស់ -- ពាក់ពន្ធ័នឹងភាពជំនាញរបស់អ្នកជំនាញរូបនេះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ការជំទាស់របស់លោកប្រធាន។ គ្រាន់តែខ្ញុំដកស្រង់ចេញពីសក្ខីកម្មដំបូងរបស់សាក្សីរូបនេះដោយគាត់ហៅរបបខ្មែរក្រហមនេះជារបបប្រល័យពូជសាសន៍។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើតាមការយល់ឃើញរបស់លោកនោះគឺថា អ្វីដែលធ្វើឡើងដោយខ្មែរក្រហមហ្នឹង គឺវាមិនត្រឹមត្រូវតែទាំងស្រុងតែម្ដងឬក៏យ៉ាងម៉េច?

[១៤:១១:៥៩]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរបែបនេះទេ មិនមែនជាភាពជំនាញរបស់លោកសាក្សីទេ!

លោកមេធាវី ការកោះអញ្ជើញសាក្សីរូបនេះមកគឺផ្ដល់សក្ខីកម្មពាក់ព័ន្ធនឹងជំងឺផ្លូវចិត្តនៃជនរងគ្រោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្រៅពីនេះ ការយល់របស់អ្នកជំនាញរូបនេះ បញ្ហាផ្សេងពីនេះគឺអាចសួរគាត់បាននៅក្នុងនាមផ្សេង បានន័យថាសាក្សី ឬក៏ជាឋានៈផ្សេងទៅវិញមិនមែនកាលៈទេសៈនេះទេ។ យើងកំណត់ច្បាស់លាស់ណាស់ គឺអ្នកជំនាញពាក់ព័ន្ធនឹងជំងឺផ្លូវចិត្តនៃជនរងគ្រោះទាំងឡាយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់លោកប្រធាន។ ជាថ្មីម្ដងទៀតខ្ញុំគ្រាន់តែដកស្រង់ចេញពីសក្ខីកម្មដែលគាត់បានឆ្លើយ នៅក្នុងសំណុំរឿង០០១ តែប៉ុណ្ណោះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** នៅពេលមើលភស្តុតាងដែលលោកបានឆ្លើយប្រាប់នៅក្នុងសំណុំរឿង០០១ សាជាថ្មីវាបានបង្ហាញឲ្យឃើញថា លោកមានការយល់ឃើញយ៉ាងអវិជ្ជមានខ្លាំងក្លាទៅលើរបបកម្ពុជាប្រជាធិបតេយ្យ

ក្នុងចន្លោះឆ្នាំ៧៥ ដល់ ៧៩។ តើជាការសង្ខេបលើចម្លើយភស្តុតាងរបស់លោកត្រឹមត្រូវដែរឬទេត្រង់ចំណុចនេះ?

[១៤:១៣:៤០]

**លោក ឈឹម សុធារ៉ា៖**

**ឆ៖** បាទ ពិតប្រាកដហើយបាទ។

**ស៖** ក្រោយពីស្តាប់ចម្លើយរបស់លោក សំណួររបស់ខ្ញុំគឺចង់សួរលោកថា តើនៅក្នុងការងារព្យាបាលជំងឺរបស់លោក និងការងារសិក្សាស្រាវជ្រាវផ្នែកវិកលវិទ្យានុ៎ង តើលោកមានបានចៀសវាងមិនឲ្យការយល់ឃើញបែបអវិជ្ជមានរបស់លោកលើសម័យឆ្នាំ៧៥-៧៩ ឬកុំឲ្យវាចូលទៅប៉ះពាល់ដល់ការងារដែលលោកធ្វើក្នុងនាមជាវិកលវិទូដែលឬទេ? បានន័យថាតើលោកមានបានកុំឲ្យការយល់ឃើញរបស់ពួកលោកអំពីរបបកម្ពុជាប្រជាធិបតេយ្យនេះប៉ះពាល់ទៅដល់ការសិក្សាស្រាវជ្រាវ និងការព្យាបាលផ្នែកវិកលវិទ្យារបស់លោកដែរឬទេ?

**ឆ៖** បាទ សូមអរគុណ។ ខ្ញុំសូមបញ្ជាក់លោកថា ខ្ញុំទទួលសញ្ញាបត្រដំបូងជាវេជ្ជបណ្ឌិត ខ្ញុំបានធ្វើសម្បថ*អ៊ីប៉ូក្រាត* នៅក្នុងពេលមុនចេញធ្វើការដើម្បី តាំងពីថ្ងៃចូលទី១នៃមហាវិទ្យាល័យដើម្បីមិនប្រើឲ្យមានភាពលម្អៀងនៅក្នុងការព្យាបាលអ្នកជំងឺ មិនប្រកាន់នូវឋានៈ ឬក៏ពូជសាសន៍ ឬក៏អីរបស់អ្នកជំងឺ។

[១៤:១៥:០៣]

អ៊ីចឹងខ្ញុំនៅប្រកាន់នូវក្រមសីលធម៌ហ្នឹងជាប់រហូត។ ហើយចំពោះសំណួរលោកទាក់ទងទៅថាលោកមើលទៅ ដូចថាមានភាពអវិជ្ជមាននៅក្នុងជំងឺក្នុងសម័យខ្មែរក្រហមនោះ ខ្ញុំសូមបញ្ជាក់ថា យើងអង្គការយើងគឺជាអង្គការមួយដែលមានលក្ខណៈអាជីពត្រឹមត្រូវ គឺយើងមានក្រមសីលធម៌ត្រឹមត្រូវនៅក្នុងការព្យាបាល។ យើងមានការត្រួតពិនិត្យ *ស៊ុបភើវីស៊ិន* ត្រឹមត្រូវ យើងមានការពិភាក្សា ប្រសិនបើមានអារម្មណ៍អវិជ្ជមានណាមួយប៉ះពាល់ យើងធ្វើការពិភាក្សាដើម្បីបំបាត់នូវអារម្មណ៍អវិជ្ជមាននោះដើម្បីជួយ ដើម្បីជាសុខភាពរបស់យើងជាអ្នកផ្តល់ប្រឹក្សា ផ្តល់ការព្យាបាលផង ហើយនិងដើម្បីឲ្យមានអព្យាក្រឹតភាពផងនៅក្នុងអាជីពរបស់យើង។

ហើយក្នុងការសិក្សានិងការប្រើប្រាស់ទៀត គឺយើងបានប្រើនូវឧបករណ៍ដែលមានលក្ខណៈមួយទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ដើម្បីកុំឲ្យថាយើងចេះតែព្យាបាលដោយសារមិនមានជំនាញអីច្បាស់លាស់ជាដើម។ អ៊ីចឹងខ្ញុំសូមបញ្ជាក់ថាយើងព្យាយាមធ្វើមិនឲ្យមានលំអៀងនៅក្នុងការព្យាបាលនោះទេ។

[១៤:១៦:២៤]

**សៈ** ខ្ញុំយល់។ តើលោកបានធ្វើការងារអ្វីជាក់លាក់ដែរ ដើម្បីជៀសវាងកុំឱ្យបង្ហាញថាលោកហ្នឹងមានភាពលម្អៀងនៅក្នុងការសិក្សាស្រាវជ្រាវរបស់លោកនោះ?

**ផៈ** បាទ ឧទាហរណ៍ដូចជានៅក្នុងការសិក្សាស្រាវជ្រាវ នៅក្នុងសម្ភាសគឺយើងអត់ប្រើបុគ្គលិករបស់ ធី.ភី.អូ *ខោនស៊ុលល័រ* របស់ ធី.ភី.អូ ដើម្បីទៅសម្ភាសទេ ពីព្រោះដោយសារ *ខោនស៊ុលល័រ* របស់ ធី.ភី.អូ អ្នកផ្តល់ប្រឹក្សា ធី.ភី.អូ ហ្នឹង គាត់យល់ពីបញ្ហាផ្លូវចិត្ត។ អ៊ីចឹងយើងគិតថាអាហ្នឹងវាអាចជាលម្អៀង។ អ៊ីចឹងយើងយកអ្នកផ្សេងដែលមិនស្គាល់អំពីអតិថិជនរបស់យើង មិនស្គាល់ពីអ្នកជំងឺរបស់យើងមកបង្រៀន ដើម្បីឱ្យគាត់ហ្នឹងចេះប្រើប្រាស់កម្រងសំណួរដើម្បីទៅសម្ភាស។ អ៊ីចឹងគឺករណីហ្នឹងគឺជាករណីដែលយើងព្យាយាមជៀសវាងកុំឱ្យមានការលម្អៀង។

**សៈ** ខ្ញុំសូមសួរទៅមុនទៀត កាលពីម្សិលមិញលោកបានផ្តល់សក្ខីកម្មថា ខ្ញុំដកស្រង់សម្តីរបស់លោក "ខ្ញុំអាចនិយាយថាជនរងគ្រោះភាគច្រើនដែលយើងផ្តល់ការព្យាបាលនោះ គឺថាពួកគេមានការភិតភ័យ និងមានជំងឺបាក់ស្បាត"។ តើលោកមានន័យយ៉ាងម៉េចនៅពេលដែលលោកនិយាយថាអ្នក -- ជនរងគ្រោះភាគច្រើនដែលលោកធ្វើការជាមួយនោះ ឬពាក្យថាធ្វើការជាមួយនេះបានន័យថាលោកព្យាបាលពួកគេ និយាយជាមួយពួកគេ ដោយតាមរបៀបសួរសំណួរ តាមការសិក្សាស្រាវជ្រាវ ឬក៏លោកមានន័យយ៉ាងម៉េចដែរ?

[១៤:១៨:២៩]

**ផៈ** ជាការបូករួមគ្នារវាងការស្រាវជ្រាវខ្លះ ហើយនិងការងារ *ខន់សាល់ថេស៊ិន* – ការពិគ្រោះខ្លះ។

**សៈ** តើចំណុចទាំងពីរអំមិញហ្នឹង តើមួយណាច្រើនជាង អ្នកដែលលោកនិយាយជាមួយហ្នឹងបានន័យថាគឺលោកជួបជាមួយគាត់ហ្នឹង ដើម្បីកិច្ចការស្រាវជ្រាវរបស់លោក ឬក៏លោកជួបជាមួយពួកគេ ដើម្បីព្យាបាលពួកគេ តើមួយណាច្រើនជាង?

**ផៈ** បាទ ខ្ញុំសូមបញ្ជាក់ថាក្នុងការស្រាវជ្រាវ ពួកខ្ញុំមិនប្រើ ខ្លួនខ្ញុំផ្ទាល់មិនសម្ភាសទេ ហើយពួកបុគ្គលិកអង្គការ ភី.ធី.អូ មិនសម្ភាសអ្នកជំងឺដែរ គឺយើងយកជនទី២ អ្នកភាគីផ្សេងដែលមិនស្គាល់អតិថិជនមកសម្ភាស។ ចំណែកឯភាគច្រើននៃការដែលយើងជួបជាមួយអ្នកជំងឺហ្នឹងគឺជួបក្នុងលក្ខណៈព្យាបាល ក្នុងលក្ខណៈផ្តល់ប្រឹក្សា ក្នុងលក្ខណៈជាការផ្តល់ប្រឹក្សា ហើយនិងការពិគ្រោះយោបល់។

[១៤:១៩:៥៩]

**សៈ** ខ្ញុំហាក់ដូចជាមិនយល់ច្បាស់ពីចម្លើយលោក លោកបានន័យថា ទាំងការព្យាបាល ទាំងបទពិសោធន៍ ទាំងសិក្សាស្រាវជ្រាវ គឺទាំងពីរហ្នឹងគឺលោកធ្វើការរួមគ្នាជួបមួយជនរងគ្រោះហ្នឹង ឬក៏យ៉ាងម៉េច?

**ឆៈ** បាទ ខ្ញុំជម្រាបលោកហើយថា អំណះអំណាងដែលខ្ញុំលើកពីម្សិលមិញ ឬក៏លើកៗមុនហ្នឹង គឺបានមកពីការស្រាវជ្រាវផង បានមកពីគ្លីនីកផង ការងារដែលពិគ្រោះជាមួយអ្នកជំងឺផង។ ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា ពួកខ្ញុំមិនជួបអ្នកជំងឺផ្ទាល់ទេនៅក្នុងករណីដែលយើងធ្វើការស្រាវជ្រាវ។ នៅពេលដែលយើងដាក់សម្រង់ -- កម្រងសំណួរដើម្បីសួរអតិថិជន គឺពួកយើងមិនមែនអ្នកធ្វើទេ គឺយើងយកមនុស្សទី៣ ភាគីមួយផ្សេងទៀត ដើម្បីមកអនុវត្តកម្រងសំណួរ ប្រើកម្រង់សំណួរដើម្បីសម្ភាសន៍។ អ៊ីចឹងអាហ្នឹងគឺផ្នែកស្រាវជ្រាវ អ៊ីចឹងវាដាច់ឡែកពីគ្នា។

[១៤:២១:០៥]

ចំណែកឯផ្នែកគ្លីនិកក្នុងការពិគ្រោះ និងផ្តល់ប្រឹក្សាហ្នឹង គឺយើងជួបផ្ទាល់បាទ។ ការសិក្សាយើងហ្នឹង ភាគច្រើនគឺយើងចង់ដឹងអំពីរោគសញ្ញា អំពីការប្រែប្រួលនៃរោគសញ្ញា ឡើងឬក៏ចុះ ដើម្បីជៀសវាងកុំឲ្យលម្អៀងថា យើងព្យាបាលហើយស្រាប់យើងវាស់ខ្លួនឯង។ យើងចង់ឲ្យដឹងថា អ្នកដទៃមកវាស់តើការសិក្សា -- តើការព្យាបាលរបស់យើងហ្នឹងមានប្រសិទ្ធភាពយ៉ាងណា។ អ៊ីចឹងអានេះគឺជាការជៀសវាងការលម្អៀង។

**សៈ** ខ្ញុំដូចជាមិនប្រាកដថា ខ្ញុំយល់ពីលោកច្បាស់សោះ។ ខ្ញុំជឿថា មានភាពខុសគ្នារវាងអ្វីដែលលោកអាចសន្និដ្ឋាននៅពេលដែលលោកទៅធ្វើការងារគ្លីនិក សម្ភាសជាមួយនឹងជនរងគ្រោះ អ្នកជំងឺ។ ហើយមួយទៀត វាមានភាពខុសគ្នារវាងការងារស្រាវជ្រាវនៅក្នុងការសិក្សារបស់លោក។

[១៤:២២:១០]

ខ្ញុំសូមផ្តល់ជាឧទាហរណ៍ ខ្ញុំសូមលើកឡើងពាក្យថា "ភាគីច្រើន" លោកប្រើពាក្យថា ភាគីច្រើននៃជនរងគ្រោះដែលលោកធ្វើការជាមួយ គឺមានជំងឺភិតភ័យ – *ត្រូម៉ាថាយ* – មានការប៉ះទង្គិចផ្លូវចិត្ត។ ហើយខ្ញុំដឹងថា ខ្ញុំនេះជាមេធាវីមានសញ្ញាបត្រច្បាប់នៅប្រទេសហូឡង់ ឧទាហរណ៍ថា ប្រសិនបើខ្ញុំនិយាយជាមួយនិងកូនក្តីរបស់ខ្ញុំ៥០នាក់ ដែលនិយាយអំពីពាក្យច្បាប់ ពាក់ព័ន្ធទៅនឹងការរំលោភច្បាប់ គឺបានន័យថា នេះគឺវាពាក់ព័ន្ធទៅនឹងកូនក្តីរបស់ខ្ញុំដែលមកជួបខ្ញុំ ឬខ្ញុំជួបជាមួយ។ វាមិនពាក់ព័ន្ធទៅនឹង

ប្រជាជនសាមញ្ញភាគច្រើនទៀតដែលគាត់យល់អំពីបញ្ហាព្រហ្មទណ្ឌនោះទេ។ ដូច្នេះបានន័យថា អ្នកដែលជាអ្នកជំងឺមកជួបលោកនោះ គឺដោយសារតែអ្នកទាំងអស់នោះ គាត់មានជំងឺខាងផ្នែកផ្លូវចិត្ត ហើយអ្នកជំងឺដែលមកជួបលោកមួយក្រុមនុ៎ង គឺមិនមែនជាតំណាងឲ្យប្រជាជនភាគច្រើននៅក្នុងប្រទេសកម្ពុជាទាំងមូលនោះទេ។ តើលោកយល់ទេ អ្វីដែលខ្ញុំលើកឡើង?

[១៤:២៣:៣៥]

**ឆ៖** ខ្ញុំមិនដឹងថា លោកយល់នូវអ្វីដែលចង់ -- ដែលខ្ញុំចង់និយាយទេ។ ខ្ញុំឆ្លើយទៅសំណួរលោកសួរដំបូងនោះ លោកសួរថាតើអំណះអំណាងដែលខ្ញុំលើកឡើងអំពីការប៉ះពាល់ផ្លូវចិត្តហ្នឹង តើសមាមាត្រប៉ុន្មានបានមកពីខាងគ្លីនិកពីខាងមើលជំងឺ ហើយនិងសមាមាត្រប៉ុន្មានបានមកពីខាងការស្រាវជ្រាវ? ហើយខ្ញុំ -- ហើយលោកបានសួរទៀតថា តើធ្វើយ៉ាងម៉េចដើម្បីបញ្ជាក់ថា មិនមានលម្អៀងនៅក្នុងការដែលយើងស្រាវជ្រាវហ្នឹង នៅក្នុងការអីហ្នឹង? ហើយខ្ញុំបានបញ្ជាក់ថា អំណះអំណាងដែលខ្ញុំយកមកនិយាយហ្នឹង មួយចំនួនធំបានមកពីបទពិសោធន៍ខាងគ្លីនិក ដែលខ្ញុំបានមើលជំងឺ ឬក៏សហការីរបស់ខ្ញុំបានផ្តល់សេវាជូនពួកគាត់ហ្នឹង ហើយមួយចំនួនទៀតបានមកពីខាងស្រាវជ្រាវ។ ហើយសូមបញ្ជាក់ទៀតថា ក្នុងការស្រាវជ្រាវហ្នឹង គឺវាអាចមានវិធីសាស្ត្រច្រើននៅក្នុងការស្រាវជ្រាវ។ ហើយអ្វីដែលយើងធ្វើការស្រាវជ្រាវនេះ គឺខ្ញុំចង់និយាយហ្នឹង គឺចង់និយាយថា យើងធ្វើការស្រាវជ្រាវ យើងចង់ដឹងអំពីកម្រិតនៃការឈឺចាប់ហ្នឹង ដើម្បីយើងវាស់វែងផង ដើម្បីចង់ដឹងអំពីប្រសិទ្ធភាពនៃការព្យាបាលផង។

[១៤:២៤:៤៨]

អ៊ីចឹងហើយបានខ្ញុំទាញមនុស្សទី៣ មកដើម្បីឲ្យគាត់ធ្វើការវាយតម្លៃជំនួសពួកខ្ញុំ ហើយនិងក្រុមខ្ញុំ ដើម្បីជៀសវាងនៅការលម្អៀង។ អ៊ីចឹងព័ត៌មានហ្នឹង វាធ្វើឲ្យខ្ញុំបានដឹងដែរ តើបញ្ហាផ្លូវចិត្តហ្នឹងវាម៉េច? វាកើនឡើងឬក៏ថយចុះក្រោយពីការព្យាបាល? ហើយបូកផ្សំនឹងសំណួរផ្សេងៗទៀតដែលពាក់ព័ន្ធ។ អ៊ីចឹងយើងបានពីខាងស្រាវជ្រាវផង យើងបានពីគ្លីនិកផង ពីព្រោះយើងជួបអ្នកជំងឺផ្សេងទៀត។ ខ្ញុំជួបអ្នកជំងឺមិនមែនក្នុងន័យសម្អាសដើម្បីធ្វើការស្រាវជ្រាវទេ គឺយើងចង់ដឹងអំពីការប្រែប្រួលរោគសញ្ញាដើម្បីជួយគាត់បន្ថយរោគសញ្ញា។ អ៊ីចឹងព័ត៌មានទាំងអស់ហ្នឹង គឺយើងអាចបានពីរផ្លូវហ្នឹង។

**សៈ** ខ្ញុំគិតថា ប្រហែលជាការរៀបចំសំណួររបស់ខ្ញុំនេះ វាមិនចំចំណុច ប៉ុន្តែខ្ញុំយល់ ខ្ញុំនឹងរៀបចំសំណួរឡើងវិញ។ តើការងារគ្លីនិកជាអ្នកវិកលវិទូនោះ គឺវាបង្ហាញជាតក្កវិទ្យាជាក់ស្តែងតែម្តង? បានន័យថា នៅពេលដែលលោកធ្វើការងារគ្លីនិកនោះ បង្ហាញឲ្យឃើញថាភាគច្រើននៃប្រជាជនកម្ពុជាកើត

ជំងឺប៉ះទង្គិចផ្លូវចិត្ត ឬក៏យ៉ាងម៉េច? បើសិនជាយើងនិយាយអំពីអ្នកដែលគាត់ឆ្លើយទៅនឹងកម្រងសំណួរ ដែលរៀបចំឡើង ថាតើពួកគាត់ប៉ះទង្គិចផ្លូវចិត្តដែរឬទេនោះ? បានន័យថាមនុស្សពីរប្រភេទនោះ បើសិន យើងសួរគាត់ទៅ គឺមានលក្ខណៈខុសគ្នា តើលោកឯកភាពទេ ត្រង់ចំណុចហ្នឹង?

[១៤:២៦:៣៥]

**ឆ៖** ខ្ញុំចង់បញ្ជាក់អ៊ីចេះ។ ទី១ គ្លីនិក ហើយទី២ ស្រាវជ្រាវ។

ចំពោះគ្លីនិក បើសិនជាលោកសួរថា តើម៉េចបានដឹងថាអ្នកជំងឺហ្នឹងប៉ះទង្គិចផ្លូវចិត្តអត់? គឺយើង ផ្អែកទៅលើ *ក្រាយធីរា* – លក្ខខណ្ឌនៃការធ្វើរោគវិនិច្ឆ័យ ដែលផ្អែកទៅលើ ឌី.អេស.អឹម – *ដាយញ៉ូស្ទិក អេន ស្តាទិស្ទិកខល មែនញ៉ូល* ឬក៏ *អ៊ីនធឺណាស់ស្យូណល ក្លាស់ស៊ីហ្វីខេសិន អូហ្វ ឌីស៊ីស (ភាសា អង់គ្លេស, គ្មានការបកប្រែ)*។ អ៊ីចឹងយើងផ្អែកទៅលើអាហ្នឹង យើងអាចដឹងអំពីលក្ខណៈដែលអ្នកជំងឺ ឈឺ ឬក៏អត់។

ប៉ុន្តែលោកសួរថា តើគ្លីនិកហ្នឹងអាចឲ្យដឹងថាមានជំងឺប៉ុន្មាន ច្រើនឬក៏អត់? ខ្ញុំមិនអាចហ៊ាន និយាយទេ ប៉ុន្តែគ្រាន់តែបញ្ជាក់ថា តម្រូវការនៃការព្យាបាលហ្នឹងគឺមានការកើនឡើងពីមួយឆ្នាំទៅមួយ ឆ្នាំ។ អ៊ីចឹងគ្រាន់តែខ្ញុំចង់បញ្ជាក់ថា មានអ្នកជំងឺដែលចង់ព្យាបាលផ្លូវចិត្តហ្នឹងវាច្រើន។ ប៉ះទង្គិចផ្លូវចិត្ត ច្រើន ហើយកំពុងតែរកសេវាហ្នឹងកាន់តែច្រើនឡើង។ ប៉ុន្តែខ្ញុំមិនកំណត់ថាប៉ុន្មានភាគរយនៃប្រជាជន យើងហ្នឹងមានជំងឺផ្លូវចិត្តតាមរយៈការសន្និដ្ឋាននៃគ្លីនិកទេ។ ទាល់តែមានការស្រាវជ្រាវ ហើយនៅក្នុង ស្រុកខ្មែរយើង ការស្រាវជ្រាវមានតិចតួច។ បាទ មានកម្រិត ហើយស្រាវជ្រាវដែលយើង ភាគច្រើន ដែលយើងធ្វើនេះ គឺយើងធ្វើទៅលើអតិថិជនយើង ដែលមកទទួលសេវា។

[១៤:២៨:០៩]

**ស៖** សូមអរគុណចំពោះចម្លើយរបស់លោក គឺយើងស្ទើរតែយល់ស្របគ្នាហើយត្រង់ចំណុច ហ្នឹង។ ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់តែម្តង កាលពីម្សិលមិញលោកថា ជនរងគ្រោះភាគច្រើនដែលលោក ធ្វើការជាមួយ លោកជួបជាមួយនោះ បានន័យថា មានជំងឺប៉ះទង្គិចផ្លូវចិត្ត។ គឺអ្នកទាំងអស់ហ្នឹង លោក បានន័យថា ភាគច្រើននៃជនរងគ្រោះទាំងអស់ហ្នឹង បានន័យថា អ្នកដែលមកទទួលការព្យាបាលនៅ គ្លីនិករបស់លោក ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** បាទ អ្នកដែលមកគ្លីនិក ហើយនិងអ្នកដែលទទួលសេវា ហើយនិងអ្នកទទួលសេវា ធី.ភី.អូ តាមរយៈ *អៅរីក* ដែលយើងចេញទៅផ្តល់សេវានៅតាមសហគមន៍។ អ៊ីចឹងមិនមែនមានតែនៅគ្លីនិក

នៅភ្នំពេញទេ។

[១៤:២៩:១៣]

**ស៖** សូមអរគុណ។ បើសិននិយាយអំពីប្រជាជនកម្ពុជាទាំងមូលតែម្តង តើលោកឯកភាពជាមួយខ្ញុំដែរឬទេ ថាការស្រាវជ្រាវហ្នឹង ហាក់ដូចជាបានបង្ហាញថាមិនមែនប្រជាជនកម្ពុជាទាំងអស់នោះគាត់ប៉ះទង្គិចផ្លូវចិត្តនោះទេ គឺបានន័យថា មានប្រជាជនតែមួយភាគបួនទេ ដែលគាត់ប៉ះទង្គិចផ្លូវចិត្ត។ បើសិនយើងគិតចំនួនប្រជាជនទាំងមូល។ តើលោកឯកភាពទេ ត្រង់ចំណុចហ្នឹង?

**ឆ៖** តើលោកសួរសំណួរហ្នឹង ផ្អែកទៅលើអី? ខ្ញុំអាចឆ្លើយទៅលោកវិញផ្អែកទៅលើឯកសារខ្លះ។ ឆ្នាំ២០០២-២០០៣ មានការសិក្សាមួយ – *ផាប់ផ្លូលេសិន ស្តាឌី* – ប៉ុន្តែយើងមិនបានធ្វើនៅក្នុងប្រទេសទាំងមូលទេ នៅខេត្តបី។ យើងសិក្សាអំពីជំងឺផ្លូវចិត្ត យើង *ស្ក្រីន* មើលតាំងពីកម្រិតទាបទៅកម្រិតធ្ងន់។ ហើយក្នុងចំណោមប្រជាជនក្នុងប្រហែលជាជាង១០០០នាក់ យើងធ្វើ*វិនដូម* នៅក្នុងខេត្តទាំងបីហ្នឹង។ ហើយលទ្ធផលនោះបង្ហាញថា *ធូ អៅ អូហ្វ ហ្វាយ* – ក្នុងចំណោមប្រាំនាក់មានពីរនាក់ដែលមានបញ្ហាផ្លូវចិត្តតាំងពីកម្រិតស្រាលដល់កម្រិតធ្ងន់។ អ៊ីចឹងរួមទាំង *ឌីប្រេសសិន អ៊ិនសាយធី* រហូតដល់*សាយកូស៊ីស*។ ហ្នឹងការសិក្សាមួយដែលធ្វើឡើង *ឌីយ៉ុង* ដែលបោះពុម្ពជាសៀវភៅមួយឈ្មោះថា "*ត្រូម៉ា វ៉រ អេន វ៉ាយអូឡេន*"។

[១៤:៣១:០៧]

ហើយថ្មីៗនេះការសិក្សារបស់សូនីស ហើយនិងក្រុមខូលិក ហ្នឹងនៅឆ្នាំ២០១២ គឺបានបង្ហាញថាគឺជា*ផាប់ផ្លូលេសិន ស្តាឌី* ដែលមានលក្ខណៈគួរឲ្យជឿ កត់សម្គាល់ដែលមានលក្ខណៈជឿទុកចិត្តបានច្រើនជាងគេ ទូលំទូលាយជាងគេ អាច *ជេននឺរ៉ែលឡាយ* – អាចធ្វើការសន្និដ្ឋានបានជាងហ្នឹង គឺថាក្នុងចំណោមអ្នកដែលមានអាយុលើ១៨ឆ្នាំហ្នឹង គឺមាន ភី.ធី.អេស.ឌី ដល់ប្រហែលជា១៤ភាគរយជាង។ បាទ អ៊ីចឹងនេះគឺជាតួរលេខខ្លះៗ ដែលខ្ញុំបានមើលអំពីការសិក្សារបស់អ្នកវិទ្យាសាស្ត្រផ្សេងទៀត។

**ស៖** ប្រហែលជាខ្ញុំមិនយល់ចម្លើយរបស់លោកទាំងស្រុង។ តើលោកឯកភាពដែរឬទេថា ភាគរយនៃប្រជាជនទាំងមូលនោះ គឺអ្នកប្រជាជន -- ភាគរយនៃប្រជាជនកម្ពុជាដែលប៉ះទង្គិច ដែលមានជំងឺ ភី.ធី.អេស.ឌី ហ្នឹងមានតែ១៤ភាគរយទេ។ តើលោកឯកភាពទេ?

[១៤:៣២:២០]

**ឆ៖** ១៤ភាគរយហ្នឹងគ្រាន់តែ ភី.ធី.អេស.ឌី ទេ។ អ៊ីចឹងបើយើងគិតដូចខ្ញុំលើកពីមុនអំមិញ

អ៊ីចឹង *ហ្វ័រម៉ាល់ ធូ សឺវៀស* – ពីកម្រិតសាលដល់កម្រិតធ្ងន់ហ្នឹងណា។ ការសិក្សាមួយហ្នឹងអាចជា *អិនឌីខេតទ័រ* – អាចបញ្ជាក់ថាអត្រានៃជំងឺផ្លូវចិត្តហ្នឹងមានច្រើន។ ក្នុងចំណោមប្រាំនាក់មានពីរនាក់។ អ៊ីចឹងជាសិក្សាមួយ។ ហ្នឹងមិនសម្គាល់តែពី ភី.ធី.អេស.ឌី មានទាំង *អិនសាយធី ឌីប្រេសសិន* ឬក៏ *សាយកូស៊ីស* អីផ្សេងៗទៀតជាដើម។

**ស៖** ខ្ញុំសូមរៀបចំសំណួររបស់ខ្ញុំឡើងវិញ។ តើលោកអាចនិយាយនៅពេលនេះបានដែរឬទេ តើមានប៉ុន្មានភាគរយក្នុងចំណោមប្រជាជនកម្ពុជា ដែលពួកគាត់នោះមានជំងឺមួយប្រភេទក្នុងចំណោមជំងឺផ្លូវចិត្តដូចដែលលោកបានរៀបរាប់ទាំងអស់ហ្នឹង? ដោយសារតែពួកគាត់បានឆ្លងកាត់កម្ពុជារបបកម្ពុជាប្រជាធិបតេយ្យពីចន្លោះពីឆ្នាំ៧៥ ដល់៧៩នោះ?

[១៤:៣៣:៣៥]

**ឆ៖** ឲ្យខ្ញុំនិយាយជំងឺទាំងអស់តែម្ដង ខ្ញុំមិនអាចសន្មតបានទេ។ ហើយខ្ញុំគ្រាន់តែបញ្ជាក់ថា ការសិក្ស -- បើសិនជាលោកឲ្យលើកជំងឺមួយ ខ្ញុំលើកការសិក្សាថ្មីចុះរបស់សូនីស។ គឺថា១៤ភាគរយនៃអ្នកដែលគាត់សិក្សាក្នុងចំណោម១០០០នាក់ជាងហ្នឹងគឺមានជំងឺផ្លូវចិត្ត។ ប៉ុន្តែការសិក្សាហ្នឹងខ្ញុំគិតថា វាមានលក្ខណៈដែលអាចជឿគួរទុកចិត្តជាងគេ ថ្វីត្បិតតែយើងមិនអាច *ជេនឺរ៉ាលឡាយ* ថាគាត់ ប្រជាជនទូទាំងប្រទេសមានអ៊ីចឹង។ យើងមិនអាចស្មានបានទេ ប៉ុន្តែជួនកាលបើសិនជាយើងអាចធ្វើក៏អាចមានច្រើនជាងហ្នឹងផង ពីព្រោះដូចខ្ញុំនិយាយបើសិនជាយើងប្រើ *ស្គ្រីននីងធូល* ដែលមានលក្ខណៈជា *ខាល់ធឺរ៉លី*– ដែលសមស្របតាមវប្បធម៌នោះ ប្រហែលជាអាចរកច្រើនជាងហ្នឹងទៀតបាទ។

**ឆ៖** ក៏ប៉ុន្តែកាលពីម្សិលមិញលោកពិតជាបានលើកឡើងថា ប្រជាជនភាគីច្រើន-- ខ្ញុំសូមបន្ថែមថា ពលរដ្ឋកម្ពុជាភាគច្រើនហាក់ដូចជាទទួលរងនូវជំងឺ រោគសញ្ញាទាំងអស់នេះ ច្រើនជាងប្រជាជនពិភពលោក ហើយប្រជាជនកម្ពុជានោះ គឺគាត់គេចវេះអំពីការលើកឡើងអំពីរបបកម្ពុជាប្រជាធិបតេយ្យក្នុងចន្លោះឆ្នាំ៧៥ ដល់៧៩។ នៅក្នុងចម្លើយរបស់លោកកាលពីម្សិលមិញនេះ គឺថាលោកទាញសន្និដ្ឋានតែម្ដងថាប្រជាជនភាគច្រើននោះ គាត់មានជំងឺនុំង។

[១៤:៣៥:៣៣]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ មេធាវីការពារក្ដីនោះ ហាក់ដូចជាមានការភ័ន្តច្រឡំរវាងពាក្យមួយចំនួន។ លោកអ្នកជំនាញគាត់និយាយអំពី១៤ភាគរយនៃការសិក្សាអំពីការប៉ះទង្គិចផ្លូវចិត្ត វិបត្តិផ្លូវចិត្តក្រោយការប៉ះទង្គិច គឺ ភី.ធី.អេស.ឌី។ ហើយម្សិលមិញនោះ គាត់និយាយថាភាគច្រើនក្នុងចំណោមហ្នឹងគឺថាមានបញ្ហាគឺថាគេចវេះ។ អ៊ីចឹងបើយើងមើលទៅគឺថាខុសគ្នា។ ភី.ធី.អេស.ឌី នេះគឺថាវាមាននិយមន័យច្បាស់លាស់ ហើយការប៉ះទង្គិចផ្លូវចិត្តជាលក្ខណៈទូទៅនោះ គឺមានន័យផ្សេង។ អ៊ីចឹងវាអាចលើសពី១៤ភាគរយ។ នេះជាការលើកឡើងនៅក្នុងការសិក្សាកាលពីឆ្នាំ២០០២ ដែលលោកអ្នកជំនាញគាត់យោងទៅដល់នោះ។

[១៤:៣៦:៣០]

ដូច្នេះការសួរសំណួររបស់មេធាវីការពារក្ដីហ្នឹង វាមិនស៊ីសង្វាក់គ្នាទេ ដោយសារតែគាត់មិនយល់ច្បាប់អំពីនិយមន័យនៃពាក្យទាំងអស់នេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

តំណាងសហព្រះរាជអាជ្ញាទំនងត្រូវ ក៏ប៉ុន្តែយើងមិនទាន់យល់ច្បាស់នូវអ្វីដែលអ្នកជំនាញឆ្លើយកាលពីម្សិលមិញ និងក្នុងថ្ងៃនេះ។ កាលពីម្សិលមិញ ខ្ញុំសង្កេតឃើញថាអ្នកជំនាញបានផ្ដល់សក្ខីកម្មឆ្លើយបញ្ជាក់ប្រជាជនកម្ពុជាភាគច្រើន។ ដូច្នេះខ្ញុំនៅពេលនេះ ព្យាយាមបង្ហាញឲ្យឃើញ ថាតើពាក្យដែលថាប្រជាជនភាគច្រើនហ្នឹង គាត់បានន័យយ៉ាងម៉េច? ហើយគឺតាមន័យហ្នឹងហើយ ទើបអ្នកជំនាញបានបញ្ជាក់អម្បាញ់មិញ។

ខ្ញុំព្យាយាមគ្រាន់តែធ្វើការបញ្ជាក់បំភ្លឺទៅលើសក្ខីកម្មរបស់អ្នកជំនាញតែប៉ុណ្ណោះ នៅពេលដែលគាត់លើកឡើងថាប្រជាជនកម្ពុជាភាគច្រើននោះ គាត់បានន័យយ៉ាងម៉េច? ហើយគាត់ផ្អែកលើមូលដ្ឋានអ្វីបានជាប៉ាន់ថាប្រជាជនកម្ពុជាភាគច្រើននោះ។

[១៤:៣៧:៤៧]

ប្រហែលខ្ញុំអាចបន្តទៅមុខទៀតបាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកអ្នកជំនាញ លោកបានស្ដាប់ឮការឆ្លើយតបខ្ញុំអម្បាញ់មិញទៅខាងតំណាងសហរាជអាជ្ញាហើយ តើលោកអាចជួយពន្យល់សាជាថ្មីទៅលើភាគរយ ១៤ភាគរយដែលលោកបានលើកឡើង

ហើយនូវអ្វីដែលលោកបានឆ្លើយកាលពីម្សិលមិញនៅពេលដែលគេសួរអំពីប្រជាជនភាគច្រើនដែលអាចទទួលរងជំងឺនោះ។ តើលោកអាចបញ្ជាក់ពន្យល់បន្ថែមទេ ត្រង់ចំណុចហ្នឹង?

[១៤:៣៨:១៨]

**លោក ឈឹម សុធារ៉ា៖**

**ឆ៖** បាទបើខ្ញុំលើក១៤ភាគរយហ្នឹងគឺសំដៅលើភី.ធី.អេស.ឌី។ ជាជំងឺមួយក្នុងចំណោមជំងឺផ្លូវចិត្តជាច្រើន។ បាទហ្នឹងទី១។ ហើយដែលខ្ញុំលើកថាប្រជាជនកម្ពុជាមានរោគសញ្ញា *អាវ៉យដិន ស៊ីមតូម* ច្រើនប្រជាជននៅ *ផុស្តុនផ្តិច (តាមសូរស័ព្ទ)* ផ្សេងទៀត បានន័យថាសញ្ញាគេចវេះ។ អ៊ីចឹងសញ្ញាគេចវេះហ្នឹងហើយ ដែលៗជាសញ្ញាមួយនៃអ្នកដែលមានត្រូម៉ា។ ជាសញ្ញាមួយរបស់ ភី.ធី.អេស.ឌី ដែរ។ អ៊ីចឹងដោយសារការគេចវេះហ្នឹង វាអាចបញ្ជាក់ថាមានប្រជាជនជាច្រើនទៀត ដែលមានបញ្ហាផ្លូវចិត្ត ប៉ុន្តែគាត់គេចវេះមិនចង់មករកសេវា មិនចង់និយាយរឿងរ៉ាវប្រាប់។ ហ្នឹងគឺបើសិនជាលោកសួរថាតើមានប្រជាជនប៉ុន្មាន ច្រើនទេ? គឺខ្ញុំៗសន្និដ្ឋានថា មានៗច្រើនទៀតដែលមានរោគសញ្ញា ហើយគាត់គេចដោយសារការគេចវេះហ្នឹងធ្វើឲ្យគាត់ហ្នឹងមិនចង់មកទទួលសេវា មិនប៉ានមកទទួលសេវា ដោយសារការភ័យខ្លាច ដោយសារការទទួលសេវារំឭកឡើងវិញនូវសញ្ញាហ្នឹង ធ្វើឲ្យគាត់ឈឺចាប់ ធ្វើឲ្យគាត់ហ្នឹងសម្រេចចិត្តថានៅសម្ងំហ្នឹងតែម្តង។ អ៊ីចឹងបើលោកបានលោកសួរថា អ៊ីចឹងគឺខ្ញុំថាមានច្រើនទៀត ដែលប្រហែលជាការសិក្សាហ្នឹងមិនទាន់បានចាប់យកបានផង។

[១៤:៣៩:៤១]

**ប្រធានអង្គជំនុំ៖**

អរគុណសាក្សី -- អ្នកជំនាញ។ អរគុណលោកមេធាវី។ ឥឡូវនេះដល់ពេលសម្រាកហើយ ប៉ុន្តែមុននឹងសម្រាកហ្នឹង សូមលោកអ្នកជំនាញអាចសម្រួលដើម្បីប្រើប្រាស់ភាសាខ្មែរបានទេ ពីព្រោះលោកប្រើប្រាស់ការហៅឈ្មោះប្រភេទជំងឺដែលជាភាពជំនាញរបស់លោកជាភាសាបរទេស។ អ៊ីចឹងការស្តាប់ហ្នឹងពិបាកយល់ៗណាស់។ ហើយអ្នកបកប្រែហ្នឹងប្រើភាសាហ្នឹងដដែល។ អ៊ីចឹងមកដូចវាអត់មានការបកប្រែអីផ្សេងទេ ហ្នឹងវាអាចនឹងមានបញ្ហា។ ហើយអ្នកស្តាប់ផ្សេងទៀត ជាពិសេសសារធារណជនក៏ដូចជាអង្គជំនុំជម្រះ រូបខ្ញុំនឹងផ្ទាល់ស្តាប់នូវឈ្មោះដែលប្រភេទអ្នកជំងឺផ្លូវចិត្តរបស់លោកដែលជាភាពជំនាញនោះអត់ច្បាស់ទេ ព្រោះលោកប្រើប្រាស់ភាសាបរទេស។ ហើយត្រឡប់មកវិញសង្ឃឹមថាលោកនឹងអាចប្រឹងប្រែងដើម្បីនិយាយបញ្ជាក់ជាភាសាខ្មែរ ដើម្បីជាប្រយោជន៍នៅក្នុងការស្វែងរកការពិតផង

ហើយជាប្រយោជន៍ក្នុងការយល់ដឹងអំពីស្ថានភាព ឬទិដ្ឋភាពជំងឺផ្លូវចិត្តនៅប្រទេសកម្ពុជាយើងបច្ចុប្បន្ន ផង។

បាទ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់អ្នកជំនាញរូបនេះសម្រាកនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបី។ សម្រាកចុះ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ។

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:១៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

[១៥:០១:៥១]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកអ្នកមានការពិភាក្សាគ្នាស្មុគស្មាញមែនទែនមុនពេលឈប់សម្រាកនេះ ដោយសារតែការប្រើប្រាស់វាមិនមែនជាពាក្យពេចន៍ខ្មែរ ហើយវាមិនច្បាស់លាស់ទៅដល់អ្នកដទៃ។ ដូច្នេះខ្ញុំសូមសង្ខេបចំណុចមួយដែលខ្ញុំយល់ថាវាមានសារៈសំខាន់។ តាមដែលខ្ញុំគិតថាយើង ខ្ញុំយល់ឃើញថាបើសិនណាជនរងគ្រោះភាគច្រើនដែលលោកធ្លាប់ធ្វើការជាមួយ ដែលគាត់ធ្លាប់ទទួលរងការប៉ះទង្គិចផ្លូវចិត្ត បាទ

វិបត្តិផ្លូវចិត្តក្រោយការប៉ះទង្គិចនោះ។ តើលោកអាចគិតថាចំណុចនេះវាកើតមានទៅលើប្រជាជនក្រោយរបបខ្មែរក្រហមទាំងអស់តែម្ដង ឬក៏យ៉ាងម៉េច?

[១៥:០២:៥៧]

**លោក ឈឹម សុធារ៉ា៖**

**ឆ៖** ខ្ញុំអត់ស្ដាប់ៗអត់យល់សំណួរ តើប៉ះពាល់ប្រជាជនក្រោយរបបខ្មែរក្រហម ឬមួយយ៉ាងម៉េច? ខ្ញុំអត់ទាន់ ច្បាស់សូមសួរមួយសាទៀត។

**ស៖** ថាតើវាត្រឹមត្រូវដែរទេ ដែលយើងឥឡូវនេះបានរកឃើញថា នៅពេលដែលលោកនិយាយពីជនរងគ្រោះភាគច្រើនដែលលោកបានធ្វើការជាមួយនោះ គឺថាពួកគាត់ទទួលរងពី ភី.ធី.អេស.ឌី ឬក៏ការគេច -- ទង្គិចផ្លូវចិត្ត តើក្នុងចំណោមហ្នឹងវាមាន -- លោកអាចនិយាយថាការប៉ះទង្គិចបែបហ្នឹងៗជាការប៉ះទង្គិចរបស់ជនរងគ្រោះដោយសារតែរបបខ្មែរក្រហមទៅលើជនរងគ្រោះទាំងអស់តែម្ដងឬម៉េច?

[១៥:០៣:៥៤]

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ថានៅពេលដែលយើងធ្វើការអង្កេត ដើម្បីស្រាវជ្រាវដូចហៅថា *ស្ក្រីននីង* មុនហ្នឹងណា ដើម្បីចម្រាញ់យកមើលអ្នកមានបញ្ហានុំង យើងប្រើកម្រងសំណួរមួយដែលទាក់ទងទៅនឹងប្រភេទនៃការប៉ះទង្គិចផ្លូវចិត្ត។ បាទ ប្រភេទនៃត្រូម៉ា នៃការប៉ះទង្គិចផ្លូវចិត្តដែលគាត់បានជួបប្រទះ។ ហើយគឺសឹងតែ១០០ភាគរយនៃអ្នកដែលយើងសម្ភាសហ្នឹង ដែលយើងឃើញថា គាត់មានប៉ះទង្គិចផ្លូវចិត្តហ្នឹងគឺសុទ្ធតែរឿងរ៉ាវប៉ះទង្គិចផ្លូវចិត្តក្នុងសម័យខ្មែរក្រហមទាំងអស់។ គឺមានតិចណាស់ដែលជួបរឿងរ៉ាវនៃការប៉ះទង្គិចផ្លូវចិត្តក្រោយសម័យខ្មែរក្រហម ដូចជាសង្គ្រាម ឆ្លងកាត់សង្គ្រាមដែលសង្គ្រាមរវាងរាជរដ្ឋាភិបាលជាមួយពួកខ្មែរក្រហម ឬក៏ជួនកាលអ្នកខ្លះ ដូចត្រឹមចោរប្លន់អីហ្នឹង គឺអាហ្នឹងវាតិចណាស់បាទ ។ អ៊ីចឹងភាគច្រើនគឺយើងឃើញថា ត្រូម៉ា គឺការព្រឹត្តិការណ៍ដែលគាត់ជួបប្រទះហ្នឹងរន្ធត់ហ្នឹងគឺទាក់ទងនឹងសម័យខ្មែរក្រហមបាទ។

**ស៖** ខ្ញុំសូមរៀបចំសំណួរឡើងវិញ។ ខ្ញុំបានអានអត្ថបទមួយ -- ណាយដែល-ហៀល ដែលលោកបានលើកឡើងហ្នឹង។ ខ្ញុំសូមដកស្រង់ លោកនិយាយថា “នៅក្នុងពេលប៉ះពាល់ដោយរបបខ្មែរក្រហមទៅលើផ្លូវចិត្តរបស់ប្រជាជនកម្ពុជា ត្រូវបានចងក្រងជាឯកសារយ៉ាងត្រឹមត្រូវ។ នៅក្នុងការសិក្សាស្រាវជ្រាវថ្មីៗអំពីស្ថានភាពផ្លូវចិត្តរបស់ប្រជាជនកម្ពុជា ១៤.២ភាគរយនៃអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានរកឃើញថា បានទទួលការប៉ះទង្គិចផ្លូវ -- វិបត្តិផ្លូវចិត្តក្រោយការប៉ះទង្គិច។ ហើយ

នៅក្នុងការសិក្សាមួយទៀតគឺថា ១១.៥ភាគរយនៃប្រជាជនកម្ពុជាទទួលរងការប៉ះទង្គិចផ្លូវចិត្តនេះ”។ ការសិក្សាពីរនេះ ទី១ គឺរកឃើញគឺ ១៤.២ មួយទៀត ១១.៥។ តើលោកយល់ស្របទេថាភាគរយដែលយើងលើកយកមកនិយាយនេះ នៅពេលដែលយើងមើលទៅលើការប៉ះទង្គិចផ្លូវចិត្តនៃប្រជាជនដែលរងគ្រោះដោយរបបខ្មែរក្រហម។ តើលោកយល់ស្របទៅលើភាគរយនេះទេ?

[១៥:០៦:៣៤]

**ឆ៖** បាទ សូមអរគុណ។ បើសិនបើលោកមើលទៅផ្នែកខាងចុងនៃអត្ថបទនោះ ដែលទាក់ទងទៅនឹង *លីមីតថេសិន* – បានន័យថាភាពខ្វះខាតនៃការសិក្សាហ្នឹង គឺថាការសិក្សាហ្នឹង វាមានរយៈពេលដូចថាមានចំនួនអីមិនគ្រប់គ្រាន់។ ដូច្នេះការសិក្សាមួយៗ វាតែងតែមានដូចថា *លីមីតថេសិន* – ការខ្វះខាតហ្នឹង។ អ៊ីចឹងសូមបញ្ជាក់ថា អ្នកខ្លះរកឃើញ១១, អ្នកខ្លះរកឃើញ១៤, អ្នកខ្លះរកឃើញ១៦, ១៧, អ្នកខ្លះរកឃើញក្រោម១០។ អ៊ីចឹងអាហ្នឹងខ្ញុំគិតថាមិនជាបញ្ហាទេ ប៉ុន្តែគ្រាន់តែថាជាបញ្ហា គឺយើងឃើញថាតួលេខហ្នឹង គឺវាមិនសូវជាខុសគ្នាប៉ុន្មាន។

**ស៖** តើវាត្រឹមត្រូវទេ បើសិនជាខ្ញុំនិយាយថា ៨៦ភាគរយនៃប្រជាជនដែលបានឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យគឺមិនទទួលរងនូវវិបត្តិផ្លូវចិត្តក្រោយប៉ះទង្គិចទេ។ តើខ្ញុំអាចនិយាយអ៊ីចឹងបានទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ -- អ្នកជំនាញកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១៥:០៨:០៤]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

អម្បាញ់មិញនេះអ្នកជំនាញបាននិយាយអំពីការសិក្សានៅឆ្នាំ២០១២ ដែលនិយាយអំពីដែលនិយាយថាមាន១៤ភាគរយ ដែលមានការប៉ះពាល់ផ្លូវចិត្តក្រោយវិបត្តិផ្លូវចិត្ត។ ហើយនៅក្នុងការស្ទង់មតិមួយទៀត គឺថាមានលើកពីហ្នឹង។ អ៊ីចឹងបានន័យថាតួលេខ១៤ភាគរយនេះ គឺវាពាក់ព័ន្ធតែមនុស្សដែលអាយុ១៦ឆ្នាំទៅ៣៥ឆ្នាំ តែប៉ុណ្ណោះទេ។ គឺជាមនុស្សដែលមិនបានឆ្លងកាត់របបខ្មែរក្រហម។ ដូច្នេះ គឺថាមានការខុសគ្នាបន្តិចបន្តួច ពីព្រោះថានៅក្នុងតួលេខ១៤ភាគរយកនេះ គឺនិយាយអំពីអ្នកដែលរស់នៅក្នុងរបបខ្មែរក្រហម ហើយនិងអ្នកដែលមិនបានឆ្លងកាត់របបខ្មែរក្រហម។ អ៊ីចឹងសំណួរដែលសួរនេះ គឺធ្វើឲ្យ

មានការភ័ន្តច្រឡំទៅដល់ភាគី ហើយនិងអ្នកជំនាញខ្លួនឯងផងដែរ។ បាទ សូមអរគុណលោកប្រធាន។

[១៥:០៩:១០]

**លោក រ៉ិចទ័រ កូប៉េះ**

លោកប្រធាន ខ្ញុំអត់យល់អំពីការជំទាស់នេះ។ ខ្ញុំបានអានពីរបាយការណ៍មួយដែលលោកអ្នកជំនាញមានលើកឡើង ពីគេហៅ ណាយដែល-ហ្សៀលនេះ ជារបាយការណ៍និយាយអំពីវិបត្តិផ្លូវចិត្តរួមនៃប្រជាជនដែលឆ្លងកាត់របបខ្មែរក្រហម ដែលពាក់ព័ន្ធទៅនឹងស្ថានភាពផ្លូវចិត្តរបស់ប្រជាជនកម្ពុជាដែលត្រូវបានចងក្រងយ៉ាងត្រឹមត្រូវ គឺការសិក្សាពីស្ថានភាពផ្លូវចិត្ត រកឃើញថា១៤ភាគរយនៃប្រជាជនជំនាន់ ទី១ នេះគឺមានការវិបត្តិផ្លូវចិត្តក្រោយការប៉ះទង្គិច។

**សួរដោយលោក រ៉ិចទ័រ កូប៉េះ**

**ស៖** សំណួរខ្ញុំស្នើសុំឲ្យមានការបញ្ជាក់ តើនេះមានន័យថា ប្រជាជនចំនួន៨៥.៥ភាគរយផ្សេងទៀតដែលរួចពីរបបខ្មែរក្រហម រស់រានពីរបបខ្មែរក្រហមនេះ មិនទទួលរងប៉ះទង្គិចផ្លូវចិត្តទេ។ តើខ្ញុំអាចនិយាយយ៉ាងដូច្នេះបានឬទេ?

[១៥:១០:២០]

**លោក ឈឹម សុធារ៉ា៖**

**ឆ៖** បាទ លោកមិនអាចនិយាយបានទេ។ ពីព្រោះពាក្យថា "ប៉ះទង្គិចផ្លូវចិត្ត" គឺមិនមែនមានតែជំងឺ ភី.ធី.អេស.ឌី ហ្នឹងទេ។ អ៊ីចឹងវាមានជំងឺច្រើនទៀត។ អ៊ីចឹងអ្វីដែលលើកនៅក្នុងនេះហ្នឹង គឺលើក ភី.ធី.អេស.ឌី។ អ៊ីចឹង ភី.ធី.អេស.ឌី វាមានប៉ុណ្ណឹងភាគរយមែន ប៉ុន្តែវាមានក្រៅពី ភី.ធី.អេស.ឌី ទៀត។ ដូចខ្ញុំបានលើកអ៊ីចឹង គឺថាមានជំងឺធ្លាក់ទឹកចិត្ត *(ឌីប្រេសសិន),* ជំងឺថប់អារម្មណ៍ *(អេនសាយធី)* ជំងឺ*សូម៉េថាយសេសិន* (ជំងឺឈឺចុកចាប់ពេញប្រាណ) ហើយនិងបញ្ហាចិត្តសង្គមផ្សេងទៀតដែលជាលទ្ធផលនៃការប៉ះទង្គិចផ្លូវចិត្ត។ អ៊ីចឹងការមានប្រសាសន៍របស់លោកថា៨០ជាងភាគរយទៀត មិនមាននោះ គឺជារឿងមិនត្រឹមត្រូវដែលខ្ញុំមិនយល់ស្រប។

[១៥:១១:២៤]

**ស៖** លោកអ្នកជំនាញ ខ្ញុំអត់យល់ទេ។ ខ្ញុំបានលើកឡើងខាងដើមហើយ គឺថាជំងឺធ្លាក់ទឹកចិត្តនេះ អត្រាគឺមានការសិក្សាស្រាវជ្រាវ គឺមានចំនួន១១.៥ភាគរយ គឺមានជំងឺធ្លាក់ទឹកចិត្ត។ តើនេះមានន័យថា ប្រជាជន៨៩.៥ភាគរយផ្សេងទៀត មិនមានជំងឺធ្លាក់ទឹកចិត្តទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ បើសិនជាលោកនិយាយតែធ្លាក់ទឹកចិត្តទទេ គឺត្រឹមត្រូវ។ ប៉ុន្តែបើលោកនិយាយថា ជំងឺបណ្តាលមកពីប៉ះទង្គិចផ្លូវចិត្ត គឺមិនពិតទេបាទ។ ពីព្រោះការប៉ះទង្គិចផ្លូវចិត្ត វាមានជំងឺច្រើន ធ្លាក់ទឹកចិត្ត ក៏មានចូលក្នុងហ្នឹងដែរ ហើយមានអីផ្សេងទៀត បាទ។

**ស៖** បាទ ឥឡូវនេះសូមផ្តោតទៅលើ ភី.ធី.អេស.ឌី វិបត្តិផ្លូវចិត្តក្រោយការប៉ះទង្គិច។ តើលោកដឹងទេ ថាតើតួលេខ១៤.២ភាគរយនេះ បើប្រៀបធៀបទៅនឹងបណ្តាប្រទេសផ្សេងទៀត ដែលមានវិបត្តិសង្គមកើតឡើង ឬក៏សង្គ្រាមកើតឡើងផងដែរ ឧទាហរណ៍បើបៀបធៀបប្រទេសកម្ពុជា បើនិយាយអំពី ភី.ធី.អេស.ឌី ជាមួយប្រទេសរវ៉ាន់ដា ជាមួយនឹង កូសូវ៉ូ ឬក៏បណ្តាប្រទេសផ្សេងដែលមានវិបត្តិសង្គមនេះកើតឡើង?

**ឆ៖** បាទ តាមការសិក្សារបស់សាស្ត្រាចារ្យ ឌីយ៉ុង ដែលបានសិក្សាទៅលើជំងឺផ្លូវចិត្តនៅក្នុងប្រទេសក្រោយសង្គ្រាម ដូចដែលបានលោករៀបរាប់ហ្នឹង គឺយើងឃើញថា នៅពេលនោះឆ្នាំជា២០០២ អីហ្នឹង យើងឃើញថា អត្រា ភី.ធី.អេស.ឌី មានប្រហែលជា២៨ភាគរយនៅកម្ពុជា។ អត្រានេះ គឺលើសអត្រានៅក្នុងប្រទេសរវ៉ាន់ដា នៅក្នុងប្រទេសស៊ូដង់ នៅប្រទេសយូហ្គាន់ដា នៅប្រទេសផាឡេស្ថាន ប៉ុន្តែទាបជាង ដូចជាខ្ញុំចាំ ដូចជាទាបជាងនៅក្នុងប្រទេសអាល់ហ្សេរី។ អីចឹងការសិក្សាដែលបញ្ជាក់នៅពេលនោះ។

[១៥:១៤:១៨]

**ស៖** លោកមានន័យថាភាគរយ ភី.ធី.អេស.ឌី នៅក្នុងប្រទេសកម្ពុជាខ្ពស់ជាងបណ្តាប្រទេសដទៃៗទៀតឬ?

**ឆ៖** បាទ នៅក្នុងការសិក្សាហ្នឹង គឺចាញ់តែប្រទេសអាល់ហ្សេរី មួយទេ ដែលមានរហូតដូចជា៣៥ភាគរយ។

**ស៖** នៅក្នុងអត្ថបទដដែល ណាយដែល-ហ្សៀល នេះ ខ្ញុំសូមអានអត្ថបទនេះដូចតទៅ៖

"ប្រជាជនកម្ពុជាជាច្រើនរូបដែលប្រឈមមុខទៅនឹងការប៉ះទង្គិចផ្លូវចិត្ត គឺចាប់ផ្តើមមានតាំងពីមុនរបបខ្មែរក្រហម ដោយសារតែការទម្លាក់គ្រាប់បែកដោយអាមេរិកាំងនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលសង្គ្រាមវៀតណាម ដែលបណ្តាលឲ្យមានអ្នករងគ្រោះ និងធ្វើឲ្យជនស៊ីវិលអត់មានកន្លែងស្នាក់អាស្រ័យ។ ហើយវាបន្តមកជាច្រើនឆ្នាំក្រោយពីការបញ្ចប់របបខ្មែរក្រហមក្តី គឺថាវាបន្តមានរហូតទៅដល់ជនភៀសខ្លួនដែលរស់នៅតាមជំរំជនភៀសខ្លួន"។

[១៥:១៥:៤៣]

តាមការសិក្សាស្រាវជ្រាវរបស់លោក ឬក៏ការយល់ដឹងរបស់លោក តើលោកអាចនិយាយបានថាភាគរយនៃ ភី.ធី.អេស.ឌី នៅក្នុងប្រទេសកម្ពុជានេះ វាខ្ពស់ជាងបណ្តាលប្រទេសដទៃ ដោយសារតែអំឡុងពេលនៃមុនរបបកម្ពុជាប្រជាធិបតេយ្យផង និងដោយសារតែព្រឹត្តិការណ៍ក្រោយកម្ពុជាប្រជាធិបតេយ្យផងបានទេ?

**ឆ៖** បាទ សូមបញ្ជាក់ថាអ្វីដែលលោកឡើង ហើយអ្វីដែលសរសេររៀបរាប់ក្នុងហ្នឹងគឺជាការស្រាវជ្រាវរបស់អ្នកសិក្សាមុន។ ជាឯកសារយោងរបស់អ្នកសិក្សាមុន មិនមែនជាការស្រាវជ្រាវរបស់ណាយដែល-ហៀល ទេ។ ចំពោះហេតុផលដែលលោកឡើង -- លោកលើកឡើងហ្នឹង គឺខ្ញុំគិតថា ភី.ធី.អេស.ឌី វាអាចមានមែនក្រោយការទម្លាក់គ្រាប់បែក។ ប៉ុន្តែបើយើងនិយាយថា អាពេលការទម្លាក់គ្រាប់បែក បើយើងគិតទូទាំងប្រទេស គឺវាអាចមានតែផ្នែកខ្លះទេ។

អ៊ីចឹងមិនដឹងថាយើងរកបានអ្នកដែលសិក្សា អ្នកដែលមកចូលសិក្សាហ្នឹងគឺជាអ្នកដែលជាជនរងគ្រោះដោយការទម្លាក់គ្រាប់បែក ឬក៏អីហ្នឹងអត់ទេ។ ប៉ុន្តែបើសិនជាយើងនិយាយអំពីសម័យខ្មែរក្រហម គឺទូទាំងប្រទេសតែម្តង។ អ៊ីចឹងអាការដែលទូទាំងប្រទេសហ្នឹងហើយ ដែលយើងគិតថាវាជះឥទ្ធិពលខ្លាំង ហើយក៏វាធ្វើឱ្យ វាគឺថាងាយមានភាពងាយរងគ្រោះ។ ជួនកាលទោះបីជាគាត់មិនទាន់ឈឺចាប់ គាត់មិនទាន់មានបញ្ហា ក៏ប៉ុន្តែក៏គាត់រងនូវ*វ័នណារ៉េប៊ីលីធី* -- គាត់មានភាពងាយរងគ្រោះទៅហើយ។ ហើយការងាយរងគ្រោះហ្នឹងហើយ ដែលជាកត្តាមួយដែលធ្វើឱ្យគាត់ហ្នឹងងាយនឹងមានជំងឺ នៅពេលដែលមានវិបត្តិអីបន្តិចបន្តួចកើតឡើងនៅពីលើបាទ។

[១៥:១៧:៤៤]

**ស៖** ថាតើលោកអាចស្វែងរកឃើញដោយរបៀបណា បើសិនណាអ្នកណាម្នាក់ទទួលរងនូវ ភី.ធី.អេស.ឌី វិបត្តិផ្លូវចិត្តក្រោយការប៉ះទង្គិចនេះ ពីអំឡុងពេលមុនឆ្នាំ៧៥ ឬអំឡុងពេលក្រោយឆ្នាំ៧៩? ថាតើគេអាចរកឃើញពីការប៉ះទង្គិចនូវព្រឹត្តិការណ៍នៅមុនពេលហ្នឹង និងក្រោយពេលហ្នឹងបានដែរឬទេ?

**ឆ៖** បាទ នៅក្នុងការសិក្សាជាច្រើន ដែលខ្ញុំធ្លាប់ឃើញ គឺគេសួរ គេមានកម្រងសំណួរសួរអំពីប្រភេទនៃការប៉ះទង្គិចផ្លូវចិត្ត ប្រភេទនៃ*ត្រូម៉ាទិកអ៊ីវេន*។ អ៊ីចឹងនៅគ្រប់ការសិក្សាភាគច្រើនដែលខ្ញុំបានជម្រាបជូនពីមុនអំមិញហ្នឹង គឺថាភាគច្រើននៃអ្នកដែលសិក្សាការប៉ះទង្គិចផ្លូវចិត្តហ្នឹង *ត្រូម៉ាទិកអ៊ីវេន* ហ្នឹង គឺភាគច្រើនគឺដោយសាររបបខ្មែរក្រហម។ អ៊ីចឹងហើយបានយើងធ្វើការសន្និដ្ឋានទៅថា រោគ

វិនិច្ឆ័យ រោគសញ្ញារបស់គាត់ហ្នឹងគឺវាហាក់ដូចវា *ខន់ស៊ីសស្តែន* – គឺវាសមស្របទៅនឹងព្រឹត្តិការណ៍ដែលគាត់ជួបប្រទះ។ អ៊ីចឹងហើយបានយើងគិតថា បញ្ហារបស់គាត់ហ្នឹងវាមានទំនាក់ទំនងជាមួយនឹងសម័យខ្មែរក្រហមច្រើនបាទ។

[១៥:១៩:១៤]

**ស៖** កាលពីម្សិលមិញលោកត្រូវបានដើមបណ្ដឹងរដ្ឋប្បវេណីសួរសំណួរ ហើយនិងក៏មានសំណួរសួរទៅដើមបណ្ដឹងរដ្ឋប្បវេណីនៅសប្ដាហ៍មុន និងដើមសប្ដាហ៍នេះ ដែលមើលទៅហាក់ឃើញថាដើមបណ្ដឹងរដ្ឋប្បវេណីភាគច្រើន ដែលមកផ្ដល់សក្ខីកម្មទទួលរងការឈឺចាប់ ទទួលការប៉ះទង្គិចផ្លូវចិត្ត ហើយក៏មានការវិបត្តិផ្លូវចិត្តក្រោយការប៉ះទង្គិចផងដែរ។ តើខ្ញុំអាចនិយាយយ៉ាងដូច្នេះបានទេថា ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់នេះ ដោយសារថាគាត់ជាផ្នែកមួយនៃប្រជាជនកម្ពុជា ជាចំណែកនៃចំនួនតួលេខ១៤.២ភាគរយ ដែលទទួលរងដោយ ទទួលរងវិបត្តិផ្លូវចិត្តក្រោយប៉ះទង្គិចបានដែរឬទេ?

**ឆ៖** លោកចង់សួរថាតើពួកគាត់ដែលមកហ្នឹង គឺស្ថិតនៅក្នុងចំណោម១៤ភាគរយ ឬក៏យ៉ាងម៉េច? ខ្ញុំអត់យល់។

**ឆ៖** ខ្ញុំមិនអាចសន្និដ្ឋានទេ អាចនៅក្នុងហ្នឹង អាចនៅក្រៅហ្នឹង ហើយអាចមានអ្នកនៅក្រៅហ្នឹងច្រើនទៀតដែលៗមិនបានបញ្ចូលនៅក្នុង១៤ភាគរយហ្នឹង។

[១៥:២០:៥៣]

**ស៖** ខ្ញុំសួរសំណួរតាមរបៀបនេះវិញ ថាតើការជ្រើសរើសដើមបណ្ដឹងរដ្ឋប្បវេណី១៦រូបដែលយកមកផ្ដល់សក្ខីកម្មនៅក្នុងតុលាការ និយាយអំពីការឈឺចាប់របស់ប្រជាជនកម្ពុជាទាំងមូលតែម្ដង។ តើមានការ វាជាជាប់ទាក់ទងណាមួយដែរទេ ចំនួនតួលេខនេះ និងទៅចំនួនប្រជាជនទូទៅតាមយោបល់លោក?

**ប្រធានអង្គជំនុំ៖**

កុំអាលទាល់ឆ្លើយតប លោកអ្នកជំនាញ!

សូមអញ្ជើញលោកស្រីមេធាវី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំសូមជំទាស់នឹងសំណួរនេះ។ ហេតុផលងាយស្រួលទេ គឺថាការជ្រើសរើសដើមបណ្ដឹងរដ្ឋប្បវេណីហ្នឹង គឺធ្វើដោយយើង។ អ៊ីចឹងខ្ញុំមិនយល់ទេថា ហេតុអ្វីបានជាគាត់និយាយទាក់ទង

នឹងលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសដើមបណ្តឹងរដ្ឋប្បវេណីនេះមកផ្តល់សក្ខីកម្មនេះ? មិនមែនជាការងាររបស់គាត់ទេ។

[១៥:២២:០៥]

**លោក វ៉ិចទ័រ កូប៉េះ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបខ្លីទេ។ ខ្ញុំព្យាយាមស្វែងរកឲ្យឃើញថា តើសក្ខីកម្ម និងផលប៉ះពាល់របស់ដើមបណ្តឹងរដ្ឋប្បវេណី វាតំណាងឲ្យការឈឺចាប់ពីរបបកម្ពុជាប្រជាធិបតេយ្យ ពីព្រោះយើងបានស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី១៦រូបបានផ្តល់ចម្លើយ ហើយគាត់លើកឡើងអំពីផលប៉ះពាល់របស់ពួកគាត់។ សំណួររបស់គាត់ថាតើក្រុមនេះ តំណាងឲ្យប្រជាជនកម្ពុជាដែលរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យរហូតមកទល់៧៩ ហ្នឹងទាំងមូលតែម្តងឬក៏អត់?

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញា!

[១៥:២៣:០៧]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាសំណួរនេះអាចមានមូលហេតុបាន បើសិនជាម្សិលមិញនោះ មេធាវីការពារនោះ មិនបានបញ្ជាក់អំពីការជំទាស់ដែលធ្វើឲ្យចេញថាតើអ្នកជំនាញនេះបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់សក្ខីកម្ម២-៣សប្តាហ៍មុននេះដែរឬក៏អត់។ តែគាត់នេះនៅបរទេសនោះ។ អ៊ីចឹងកាលគាត់នៅបរទេស ប្រហែលជាគាត់ទទួលបានព័ត៌មានប្រភពណាមួយក៏ប៉ុន្តែមេធាវីម្នាក់ដែលជំទាស់ ហើយចង់សួរថាតើអ្នកជំនាញនេះបានស្តាប់អ្វីដែលគេបាននិយាយនៅក្នុងសវនាការនេះទេ? តែឥឡូវនេះបែរជាចោទសួរទៅមេ -- ទៅអ្នកជំនាញនេះឲ្យទាញយក ទាញសេចក្តីសន្និដ្ឋានអីមួយទៅវិញ។ អ៊ីចឹងដូចជាអត់មានហេតុផលអីសោះ លោកប្រធាន។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២៤:៤០]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់របស់ខាងតំណាងសហព្រះរាជអាជ្ញាលើសំណួរនេះមានលក្ខណៈត្រឹមត្រូវសមស្របពីព្រោះលោកអ្នកជំនាញរូបនេះមិនបានតាមដានស្តាប់នូវកិច្ចដំណើរការសវនាការស្តាប់សេចក្តី

រៀបរាប់អំពីទុក្ខសោកព្យសនកម្ម និងការផ្ដល់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនដែលអង្គជំនុំជម្រះកំណត់ស្ដាប់នូវសេចក្ដីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនារបស់គាត់នៅក្នុងអំឡុងពេលកន្លងមកទេ។

អ្នកជំនាញមិនបាច់ឆ្លើយតបនឹងសំណួរចុងក្រោយដែលសួរឡើងដោយមេធាវី កូប៉េ នេះទេ!

**លោក វិុចទ័រ កូប៉េ៖**

លោកប្រធានខ្ញុំស្នើសុំតាំងសំណួរឡើងវិញខុសគ្នាទាំងស្រុងតែម្ដងៗនេះ។

[១៥:២៥:៣៨០]

**សួរដោយលោក វិុចទ័រ កូប៉េ៖**

**ស៖** លោកអ្នកជំនាញ តើលោកអាចជម្រាបអង្គជំនុំជម្រះបានទេ ថាតាមយោបល់តាមការយល់ឃើញរបស់លោក តើគួរតែការជ្រើសរើសដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីឲ្យយល់ឃើញថាជាតំណាងទៅឲ្យប្រជាជនដែលរងការឈឺចាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬអាចនិយាយម្យ៉ាងទៀតបានថាតើលក្ខណៈនៃការជ្រើសរើសជាតំណាងនេះដែលយើងចង់បាននេះ តើដើមបណ្ដឹងរដ្ឋប្បវេណីហ្នឹងគួរតែផ្ដល់សក្ខីកម្មបែបណា សូមលោកនិយាយអំពីលក្ខណៈដែលអាចធ្វើភាពជាតំណាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីប្រៀបធៀបទៅនឹងប្រជាជនទាំងអស់?

[១៥:២៦:៤៣]

**លោក ឈឹម សុធារ៉ា៖**

**ឆ៖** ខ្ញុំគិតថាខ្ញុំអត់មានតួនាទីក្នុងការកំណត់លក្ខខណ្ឌនៃការរើសអ្នកដើមបណ្ដឹងរដ្ឋប្បវេណីទេ ដូច្នេះមិនមែនកាតព្វកិច្ចរបស់ខ្ញុំ។

**ស៖** សូមសាកល្បងម្ដងទៀត ប្រសិនណាជាចំនួនភាគរយនេះវាត្រឹមត្រូវ ហើយតួលេខ១៤ភាគរយនៃអ្នកដែលរស់រានមានជីវិតពីរបបនោះគឺថាវាទទួលរិបត្តិផ្លូវចិត្តក្រោយការប៉ះទង្គិច។ គួរតែមានការជ្រើសរើសដើមបណ្ដឹងរដ្ឋប្បវេណី គឺគួរតែជ្រើសរើសប្រជាជនដែលត្រូវតែចេញមកពី៨៦ភាគរយដែលមិនរងការប៉ះទង្គិចនេះដែរឬយ៉ាងណា?

**ប្រធានអង្គជំនុំ៖**

សាក្សី -- អ្នកជំនាញមិនបាច់ឆ្លងតបនឹងសំណួរបែបនេះទេ! សំណួរនេះមិនត្រឹមត្រូវទេ។ ហើយម្យ៉ាងទៀត សំណួរនេះលោកអ្នកជំនាញបានបញ្ជាក់រួចហើយអំមិញគឺលោកមិនមានមុខងារ ភារកិច្ច ឬ

ក៏ភាពជំនាញ នៅក្នុងការកំណត់លក្ខខណ្ឌលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសរកដើមបណ្តឹងរដ្ឋប្បវេណីមកផ្តល់សក្ខីកម្មទេ។ ហើយលោក កូប៉េ ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះមិនមែនអាស្រ័យទៅលើអ្នកជំនាញ ជាអ្នកកំណត់ក្នុងការជ្រើសរើសក្នុងចំណោមប្រជាពលរដ្ឋរងគ្រោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ គឺជ្រើសរើសនៅក្នុងចំណោមអ្នកដាក់ពាក្យប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងអង្គហេតុទាំងឡាយដែលមាននៅក្នុងសំណុំរឿង០០២ តែប៉ុណ្ណោះ។

[១៥:២៨:៤៦]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ជាការត្រឹមត្រូវហើយលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សំណួរមួយទៀតធ្ងន់ធ្ងរបន្តិចចុងក្រោយហើយ សម្រាប់សួរទៅលោកអ្នកជំនាញ។ ទោះបីជាលោកមិនបានអញ្ជើញមកទីនេះក្តី នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីផ្តល់សក្ខីកម្មពីផលប៉ះពាល់ទាំងនេះ គេអាចសន្និដ្ឋានសរុបមកវិញថាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនតូចទេ គឺមិនបានរស់នៅក្នុងប្រទេសកម្ពុជាទេ អាចរស់នៅបារាំង ឬក៏នៅសហរដ្ឋអាមេរិក។ ដូច្នេះយល់ឃើញថាការប៉ះទង្គិចផ្លូវចិត្តហាក់បីដូចជាមាននៅលើប្រជាជនដែលរស់នៅប្រទេសបារាំង សហរដ្ឋអាមេរិកហ្នឹងខ្ពស់ជាង។ តើត្រឹមត្រូវទេភាគរយនៃប្រជាជនកម្ពុជាដែលរស់នៅក្រៅប្រទេសនោះ គឺវាមានកម្រិតការប៉ះទង្គិចផ្លូវចិត្តនេះខ្ពស់ជាង? អាចនិយាយបានដូច្នេះបានទេ?

**លោក ឈឹម សុធារ៉ា៖**

**ឆ៖** បើសិនជាយើងនិយាយអំពីចំនួនគឺចំនួនធៀបទៅនឹងចំនួនប្រជាជនកម្ពុជានៅបរទេសនុ៎ង។ បាទ អ៊ីចឹងភាគរយទោះបីជាភាគរយច្រើន ឬតិច ប៉ុន្តែចំនួនវាអាចមិនស្មើនឹងចំនួនអ្នកដែលនៅក្នុងស្រុកខ្មែរ។ ប៉ុន្តែបើយើងគិតទៅនៅក្នុងការសិក្សាមុនៗហ្នឹងគឺគេចង់បង្ហាញអំពីភាគធ្ងន់ធ្ងរ និងការបន្តមាននូវរោគសញ្ញារបស់បងប្អូនដែលយើងនៅប្រទេសក្រៅនោះ គឺនៅតែមានបន្តទោះបីជា២០ឆ្នាំ ៣០ឆ្នាំហើយក៏ដោយ។ តើខ្ញុំអាចបញ្ជាក់ច្បាស់ទេ?

[១៥:៣១:០២]

**ស៖** តើការពិតទេដែលថាប្រជាជនកម្ពុជារស់នៅក្រៅប្រទេសរងការឈឺចាប់ ឧទាហរណ៍ តើអាចនឹងទទួលការទទួលជំងឺធ្លាក់ទឹកចិត្ត ឬក៏វិបត្តិផ្លូវចិត្តក្រោយការប៉ះទង្គិចអីដែរឬទេ?

**ឆ៖** បាទ ដូចខ្ញុំជម្រាបជូនអង្គសវនាការម្សិលមិញអ៊ីចឹងគឺថា បងប្អូនយើងនៅប្រទេសក្រៅហ្នឹងក៏នៅតែមានការប៉ះទង្គិចផ្លូវចិត្តខ្លាំងណាស់ដែរ ដោយសារមូលហេតុជាច្រើន ថ្វីត្បិតតែគាត់មានសុវត្ថិភាព ថ្វីត្បិតតែគាត់មានការគាំទ្រសង្គមច្រើន ប៉ុន្តែគាត់ខ្វះការគាំទ្រខាងផ្នែកវប្បធម៌ ខាងផ្នែកសាសនា កន្លែងគោរពបូជា។ គាត់មិនអាចយល់ច្បាស់អំពីច្បាប់នៅប្រទេសផ្សេង គាត់មិនអាចទំនាក់ទំនងដោយសារតែពិបាកក្នុងភាសា កូនចៅជំនាន់ក្រោយរបស់គាត់មិនយល់អំពីគាត់។ អ៊ីចឹងលក្ខណៈទាំងអស់ហ្នឹងវាជាកត្តារំញោចមួយដែលគាត់ឲ្យនឹកឃើញនូវរឿងរ៉ាវ។

ហើយខ្ញុំឃើញការសិក្សារបស់សាស្ត្រាចារ្យ ដេវីដ ហេនតុន គឺបញ្ជាក់ច្បាស់អ៊ីចឹងគឺថា នៅចំនួនអតិថិជនដែលគាត់ព្យាបាលនោះគឺថាងាយនឹងមានកំហឹង ងាយនឹងមានជំងឺផានិក ជំងឺស្ពន់ស្ពោរ ជំងឺថប់អារម្មណ៍ណាស់ នៅពេលដែលគាត់មានទំនាស់ ឬក៏វិបត្តិអីជាមួយនឹងកូនចៅហ្នឹង ធ្វើឲ្យគាត់ហ្នឹងងាយនឹងនឹកឃើញអារឿងត្រូម៉ាហ្នឹងឡើងវិញ។ អ៊ីចឹងអាកត្តាទាំងអស់ហ្នឹងហើយដែលជាកត្តាខ្វះខាតរបស់ពួកគាត់ ដែលជាកត្តាបន្តឲ្យមានការឈឺចាប់ហ្នឹងតទៅទៀត។

[១៥:៣២:៤៥]

**ស៖** សូមអរគុណលោកអ្នកជំនាញ។ បាទ ចំណុចចុងក្រោយពាក់ព័ន្ធទៅនឹងតួលេខ៨៦ភាគរយទល់នឹង១៤ភាគរយនេះ។ តើលោកអាចបញ្ជាក់ទៅលើកត្តាមួយចំនួនដូចជាការអប់រំ កត្តាទ្រព្យសម្បត្តិ កត្តាស្ថានភាពសង្គម ឋានៈសង្គមរបស់ប្រជាជនដែលរងការប៉ះទង្គិច រងវិបត្តិផ្លូវចិត្ត។ តើអាចនិយាយបានថា អ្នកដែលរស់ឆ្លងកាត់ពីឆ្នាំ១៩៧០ ហ្នឹងអាចទទួលរងការប៉ះទង្គិចនេះច្រើន ជាងអ្នកដែលអប់រំខ្ពស់ៗហ្នឹងទទួលការប៉ះទង្គិចច្រើនជាងប្រជាជនរស់នៅជនបទជាកសិករនោះទេ?

**ឆ៖** បាទ ប្រសិនជាលោកមើលទៅលើការសិក្សារបស់ ហ៊្វីល យើងមើលថាទំនាក់ទំនងរវាងភី.ធី.អេស.ឌី ជាមួយនឹងកត្តាផ្សេងៗ។ ចំនួនត្រូម៉ាទិកអ៊ីវិន ចំនួននៃការប៉ះទង្គិចផ្លូវចិត្តដែលគាត់មានការគាំទ្រនៅក្នុងអំឡុងពេលសម័យខ្មែរក្រហមនោះ ដូចថាប្រសិនបើគាត់មានបញ្ហា ហើយគាត់អាចរត់រកអ្នកណាជួយបាន ស្ថានភាពសេដ្ឋកិច្ចរបស់គាត់ កត្តាទាំងអស់ហ្នឹងសុទ្ធតែមានទំនាក់ទំនងទៅនឹងជំងឺភី.ធី.អេស.ឌី បាទ។

[១៥:៣៤:២៥]

**ស៖** បាទ សំណួរចុងក្រោយរបស់ខ្ញុំ ដើម្បីប្រើវាក្យសព្ទពាក់ព័ន្ធទៅនឹងប្រជាជន១៧មេសា និងប្រជាជនមូលដ្ឋាន តើមានឱកាសណាមួយដែលអាចនឹងឲ្យរកឃើញ ភី.ធី.អេស.ឌី ឬក៏ជំងឺធ្លាក់ទឹកចិត្ត

ជាមួយប្រជាជន១៧មេសា ខ្ពស់ជាងអ្នកមូលដ្ឋានឬ? ថាតើប្រជាជន១៧មេសា មានឱកាសច្រើនដែលនាំឲ្យមានជួបប្រទះទៅនឹងវិបត្តិផ្លូវចិត្ត ឬជំងឺផ្សេងៗជាងប្រជាជនមូលដ្ឋានឬ?

**ឆ៖** ខ្ញុំមិនអាចសន្និដ្ឋានបានទេ ពីព្រោះខ្ញុំអត់បានសិក្សាអាហ្នឹងទេ ប៉ុន្តែខ្ញុំគ្រាន់តែបញ្ជាក់ថាអ្នកណាក៏ដោយ ឲ្យតែរងនូវការព្រឹត្តិការណ៍នៃការប៉ះទង្គិចផ្លូវចិត្តច្រើន គឺមានឱកាសដែលមានបញ្ហា ភី.ធី.អេស.ឌី ហ្នឹងច្រើន។ ដូចសិក្សារបស់ ណាយដែល-ហៀល ហ្នឹងបញ្ជាក់ហើយ គឺវាមានទំនាក់ទំនងរវាងចំនួននៃការប៉ះទង្គិចផ្លូវចិត្ត និងរោគសញ្ញារបស់ ភី.ធី.អេស.ឌី។ អ៊ីចឹងបើសិនជាអ្នក ១៧ មេសាមានប៉ះទង្គិចផ្លូវចិត្តច្រើន អ៊ីចឹងគាត់មានឱកាសនៅក្នុងការមានជំងឺ ភី.ធី.អេស.ឌី ច្រើនជាងអ្នកមូលដ្ឋាន។

[១៥:៣៥:៤៥]

**ស៖** បាទខ្ញុំនឹងបញ្ចប់មែនទែនហើយ។ តើលោកអាចនិយាយថាភាគរយប្រជាជនដែលមានការអប់រំខ្ពស់ ឬក៏មកពីដែលមានឋានៈសង្គមខ្ពស់អាចស្ថិតនៅក្នុងចំនួនតួលេខ១៤ភាគរយនៃអ្នកទទួលវិបត្តិផ្លូវចិត្តក្រោយការប៉ះទង្គិចនេះទេ?

**ឆ៖** ខ្ញុំពិបាកសន្និដ្ឋានណាស់ ពីព្រោះវាអាស្រ័យទៅលើអត្ថន័យរបស់ពួកគាត់។ ជួនកាលអត់មាននៅក្នុងអា១៤ភាគរយ ភី.ធី.អេស.ឌី ហ្នឹងទេ ប៉ុន្តែគាត់អាចនៅក្នុងអាប៉ុន្មានភាគរយនៃធ្លាក់ទឹកចិត្តនោះ។ ពីព្រោះអី? បើយើងមើលជំងឺធ្លាក់ទឹកចិត្ត ជាជំងឺដែលទាក់ទងទៅនឹងការបាត់បង់។ អ៊ីចឹងប្រហែលជាអ្នកដែលឋានៈខ្ពស់ ទ្រព្យសម្បត្តិច្រើន ប្រហែលជាគាត់ថាមានការបាត់បង់ច្រើន។ អ៊ីចឹងការដែលគាត់ឲ្យអត្ថន័យទៅលើការបាត់បង់ សារៈសំខាន់នៃរបស់របរ – *ប៊ីឡុងហ្គីញ* – ដែលគាត់បាត់បង់ហ្នឹងខ្លាំង គឺគាត់អាចមានធ្លាក់ទឹកចិត្តខ្លាំង។ អ៊ីចឹងអាធ្លាក់ទឹកចិត្ត ក៏ជាផ្នែកមួយនៃការប៉ះទង្គិចផ្លូវចិត្តដែរ។ អ៊ីចឹងគាត់អាចនៅក្រៅ១៤ភាគរយ ប៉ុន្តែមិនមែនមានន័យថាគាត់អត់ឈឺទេ គាត់អាចមានដែរ។

[១៥:៣៧:១១]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចប់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ

សំផន ដើម្បីមានឱកាសនឹងសួរដេញដោលចំពោះអ្នកជំនាញរូបនេះ។ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន សូមគោរពអង្គជំនុំជម្រះ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោក ឈឹម សុធារី -- បាទ សូមទោស សុធារ៉ា។ ខ្ញុំបានស្ដាប់លោកពីម្សិលមិញថាលោកមានអាយុ៤៥ឆ្នាំហើយឥឡូវនេះ។ លោកអាចបញ្ជាក់ពីថ្ងៃខែឆ្នាំកំណើតរបស់លោកបានទេ?

**លោក ឈឹម សុធារ៉ា៖**

**ឆ៖** ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៦៨។

**ស៖** បាទខ្ញុំចង់សួរបញ្ជាក់ថា នេះគឺជាឆ្នាំកំណើតរបស់លោកពិតប្រាកដ ឬមួយក៏ជាឆ្នាំដែលលោកប្រឌិតក្រោយទេ?

**ឆ៖** ខ្ញុំបន្ថយអាយុប្រហែលជាជិត៣ឆ្នាំ ក្រោយពីសម័យខ្មែរក្រហមមកដើម្បីចៀសវាងការគេចទាហាន។

[១៥:៣៨:៣០]

**ស៖** បាទសូមអរគុណ។ ទាក់ទងទៅនឹងការចូលសិក្សានៅមហាវិទ្យាល័យវេជ្ជសាស្ត្រ លោកចូលឆ្នាំណាដែរ? ខ្ញុំដឹងថាលោកបញ្ចប់នៅឆ្នាំ៩២។

**ឆ៖** ចូលឆ្នាំ១៩៨៦។

**ស៖** បាទអ៊ីចឹងលោកសិក្សាវេជ្ជសាស្ត្ររយៈពេល៦ឆ្នាំ។ បាទសូមអរគុណ។ ទាក់ទងទៅនឹងការសួរដេញដោលរយៈពេល២ថ្ងៃកន្លងមកនេះ ខ្ញុំបានស្ដាប់ឮថា លោកអត់បានធ្វើការសិក្សាទៅលើថាតើអត្រានៃប្រជាពលរដ្ឋខ្មែរប៉ុន្មានភាគរយដែលទទួលរងនូវការប៉ះទង្គិចផ្នែកផ្លូវចិត្តនោះទេ? តើអ៊ីចឹងត្រឹមត្រូវដែរទេ?

**ឆ៖** បាទសូមបញ្ជាក់ថា នៅក្នុងកម្ពុជាយើង មិនមានការសិក្សានៅក្នុងចំណោមប្រជាពលរដ្ឋទាំងអស់ទេ ដែលទាក់ទៅនឹងការប៉ះទង្គិចចិត្តផ្លូវចិត្ត។ ប៉ុន្តែការសិក្សាមួយដែលយើងហៅថា ការសិក្សាក្នុងប្រជាពលរដ្ឋដែលយើងអាចយក ដែលថាមានលក្ខណៈសុក្រឹតជាងគេ ជាងការសិក្សាដទៃហ្នឹង គឺការសិក្សារបស់ សូនីស នៅឆ្នាំ២០១២។

[១៥:៤០:០៦]

**ស៖** បាទ សូមអរគុណ។ ដោយឡែកទាក់ទងទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២នេះ លោកក៏អត់បានធ្វើសិក្សាទៅលើអត្រានៃការប៉ះទង្គិចផ្លូវចិត្តទៅលើអ្នកទាំងអស់នោះដែរ តើ អ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា អង្គការ ធី.ភី.អូ ដែលខ្ញុំធ្វើការហ្នឹង បានធ្វើការសម្ភាសអ្នកដើមបណ្ដឹងរដ្ឋប្បវេណីករណី០០២ បានចំនួន២៥០នាក់ហើយ។ យើងប្រើកម្រងសំណួរអំពីសុខភាពផ្លូវចិត្ត ហើយយើងបានឃើញអ្នកដែលមានបញ្ហាខ្លះហើយ ក្នុងការវិភាគដំបូងៗ។

**ស៖** បាទ សូមអរគុណ។ លោកដឹងថា តើដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នេះ មានចំនួនទាំងអស់ប៉ុន្មាននាក់ដែរទេ?

**ឆ៖** ខ្ញុំអត់ដឹងចំនួនពិតប្រាកដទេ ប៉ុន្តែប្រហែលថាជាង ប្រហែលជាជិត៤០០០នាក់ ចន្លោះពី៣០០០ជាង ទៅ៤០០០នាក់។

**ស៖** បាទសូមអរគុណ។ អ៊ីចឹងមានន័យថា លោកសិក្សាទៅលើដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នេះ ប្រហែលជា៦ភាគរយ ខ្ញុំស្មានទេ ទៅតាមតួលេខនេះ?

[១៥:៤២:០៥]

**ឆ៖** យើងធ្វើ ស្ត្រីននឹង ជាបន្ត។ ការសិក្សាហ្នឹងមិនទាន់ចប់ទេ គឺយើងធ្វើជាបណ្ដើរៗដោយសារយើងមានធនធានតិច។ អ្នកផ្ដល់ប្រឹក្សានៅក្នុងអង្គការយើង ដែលធ្វើការនៅក្នុងគម្រោងនេះ មានប្រហែលជាប្រាំមួយប្រាំពីរនាក់ទេ។ ដូច្នេះយើងមិនអាចមានសមត្ថភាពក្នុងធ្វើការជាមួយពួកគាត់ទាំង ៣០០០នាក់ ប៉ុន្តែយើងនឹងខំៗឲ្យច្រើន។ អ៊ីចឹងការសិក្សាហ្នឹងមិនទាន់ចប់ទេ បាទ។

**ស៖** បាទ សូមអរគុណ។ លោកបញ្ជាក់ពីពាក្យថា "ធ្វើការ" លោកនិយាយអម្បាញ់មិញនេះ ជាការស្រាវជ្រាវជាមួយគាត់ ឬក៏ជាវិធីផ្ដល់ជាឱវាទជាទីប្រឹក្សា ឬមួយក៏ជាវិធីព្យាបាល?

**ឆ៖** បាទ សូមបញ្ជាក់ថា ជាអន្តរាគមន៍ ជាការអន្តរាគមន៍ផ្លូវចិត្តទៅដល់គាត់។ ប៉ុន្តែនៅក្នុងអន្តរាគមន៍ដើម្បីឲ្យដឹងថា អន្តរាគមន៍ហ្នឹងមានប្រសិទ្ធភាព ឬក៏មិនមានប្រសិទ្ធភាព យើងធ្វើការសិក្សាស្រាវជ្រាវជាមួយអ្នកដែលយើងធ្វើអន្តរាគមន៍ហ្នឹង បាទ។

**ស៖** បាទ ខ្ញុំអត់យល់ពាក្យថា "អន្តរាគមន៍" នេះ លោកអាចជួយបញ្ជាក់ផង តើអន្តរាគមន៍នេះ មានលក្ខណៈដូចម្ដេច? ហើយវាមានផលប៉ះពាល់ ឬក៏ការធ្វើឲ្យធូរស្រាលយ៉ាងដូចម្ដេចដែរ?

**ឆ៖** បាទ អន្តរាគមន៍មានន័យថា ជាការជួយ។ ជាការជួយពួកគាត់ ជួយខាងផ្នែកផ្លូវចិត្ត ជាការផ្តល់ប្រឹក្សា ជាបុគ្គល ជាការផ្តល់ប្រឹក្សាជាក្រុម ជាការព្យាបាលដោយប្រើវេជ្ជសាស្ត្រ ហើយជាការធ្វើការព្យាបាលបែបសក្ខីកម្ម ហើយនិងការបង្កើតក្រុមជួយខ្លួនឯង។

[១៥:៤៤:០៧]

**ស៖** លោកសិក្សាទៅលើ លោកជាអ្នកដឹកនាំផ្ទាល់ក្នុងអាការផ្តល់ប្រឹក្សាយោបល់នេះ ដែលទាំងអស់ដែលលោកមាននិយាយថាពាក្យថា អន្តរាគមន៍ នេះ ឬមួយក៏មានអ្នកជំនាញដទៃទៀតចូលរួមក្រៅពីក្រុមរបស់លោក?

**ឆ៖** ដូចខ្ញុំជម្រាបជូនអ៊ីចឹង យើងមានក្រុម។ អង្គការ ធី.ភី.អូ មានក្រុមខាងផ្នែកផ្តល់សេវាសុខភាពផ្លូវចិត្តទៅដល់សាក្សី និងជនរងគ្រោះ និងដើមបណ្តឹងហ្នឹង គឺយើងធ្វើការជាក្រុម។

**ស៖** លោកអាចបញ្ជាក់បន្ថែម ពីក្រុមហ្នឹង ក្រុមធ្វើការចែកជាក្រុម ប៉ុន្តែធ្វើការដូចគ្នាទាំងអស់ ឬមួយក៏ក្រុមហ្នឹងផ្តល់សេវាផ្សេងៗគ្នា មានអ្នកផ្តល់ផ្នែកសម្ភារៈអ៊ីចឹងទៅ ឬក៏មួយក៏ផ្នែកខាងផ្លូវចិត្ត ឬក៏ផ្នែកជួយអីផ្សេងៗទៀត ខ្ញុំអត់ដឹងដែរ សូមលោកជួយពន្យល់?

**ឆ៖** មានន័យថា នៅក្នុងគម្រោងដែលអង្គការខ្ញុំបង្កើតហ្នឹងមានគ្នាប្រហែលជាប្រាំមួយ ប្រាំពីរនាក់។ ហើយទាំងអស់គ្នាសុទ្ធតែមានជំនាញនៅក្នុងការផ្តល់ប្រឹក្សា។ សុទ្ធតែមានជំនាញក្នុងការសម្របសម្រួលក្រុម ក្រុមដែលហៅការព្យាបាលផ្លូវចិត្តជាក្រុម។ សុទ្ធតែមានជំនាញនៅក្នុងធ្វើការព្យាបាលតាមបែបសក្ខីកម្ម – *តេស្តទីម៉ូណេតេរ៉ាពី* – សុទ្ធតែមានជំនាញក្នុងការព្យាបាលជាឱសថ។ អ៊ីចឹងយើងចែកគ្នា។ អ៊ីចឹងអ្នកខ្លះគាត់មកជួយគាំទ្រដល់សាក្សី និងដើមបណ្តឹងនៅក្នុងតុលាការ អ្នកខ្លះគាត់ទៅចុះទៅមូលដ្ឋានរបស់គាត់ ហើយអ្នកខ្លះនៅក្នុងទូរស័ព្ទ -- ទូរស័ព្ទហ៊តឡាញដើម្បីជួយ ហើយអ្នកខ្លះធ្វើការអប់រំជាពិសេសនៅវិទ្យុបាទ។

[១៥:៤៥:៥៩]

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់អំពីចំនួនអ្នកដែលមិនទទួលការប្រឹក្សាពីលោកបានទេ ទាក់ទងទៅនឹងជំងឺប៉ះពាល់ផ្លូវចិត្តនេះ បន្ទាប់ពីអង្គការរបស់លោកបានចាប់ផ្តើមបើកមកនោះ?

**ឆ៖** តាំងពីចាប់ផ្តើមបើកមក គឺខ្ញុំរាប់មិនអស់ទេ ច្រើនណាស់ ១ឆ្នាំៗរាប់ពាន់នាក់។ បាទ ១ឆ្នាំៗគឺរាប់ពាន់នាក់។ សរុបមកគឺ១៦ - ១៧ឆ្នាំហើយបាទ។

**ស៖** បាទ សូមអរគុណ។ តើលោកមានស្ថិតិច្បាស់លាស់ទេ ហើយលោកមានពិនិត្យទៅលើ

អត្រាអ្នកដែលមកលើកទី១ ហើយមកទី២ទៀត ឬក៏លើកទី៣ទៀត អ្នកដែលមកដដែលៗ ឬក៏អ្នកទាំងអស់ហ្នឹងសុទ្ធតែជាអ្នកថ្មីទាំងអស់?

**ឆ៖** បាទ សុទ្ធតែជាអ្នកថ្មី គឺចំនួនយើងរាប់កើតឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ខ្ញុំលើកឧទាហរណ៍នៅក្នុងគ្លីនិកមួយនៅភ្នំពេញ ក្នុង១ឆ្នាំយើងព្យាបាលជំងឺថ្មីប្រហែលជា៤០០ ទៅ ៥០០នាក់។ ហើយការព្យាបាលតាមដានបន្តនោះ ក្នុងមួយនាក់យ៉ាងហោចក្នុង១ឆ្នាំក៏ជួបយើងបានបួនដងទៅប្រាំដងដែរ។ អ៊ីចឹងបើយើងគិតពីការពិគ្រោះ គឺចូលដល់រាប់ ៥០០០, ៦០០០ការពិគ្រោះហើយបាទ។

[១៥:៤៧:៤៦]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងផលប៉ះពាល់ ដែលលើកឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ តើលោកមានមធ្យោបាយអីដើម្បីបញ្ជាក់ថា ផលប៉ះពាល់របស់អ្នកជំងឺរបស់លោកណាម្នាក់ដែលកើតឡើងដោយសារតែរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** បាទ សំណួរហ្នឹងខ្ញុំបានឆ្លើយទៅលោកមេធាវីមុនហើយ។ ខ្ញុំសូមបញ្ជាក់ថា យើងមានកម្រងសំណួរមួយដែលយើងសួរអំពីប្រភេទនៃការប៉ះទង្គិចផ្លូវចិត្ត។ ភាគច្រើននៃអ្នកដែលយើងផ្តល់អន្តរាគមន៍ ផ្តល់ការជួយហ្នឹងគឺសុទ្ធតែរៀបរាប់អំពីព្រឹត្តិការណ៍ផ្លូវចិត្តដែលកើតមានក្នុងសម័យខ្មែរក្រហម។ អ៊ីចឹងយើងមើលរោគសញ្ញាដែលគាត់មានឥឡូវ ជាមួយនឹងព្រឹត្តិការណ៍ផ្លូវចិត្តដែលគាត់ធ្លាប់ជួបប្រទះ អ៊ីចឹងយើងអាចសន្និដ្ឋានថា វាមានលក្ខណៈដែលសមស្របគ្នា។ អ៊ីចឹងយើងអាចសន្និដ្ឋានថាវាមានទំនាក់ទំនងទៅនឹងបញ្ហាដែលកើតមានក្នុងសម័យខ្មែរក្រហម។

[១៥:៤៩:០១]

**ស៖** បាទសូមអរគុណ។ អ៊ីចឹងខ្ញុំសូមបញ្ជាក់សាឡើងវិញ។ អម្បាញ់មិញនេះលោកមានប្រសាសន៍ថា កម្រងសំណួរដែលលោកប្រើនោះគឺទាក់ទងទៅនឹងសម័យខ្មែរក្រហម ផលប៉ះពាល់នានាទាក់ទងសម័យខ្មែរក្រហម។ អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** បាទ ចុះមានសំណួរផ្សេងទៀតក្រៅពីផលប៉ះពាល់នានាក្នុងសម័យខ្មែរក្រហមដែរទេ? ឧទាហរណ៍ ដូចជាសំណួរទាក់ទងទៅនឹងព្រឹត្តិការណ៍មុនសម័យកម្ពុជាប្រជាធិបតេយ្យ ឬក៏ក្រោយសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង?

**ឆ៖** មាន គឺមានព្រឹត្តិការណ៍នៅក្នុងជីវិតរបស់គាត់តែម្តង។ អ៊ីចឹងអាចមុនសម័យកម្ពុជាប្រជា

ធិបតេយ្យ អាចក្នុងពេលហ្នឹង ហើយអាចក្រោយ។ ប៉ុន្តែចំនួនភាគច្រើនដែលយើងជួប គឺនៅក្នុងចន្លោះពេលហ្នឹង។

[១៥:៥០:០៤]

**ស៖** លោកអាចបញ្ជាក់ពីកម្រងសំណួរហ្នឹងបានខ្លះៗជូនអង្គជំនុំជម្រះបានទេ?

**ឆ៖** បាទ ដូចជាការជួបប្រទះ ខ្ញុំមើលឲ្យស្ដាប់។ ខ្ញុំអត់បានជាប់មក ប៉ុន្តែកម្រងសំណួរហ្នឹង -- អ៎! នេះ។ ឧទាហរណ៍ថា តើលោកអ្នកបានធ្លាប់ជួបប្រទេះដោយផ្ទាល់ ឬដោយឃើញផ្ទាល់ភ្នែក ឬក៏ដោយស្ដាប់ឮនូវព្រឹត្តិការណ៍ទាំងឡាយផ្សេងអត់? ដូចជាព្រឹត្តិការណ៍ដែលទាក់ទងនឹងការដែលជួបនឹងគ្រោះថ្នាក់រៀបនឹងស្លាប់។ ព្រឹត្តិការណ៍ដែលទាក់ទងនឹងការបាត់ -- ខ្វះម្ហូបអាហារ ខ្វះជម្រក ត្រូវបានគេចាប់ជំរិត ត្រូវបានគេធ្វើទារុណកម្ម ត្រូវបានទៅជួបប្រទះនូវគ្រោះធម្មជាតិ ឬក៏ព្រឹត្តិការណ៍ផ្សេងៗទៀត ឃើញនូវក្រុមគ្រួសារត្រូវមានគ្រោះថ្នាក់ ឬក៏ស្លាប់អីជាដើមបាទ។

**ស៖** បាទសូមអរគុណ។ តើកម្រងសំណួរទាំងអស់នេះសួរសម្រាប់តែរយៈពេលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬមួយក៏លោកសួរក្នុងខ្សែជីវិតរបស់គាត់តែម្ដង?

[១៥:៥១:៥៥]

**ឆ៖** យើងសួរនៅក្នុងខ្សែជីវិតបាទ។ ប៉ុន្តែយើងឲ្យគាត់កំណត់ តើអាហ្នឹងកើតឡើងនៅចន្លោះណា? ចន្លោះកម្ពុជាប្រជាធិបតេយ្យ ឬក៏មុន ឬក៏ក្រោយ?

**ស៖** លោកឲ្យគាត់កំណត់យ៉ាងដូចម្ដេចទៅ សូមលោកជួយបញ្ជាក់បន្ថែមបន្តិចមក?

**ឆ៖** យើងសួរគាត់ថាព្រឹត្តិការណ៍ហ្នឹងកើតឡើងនៅចន្លោះពេលណា។

**ស៖** តើលោកបានមកវិញ បើយើងឃើញជាភាគរយវិញ ថាតើព្រឹត្តិការណ៍ដែលគាត់ឆ្លើយមកថាមានលក្ខណៈជាផលប៉ះពាល់ច្រើននោះ មានប៉ុន្មានភាគរយនៅក្នុងមុនរបបកម្ពុជាប្រជាធិបតេយ្យ? ហើយប៉ុន្មានភាគរយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ? ហើយក្រោយរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងប៉ុន្មានភាគរយ?

**ឆ៖** ខ្ញុំអត់បានគិតខាងហ្នឹងទេ ប៉ុន្តែខ្ញុំរាប់ចំនួនព្រឹត្តិការណ៍ដែលគាត់ជួបប្រទះវិញ។ អ៊ីចឹងឧទាហរណ៍ថា ដែលទាក់ទងនឹងព្រឹត្តិការណ៍គ្រោះថ្នាក់រៀបតែនឹងស្លាប់ហ្នឹងអាចមាន៩០ភាគរយ ប៉ុន្តែម្នាក់ៗមិនមានព្រឹត្តិការណ៍តែមួយទេ។ អ្នកខ្លះមានព្រឹត្តិការណ៍សម័យខ្មែរក្រហមផង អ្នកខ្លះមានព្រឹត្តិ-ការណ៍មុនផង អ្នកមានព្រឹត្តិការណ៍ក្រោយផង។ អ៊ីចឹងប៉ុន្តែខ្ញុំមិនបានកំណត់ថាប៉ុន្មានភាគរយដែលទាក់

ទងនឹងរបបមួយៗទេ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងអាយុរបស់អ្នកដែលលោកផ្តល់ប្រឹក្សាដល់ហ្នឹង តើលោកមានអត្រា មានកំណត់អត្រាអាយុទៀតទេ? ចាប់ពីអាយុប៉ុន្មានដល់ប៉ុន្មានៗភាគរយ ចាប់ពីអាយុប៉ុនណាដល់ប៉ុនណាប៉ុន្មានភាគរយហ្នឹងបាទ?

**ឆ៖** បាទ យើងមាន។ ជាទូទៅខាងសេវាយើង យើងទទួលព្យាបាលតែមនុស្សពេញវ័យទេ។ ហើយយើងមានចន្លោះអាយុ ប៉ុន្តែខ្ញុំអត់បានៗចាំអំពីតួរលេខទេ។

**ស៖** លោកអាចវាយតម្លៃទៅតាមការសិក្សារបស់លោកកន្លងមកថា ក្នុងចន្លោះអាយុពីដូចថា ៥០ឆ្នាំឡើងទៅ មានប៉ុន្មានភាគរយ ហើយក្រោមពី៥០ មក៣០ ប៉ុន្មានភាគរយ ហើយពីក្រោម៣០មក ប៉ុន្មានភាគរយ តើមានលោកអាចចាំបាន ហើយធ្វើការវាយតម្លៃបានទេ?

**ឆ៖** ខ្ញុំអត់ចាំបានទេ ប៉ុន្តែគ្រាន់តែថាភាគច្រើនគឺអាយុដូចជាលើសៗ ៤០ ទាល់តែមើលឯកសារបានខ្ញុំដឹងបាទ។

[១៥:៥៥:១១]

**ស៖** លោកនិយាយថាភាគច្រើនហ្នឹងកម្រិតច្រើនប៉ុនណា ភាគច្រើនប៉ុនណាដែរ អាយុលើស ៤០ហ្នឹង?

**ឆ៖** មានន័យថាអត្រាអ្នកទទួលសេវានៅក្នុងចន្លោះអាយុហ្នឹងច្រើនជាងអាយុផ្សេងៗទៀត។

**ស៖** លោកចាំថាលោកបែងចែកអាយុហ្នឹងជាប៉ុន្មានថ្នាក់ទេ ខុសប្លែកគ្នា ខុសគ្នាហ្នឹងប៉ុន្មានកម្រិតទេ?

**ឆ៖** ខ្ញុំអត់ចាំទេ ប្រហែលខ្ទង់ ៤ - ៥ ចន្លោះអាយុបាទ។

**ស៖** ពីអាយុមួយ ពីកម្រិតមួយទៅកម្រិតមួយខុសគ្នាប៉ុន្មានឆ្នាំដែរ?

**ឆ៖** ប្រហែលជា៥ឆ្នាំ។ ប៉ុន្តែខ្ញុំសូមបញ្ជាក់លោកថា នេះអ្វីដែលខ្ញុំនិយាយរៀបរាប់ជូនលោកហ្នឹងគឺជាលក្ខណៈអ្នកជំងឺដែលពួកខ្ញុំព្យាបាលនៅជំងឺផ្លូវចិត្តនៅភ្នំពេញបាទ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងខ្លួនលោកផ្ទាល់ ពីព្រោះតាមអ្វីដែលលោកបានឆ្លើយមកលោកបានបន្ថយអាយុប្រហែលជា៣ឆ្នាំ ប្រហែលលើសពី៣ឆ្នាំ។ អ៊ីចឹងប្រហែលជាលោកកើតនៅក្នុងឆ្នាំ១៩៦៥ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ខ្ញុំអត់ដឹងប៉ុន្តែឆ្នាំមមី។ អ៊ីចឹងប្រហែលខ្ទង់៤៨ អាចមិនលើស៣ឆ្នាំទេ គឺអាចក្រោម៣ឆ្នាំ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងបានន័យថាលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យលោកនៅក្នុងស្រុកខ្មែរដែរ ឬមួយក៏លោកនៅទីណាផ្សេង?

**ឆ៖** ខ្ញុំនៅស្រុកខ្មែរ ហើយស្រុកនោះឈ្មោះស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាលបាទ។

**ស៖** បងប្អូនគ្រួសាររបស់លោក នៅក្នុងស្រុកខ្មែរដែរទេ នៅសម័យនោះ?

**ឆ៖** បាទ នៅក្នុងស្រុកខ្មែរទាំងអស់គ្នា។

**ស៖** បាទ សូមអរគុណ។ តើមានបងប្អូណាមួយរបស់លោកមានជួបបញ្ហានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលជាបញ្ហាប៉ះពាល់ដល់ផ្លូវចិត្តដែលជាចំណុចដែលលោកធ្វើការសិក្សានេះដែរឬទេ?

**ឆ៖** ខ្ញុំមានបងស្រីបង្កើតដែលគាត់ស្លាប់នៅពេលហ្នឹងដោយសារជំងឺ។ ហើយមានបងប្អូនជីដូនមួយជាច្រើនទៀតដែលស្លាប់។ នៅសល់តែបងប្អូនកំព្រា។

[១៥:៥៨:៥២]

**ស៖** ទាក់ទងទៅនឹងបញ្ហាដែលលោកបានបង្ហាញថាពីជំងឺបាក់ស្បាត ខ្ញុំបានស្ដាប់កន្លងមកមានពេលខ្លះលោកប្រើថាជារោគសញ្ញា ពេលខ្លះលោកនិយាយថាជាជំងឺ តើអាមួយណាពិតប្រាកដ?

**ឆ៖** បាទ សូមអរគុណចំពោះសំណួរដ៏ល្អ។ ខ្ញុំកំពុងតែធ្វើការសិក្សាក្នុងការបង្កើតជាទ្រឹស្ដីនៃត្រូម៉ា តាមបែបវប្បធម៌របស់កម្ពុជា។ ការសិក្សាហ្នឹងបានមួយដំណាក់ហើយ។ ហើយយើងកំពុងតែឈានទៅមុខទៀត។ នៅក្នុងឥឡូវហ្នឹងគឺខ្ញុំអាចប្រើពាក្យសិនថាជា *ខនឌិសិន* – ជាលក្ខខណ្ឌនៃជំងឺ – ខ្ញុំមិនទាន់ហៅជំងឺមែនទែនទេ។ ប៉ុន្តែប្រជាជនខ្មែរយើងហៅជំងឺហើយ ខ្ញុំមានជំងឺបាក់ស្បាតហើយ បើខ្ញុំមិនទាន់ហៅទេ ដោយសារយើងជាអ្នកសិក្សា យើងត្រូវមានលក្ខខណ្ឌឲ្យសមរម្យបន្តិចដើម្បីបង្កើតវាមានអំណះអំណាងត្រឹមត្រូវ ដើម្បីកំណត់ថាជាជំងឺបានបាទ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ លោកសុធារ៉ា ខ្ញុំអស់សំណួរហើយ សូមអរគុណលោក។

**ប្រធានអង្គជំនុំ៖**

អរគុណ។ បាទ អរគុណលោកអ្នកជំនាញ ឈឹម សុធារ៉ា ការស្ដាប់សក្ខីកម្មរបស់លោកអ្នកជំនាញរហូតដល់ពេលនេះបានចប់ហើយ ហើយវត្តមានរបស់លោកអ្នកជំនាញនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។

អង្គជំនុំជម្រះសូមថ្លែងអំណរគុណចំពោះលោកដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះរយៈពេល២ពេលនៃពេលសវនាការ គឺស្មើនឹង១ថ្ងៃកន្លងមកនេះ ដោយភាពអំណត់អត់ធ្មត់ និងខិតខំប្រឹងប្រែងព្យាយាមអស់ពីលទ្ធភាព និងសមត្ថភាពក្នុងការឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលលំបាកៗជាច្រើន។ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។ សូមជូនពរជួបតែសំណាងល្អ មានសុខភាពល្អ និងបានសេចក្ដីសុខសេចក្ដីចម្រើន។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនអ្នកជំនាញរូបនេះវិលត្រឡប់ទៅកាន់ទៅកន្លែងជាគោលដៅដែលគាត់មានបំណងចង់ទៅ ឬក៏កាន់លំនៅដ្ឋានរបស់គាត់វិញបានហើយ។

[១៦:០១:២៣]

សវនាការនៅថ្ងៃនេះដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃសុក្រ ទី០៧ ខែមិថុនា ឆ្នាំ ២០១៣ ដោយចាប់ផ្ដើមពីម៉ោងប្រាំបីនិងសាមសិបនាទីព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មសាក្សី ស៊ីដនី ស្កេនប៊ឺក តាមមធ្យោបាយសោតទស្សន៍ពីទីក្រុងញូវយ៉ក សហអាមេរិក ហើយនៅពេលរសៀល អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាមTCW-665។ សូមភាគីនៃរឿងក្ដី បុគ្គលិកគាំទ្រដល់កិច្ចដំណើរការសវនាការនៃអង្គជំនុំជម្រះសាលាដំបូង និងសាធារណជនជ្រាប។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងឱ្យនាំខ្លួនពួកគាត់មកចូលរួមសវនាការវិញនៅព្រឹកថ្ងៃស្អែកឱ្យបានមុនម៉ោងប្រាំបីសាមសិបនាទី។ ដោយឡែកលោក នួន ជា ឱ្យគាត់នៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដើម្បីឱ្យគាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមមធ្យោបាយសោតទស្សន៍។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*